ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Jan-2017, 12:45
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅជំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៤៧៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៉ង

លោក រ៉ូជ័រ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក អៀង ផាន (2-TCW-1046) | ខ្មែរ |
| សាក្សី 2-TCW-1065 | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក អៀង ផាន** (2-TCW-1046)


សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ........ ទំព័រ ៣

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន ផ្ដើមពី ........ ទំព័រ ២០

សួរដោយលោកស្រី អង់តា ហ្គីសសេ ផ្ដើមពី........ ទំព័រ ២២


**ការសួរសំណួរទៅសាក្សី៖** 2-TCW-1065


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ៤២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី អៀង ផាន បញ្ចប់ ហើយនិងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1065។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ លើកលែងតែលោក ពេជ អង្គ មេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលបានជូនដំណឹងមកថា នឹងអវត្តមាននៅសវនាការព្រឹកនេះ ដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

[០៩:០២:៤២]

សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះគឺលោក អៀង ផាន។ លោកនិងមេធាវីប្រឹក្សាលោក ម៉ម រិទ្ធា មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ទៀតមានរហស្សនាម 2-TCW-1065។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅព្រឹកនេះ នៅចំពោះមុខលោកតាដំបងដែក មុននឹងផ្តល់សក្ខីកម្ម ហើយសាក្សីមានមេធាវីប្រឹក្សា លោក ចាន់ សម្បូរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណកញ្ញា ជា ស៊ីវហ៊ង។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះ និងវិលមុខ មិនអាចអង្គុយយូរបាន និងផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយខាងក្រោមសាលសវនាការនេះ។

[០៩:០៤:២០]

ផ្អែកលើមូលដ្ឋាននេះ និង យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សហការីទាំងអស់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំនៅមានប្រធានបទចំនួនបីទៀត ដែលត្រូវលើកយកមកសួរលោក តែឥឡូវនេះ ខ្ញុំសូមសួរភ្ជាប់ទៅនឹងអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញ។ នៅខាងមុខខ្ញុំហ្នឹង ខ្ញុំមានសេចក្ដីព្រាងប្រតិចារឹកសក្ខីកម្មរបស់លោក នៅម៉ោង១៥:២៩ លោកបានឆ្លើយដូចតទៅ ឥឡូវខ្ញុំសូមដកស្រង់ឡើងវិញ ដើម្បីឲ្យលោកស្ដាប់ឲ្យបានច្បាស់។ នេះគឺអ្វីដែលលោកបានឆ្លើយ នៅពេលដែលខ្ញុំចាប់ផ្ដើមសួរសំណួររបស់ខ្ញុំហ្នឹង គឺខ្ញុំសួរអំពីកងកម្លាំងប្រដាប់អាវុធខ្មែរ ដែលជួយគាំទ្រដោយកងកម្លាំងវៀតណាម។ លោកបានឆ្លើយថា សូមដកស្រង់៖ “អ្វីដែលខ្ញុំដឹង ក្នុងចំណោមកងទ័ពវៀតណាមហ្នឹង គឺមានកងទ័ពខ្មែរផងដែរ។ កងទ័ពខ្មែរទាំងនោះ គឺថាត្រូវបានគេបណ្ដុះបណ្ដាលនៅវៀតណាម ហើយកងទ័ពទាំងនោះ គឺជាអ្នកដែលរត់គេចចេញពីភូមិភាគបូព៌ា។ ខ្ញុំដឹងច្បាស់លាស់ក្រោយពេលធ្វើសមាហរណកម្មហើយ។ អ្នកខ្លះហ្នឹង គឺឧត្ដមសេនីយ៍ផ្កាយ<១ ឬផ្កាយ>២ គឺថាបាននិយាយថា គាត់ធ្លាប់ត្រូវបានបណ្ដុះបណ្ដាលនៅវៀតណាម អ៊ីចឹងឯង ទើបបានខ្ញុំយល់ច្បាស់អំពីបញ្ហានេះ។”

ហើយខាងក្រោយនេះ លោកឆ្លើយថា៖ “ពួកគាត់ខ្លះបានប្រាប់ខ្ញុំថា ពួកគាត់ចាកចេញពីកម្ពុជាហ្នឹង តាំងចុងឆ្នាំ៧៨ ហើយអ្នកខ្លះតាំងពីចុង៧៧ និងដើម៧៨ផងដែរ។ ហើយសព្វថ្ងៃនេះ ពួកគាត់ហ្នឹងអ្នកទាំងនោះ គឺថានៅតែធ្វើជាមេបញ្ជាការកងទ័ពសព្វថ្ងៃនេះ។” តើលោកនៅចាំទេ ថាក្រោយពេលលោកបានធ្វើសមាហរណកម្មនៅក្នុងឆ្នាំ១៩៩៧ <យូរប៉ុន្មានដែល>លោក<>បាននិយាយជាមួយឧត្ដមសេនីយ៍ផ្កាយ១ <ឬ>ផ្កាយ២ អំពីការបណ្ដុះបណ្ដាល<របស់ពួកគេ>នៅវៀតណាម<>?

[០៩:០៧:២៣]

**លោក អៀង ផាន៖**

**ផ៖** ខ្ញុំសូមបញ្ជាក់ថា ពិតជាបាននិយាយគ្នាពេលហូបបាយហូបអីហ្នឹង មិន -- និយាយលេងផង មែនផងហ្នឹង គឺថាគាត់បានប្រាប់ខ្ញុំថា គាត់បានទៅហ្វឹកហ្វឺននៅវៀតណាមតាំងពីឆ្នាំ៧៨ ដើមឆ្នាំ៧៨ អ្នកខ្លះពាក់កណ្ដាល៧៨ហ្នឹង។ ហ្នឹងគឺខ្ញុំបានភ្លាប់គាត់និយាយអ៊ីចឹង។ ហើយពីមុនមក ខ្ញុំបានបញ្ជាក់ហើយគឺថា ខ្ញុំមិនភ្លាប់មិនបានទេ ភ្លាប់អត់បានទេ ទើបតែសមាហរណកម្មហ្នឹង គឺបានដឹង ដឹង។

**ស៖** បាទ ខ្ញុំច្បាស់ហើយ។ តើលោកមានបំណងលើកឈ្មោះឧត្ដមសេនីយ៍ផ្កាយ១ ឧត្ដមសេនីយ៍ផ្កាយ២ ដែលលោកបាននិយាយគ្នាលេង ពេលពិសាបាយហ្នឹង? តើលោកអាចលើកឈ្មោះគាត់ទាំងនោះ

យកមកប្រាប់តុលាការបានទេ ឬក៏ថា លោករក្សាឈ្មោះទាំងនោះ ជាការសម្ងាត់?

**ឆ៖** ខ្ញុំហាក់មិនអាចជម្រាបថា ឈ្មោះអ្នកនេះ ឈ្មោះអ្នកនោះបាទ ព្រោះការយើងនិយាយលេង ហើយដល់មកនិយាយក្នុងតុលាការ ដូចជាមិនសមហេតុផល។ បាទ សូមអរគុណ។

**ស៖** ខ្ញុំយល់ អ៊ីចឹងហើយបានខ្ញុំសួរសំណួរទៅលោក។ ក៏ប៉ុន្តែបើយើងមិននិយាយឈ្មោះឧត្តមសេនីយ៍ដែលលោកបាននិយាយអម្បាញ់មិញនេះទេ។ តើលោកមានដឹងព័ត៌មានលម្អិត ដូចជា ថាតើពួកគាត់បានទទួលការបណ្តុះបណ្តាលនៅទីណា? គាត់បានជួបប្រជុំគ្នានៅឯវៀតណាមហ្នឹង នៅទីណាដែរ? តើចំណុចទាំងអស់នេះ លោកនឹកឃើញទេ ថាលោកបាននិយាយចូលដល់ចំណុចទាំងអស់នេះទេ?

[០៩:០៩:៣៥]

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំមិននិយាយចូលជ្រៅដល់ចំណុចនេះទេ គ្រាន់តែដឹងថា គាត់គ្រាន់តែប្រាប់ខ្ញុំថា គាត់បានទៅហ្វឹកហ្វឺន បានទៅហាត់រៀននៅវៀតណាមឆ្នាំ៧៨អ៊ីចឹង ប៉ុន្តែឲ្យចូលជ្រៅនៅកន្លែងណា ទីកន្លែងណា? ខ្ញុំមិនបានដេញដោលដល់កម្រិតនេះទេ។

**ស៖** តើពួកគាត់មានបាននិយាយប្រាប់លោកលម្អិតទេថា កងទ័ពវៀតណាមហ្នឹងមកពី<យោធា>ភូមិភាគណា <ដែលពួកគាត់បានសហការជាមួយ ឬក៏ទទួលការបណ្តុះបណ្តាលមកពីខាងណាដែរ? តើពួកគាត់មានប្រាប់លម្អិតរឿងទាំងអស់នេះទេ>?

**ឆ៖** ខ្ញុំសូមជម្រាបថា គាត់គឺទៅពីភូមិភាគបូព៌ា ឈ្មោះដែលបាននិយាយខ្ញុំ គាត់ទៅពីភូមិភាគបូព៌ាតែម្តង គឺអ្នកស្វាយរៀងនេះ។

**ស៖** ខ្ញុំយល់ហើយ។ <តើពួកគាត់មានបានប្រាប់លោកទេថា តើ>កងទ័ពវៀតណាម<ហ្នឹងជាអ្នកណា ដែលពួក>គាត់បានទទួលការបណ្តុះបណ្តាល ឬក៏ថាគាត់សហការជាមួយទ័ពខាងណាដែរនៅក្នុងឆ្នាំ១៩៧៨នោះ?

**ឆ៖** ចំណុចនេះ បើនិយាយពី ឲ្យខ្ញុំបញ្ជាក់ថា កងទ័ពវៀតណាមសហការជាមួយអ្នកណាខ្លះ គឺថាខ្ញុំក្តាប់មិនបានទេ។ ជារួមគឺថាក្តាប់អត់បានទេ មិនដឹងសហការយ៉ាងណាអីយ៉ាងណា ឬថាម៉េចផែនការរបស់វៀតណាម ខ្ញុំក្តាប់មិនជុំដែរ។

[០៩:១១:៣៨]

**ស៖** ខ្ញុំយល់ហើយ។ កងទ័ពយោធភូមិភាគទី៧របស់វៀតណាម បើខ្ញុំលើកឈ្មោះអំពីយោធភូមិភាគទី៧របស់កងទ័ពវៀតណាម តើលោកនឹកឃើញទេ?

**ឆ៖** ខ្ញុំមិនយល់ថាយោធភូមិភាគទីប៉ុន្មាននោះទេ ប៉ុន្តែគ្រាន់ថា វៀតណាមដែលវៃចូលនៅកម្ពុជានេះគឺមានច្រើនកងពល។ ហើយកងពលដែលធ្លាប់ទល់ជាមួយខ្ញុំហ្នឹងមានកងពល៣៣០, ៣៣៩, កងពលលេខ៧។ ឯយោធភូមិភាគខ្ញុំភ្លាប់មិនបានទេហ្នឹង ប៉ុន្តែបើដឹងកងពលដែលធ្លាប់ទល់ជាមួយខ្ញុំ មានអា៣៣០, ៣៣៩, លេខ៧។ លេខ៧ហ្នឹង មិនដឹងជាយោធភូមិភាគ ឬក៏ថាជាកងពលទេ។

**ស៖** ឧត្តមសេនីយ៍ ដុង វ៉ាន់កុង មានកងទ័ពវៀតណាមម្នាក់ឈ្មោះ ដុង វ៉ាន់កុង ហើយជាឧត្តមសេនីយ៍ តើលោកស្គាល់ទេ? <តើឈ្មោះនេះដែលធ្លាប់ត្រូវបានលើកឡើងនៅក្នុងការនិយាយគ្នារបស់លោកដែរ ឬទេ?>

**ឆ៖** ខ្ញុំអត់ស្គាល់ទេ។

**ស៖** ឥឡូវខ្ញុំសូមអានសម្រង់ចេញពីសៀវភៅមួយក្បាល <របស់បុគ្គលម្នាក់>ដែលគាត់បានផ្តល់សក្ខីកម្មជាអ្នកជំនាញក្នុងរឿងក្តីប្រឆាំងទៅនឹង ឌុច ឈ្មោះ ណាយ៉ាន់ ចាន់ដា។ សៀវភៅគាត់គឺ E3/2376 ទំព័រ<៣៣៩> អង់គ្លេស 00192524, បារាំង<00237170>, ខ្មែរ 00181682 *(ស៊ីក)*។ ខ្ញុំនឹងអានយឺតៗទេ ដើម្បីឱ្យអ្នកបកប្រែអាចតាមទាន់។ ហើយសំណួររបស់ខ្ញុំ ខ្ញុំនឹងសួរលម្អិតពីចំណុចនេះ ហើយនិងជួយរំឭកដល់ការចងចាំរបស់លោកផង។ ណាយ៉ាន់ ចាន់ដា គាត់បាននិយាយអំពីកិច្ចប្រជុំដ៏សំខាន់មួយ រវាងអតីត<>យុទ្ធជនបក្សកុម្មុនីស្តកម្ពុជា<ភូមិភាគបូព៌ា និងកងកម្លាំងយោធាមកពី>វៀតណាម។ គាត់បាននិយាយអំពីកិច្ចប្រជុំនៅពេលព្រឹក<>ថ្ងៃទី០២ ខែធ្នូ ឆ្នាំ៧៨ គឺកិច្ចប្រជុំនៅកណ្តាលចម្ការកៅស៊ូមួយ <ខាងកើត>ស្រុកស្នួល។ នេះគឺអ្វីដែលគាត់បាននិយាយ។

[០៩:១៤:៤៩]

ខ្ញុំសូមអានយឺតៗដោយប្រុងប្រយ័ត្ន សូមដកស្រង់៖ "ទីតាំងដែលត្រូវបានជ្រើសរើសសម្រាប់រណសិរ្សរំដោះជាតិកម្ពុជា<ថ្មី> យើងហៅថា យើងហៅថារណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ គឺយើងរើសកន្លែង២ម៉ាលមកខាងក្នុងទឹកដីកម្ពុជា។ គឺនៅក្នុងចម្ការកៅស៊ូមួយនៅ<>ខាងកើត<>ក្រុងស្នួល។ នៅព្រឹកថ្ងៃទី០២ ធ្នូ ៧៨ ខ្មែររាប់ពាន់នាក់បានប្រមូលជួបជុំគ្នានៅក្រោមកម្តៅព្រះអាទិត្យ ដើម្បីអបអរសាទរទៅដល់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។"

ហើយគាត់សរសេរបន្តទៀតគឺ៖ "ពេលនោះគេមានច្រៀងបទភ្លេងជាតិ<ថ្មីមួយ ហើយ>ទង់<ជាតិ>ពណ៌ក្រហម <លឿង ចំនួន១២ត្រូវខ្យល់>បក់រវិចៗ។ ហើយបន្ទាប់មកទៀត សមាជិក១៤នាក់នៃសមាជិកគណៈមជ្ឈិមរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា <ត្រូវបានគេប្រគល់ជូនបាច់>ផ្កា<

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែលនាំមកពី>វៀតណាម<> នៅពេលដែលគេណែនាំបង្ហាញពួកគាត់ទៅដល់អ្នកឈរចាំទទួលទាំងអស់។ <ប្រធាន>រណសិរ្ស<> ហេង សំរិន គឺបានអានកម្មវិធី<នយោបាយរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា>ហើយអ្នកដែលឈរនោះគឺថា បានស្រែកអបអរសាទរ<គាំទ្រ ដោយបោះកណ្ដាប់ដៃឡើងទៅលើ>។ ក្រោយកិច្ចប្រជុំនោះរួចមកលោក ហេង សំរិន <បានដើរទៅមុខ ដើម្បីថ្លែងអំណរគុណ ឡេ> ឌឹកថូ <ដែលឈរនៅសង្កេតមើលពិធីនោះពីចម្ងាយ ហាក់បីដូចជាមេមាន់មួយសប្បាយចិត្តនឹងកូនៗរបស់វាអ៊ីចឹង។ "ខ្ញុំមិននឹកស្មានថា អ្នករៀបចំពិធីបានល្អដូច្នេះសោះ។"> ហេង សំរិន គាត់ប្រាប់ទៅ ឌឹកថូ <>។" មានព័ត៌មានល្អិតបន្ថែមទៀត លោកសាក្សី ក៏ប៉ុន្តែកិច្ចប្រជុំមួយ<នេះ គឺធ្វើឡើងនៅក្នុងទឹកដីកម្ពុជា> នៅក្នុងខែធ្នូ ៧៨ នៅ<ជិត>ស្នួល គឺថាមាន<ខ្មែររាប់ពាន់នាក់>ទទួលអបអរសាទរគណៈកម្មធិការមជ្ឈិមរណសិរ្សនេះ<>។ តើ<នេះគឺជារឿងរ៉ាវដែលឧត្តមសេនីយ៍ទាំងអស់នេះនិយាយប្រាប់លោក? តើពួកគាត់មានវត្តមានដែរ ឬទេ? តើលោកអាចជួយបញ្ជាក់អំពីអ្វីដែលលោកចាន់ដា បានសរសេរនេះបានដែរ ឬទេ>?

[០៩:១៧:៤៧]

**ឆ៖** ខ្ញុំសូមជម្រាបថា ការងាររៀបចំនៅភូមិភាគបូព៌ា ហើយបង្កើតរណសិរ្សនេះគឺថា ខ្ញុំអត់បានដឹងទេ។ សូមជម្រាបត្រង់អ៊ីចឹងតែម្ដង អត់បានដឹង អត់បានយល់ទេ។

**ស៖** ខ្ញុំសួរអំពីចំណុចលម្អិតមួយទៀត គឺមានមនុស្សម្នាក់ដែល<គាត់បាននិយាយសំដៅយោងទៅលើនរណាខ្លះដែល>មានវត្តមាននៅក្នុងអង្គប្រជុំនោះដែរ ក៏ប៉ុន្តែជាអកុសល គឺថាគាត់បានទទួលមរណភាព២ថ្ងៃកន្លងនេះទៅហើយ អ៊ីចឹងគាត់មិនមានឱកាសនឹងមកផ្ដល់សក្ខីកម្មទេ។ នេះអ្វីដែល ណាយ៉ាន់ ចាន់ដា បាននិយាយអំពីបុគ្គលរូបនេះ<។ ខ្ញុំកំពុងតែនិយាយអំពី>លេខាធិការបក្ស<ប្រជាជនបដិវត្តន៍កម្ពុជា>ថ្មីគឺ ប៉ែន សុវណ្ណ។ គឺសៀវភៅ ណាយ៉ាន់ ចាន់ដា គឺអង់គ្លេស ERN 00192558, បារាំង <00237196>, ខ្មែរ 00191719 <>ឯកសារ E3/2376 ត្រង់ទំព័រ<៣៧៣> និយាយអំពីបក្សកុម្មុយនីស្តកម្ពុជា។ សុំដកស្រង់៖ "បក្សថ្មីនេះត្រូវបានដាក់ឈ្មោះឡើងវិញថា បក្ស<ប្រជាជនបដិវត្តន៍>កម្ពុជា ដែលមានសមាជិក៨០០នាក់។ តាមការពិត គឺថាជាអ្នកដែលគាំទ្រខាងវៀតណាម <របស់បក្សកុម្មុយនីស្តកម្ពុជា> ដែល ប៉ុល ពត កម្ទេចស្ទើរតែទាំងអស់ទៅហើយ។ លេខាបក្សថ្មីនេះគឺ ប៉ែន សុវណ្ណ ជាខ្មែរឥស្សរៈដែលបាននិរទេសពីហាណូយ<។ បក្សថ្មីបាននាំមកវិញនូវឯកភាពប្រជាជនឥណ្ឌូចិន>ត្រូវបានបំបាក់បំបែកដោយ ប៉ុល ពត។ ខុសពី ប៉ុល <ពត ដែលមិនទទួលស្គាល់ចំណងជា

បងប្អូននឹងវៀតណាម>, ប៉ែន សុវណ្ណ នេះគឺទទួលស្គាល់ថា បក្ស<ប្រជាជនបដិវត្តន៍>កម្ពុជា <នឹងធ្វើឲ្យប្រពៃណីដ៏ថ្លៃថ្នូររបស់>បក្សឥណ្ឌូចិន <ដែលបង្កើតឡើង>ដោយ ហូ ជីមិញ<បន្តទៅមុខទៀត>។" បញ្ចប់ការដកស្រង់។ នៅក្នុងការសន្ទនារបស់លោកជាមួយឧត្តមសេនីយ៍<ផ្កាយ១ ឬ> ឧត្តមសេនីយ៍<ផ្កាយពីរ> តើពួកគាត់មាននិយាយអំពីការបង្កើតបក្ស<ប្រជាជន>បដិវត្តន៍កម្ពុជា<ដែរ ឬទេ? តើពួកគាត់មានលើកឡើងអំពីអ្វីដែល>ប៉ែន សុវណ្ណ <បាននិយាយដែរ ឬទេ>? ប៉ែន សុវណ្ណ មានតួនាទីអ្វីដែរទេ? លោកនឹកឃើញទេ ហើយពួកគាត់មាននិយាយដល់ចំណុចទាំងនេះទេ?

[០៩:២១:០០]

**ឆ៖** ខ្ញុំសូមជម្រាបថា ពួកគាត់មិនបាននិយាយដល់ចំណុចនេះទេ។

**ស៖** ស្តាយដែរ ដែលគាត់មិនបាននិយាយ។ ដោយសារថា អង្គជំនុំជម្រះបដិសេធមិនកោះហៅបុគ្គលទាំងនេះ អ៊ីចឹងហើយបានខ្ញុំសួរលោកទៅដល់ចំណុចទាំងអស់នេះ។ ឥឡូវខ្ញុំចូលទៅប្រធានបទបន្ទាប់របស់ខ្ញុំ គឺខ្ញុំត្រឡប់ទៅសួរម្តងទៀតអំពីសក្ខីកម្មរបស់ ឈូក រីន។ មុនពេលខ្ញុំសួរលោកអំពីអ្វីដែល ឈូន រីន បានប្រាប់ទៅមន្ត្រីស៊ើបអង្កេត ខ្ញុំសួរសំណួរ<បើក>មួយ<ទៅកាន់លោក>ជាមុនសិន។ តើលោកមាននៅនឹកឃើញថាមានការប្រយុទ្ធណាមួយនៅមុនឆ្នាំ៧៥ រវាងកងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏ថាខ្មែរក្រហម ជាមួយនឹងវៀតណាម ជាមួយកម្លាំងវៀតកុង គឺមានន័យថា ការវាយប្រយុទ្ធគ្នារវាងបក្សកុម្មុយនីស្ត កងកម្លាំងបក្សកុម្មុយនីស្តវៀតណាម និងកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជា នៅមុនឆ្នាំ១៩៧៥?

**ឆ៖** ខ្ញុំសូមជម្រាបថា ចំណុចទាំងអស់នេះគឺថា ខ្ញុំមិនៗក្តាប់បាន ហើយក៏មិនៗយល់បញ្ហាដែរទាក់ទងនឹងបក្សកុម្មុយនីស្តកម្ពុជា និងបក្សកុម្មុយនីស្តវៀតណាមប្រយុទ្ធគ្នាអី គឺថាខ្ញុំផ្ទាល់គឺក្តាប់ៗមិនជុំតែម្តង។

[០៩:២៣:០៦]

**ស៖** ខ្ញុំព្យាយាមជួយរំឭកដល់ការចងចាំ<របស់លោក តាមរយៈការ>អានទូវអ្វីដែល ឈូក រីន ប្រាប់នៅហ្នឹង គឺ<E3/361> អង់គ្លេស 00766449, ខ្មែរ 00194463 ដល់64, បារាំង 00268880។ គឺគាត់និយាយអំពីអំឡុងពេលមុនឆ្នាំ១៩៧៥៖ "បក្សកុម្មុយនីស្តកម្ពុជាបដិសេធមិនសហការ ដោយសារថា វៀតណាមហ្នឹងចង់គ្រប់គ្រងយើង ហើយយើង<ចង់>ឯករាជ្យ។ អ៊ីចឹងឯងបានជាយើងមានទំនាស់គ្នាជាមួយវៀតណាម គឺឆន្ទៈរបស់វៀតណាមនោះ មហិច្ឆតាគឺចង់ក្តោបក្តាប់យើង។ ជម្លោះចម្បាំងរវាង

បក្សកុម្មុយនីស្តកម្ពុជា និងវៀតណាមគឺចាប់ផ្ដើមតាំងពីចំណុចនេះឡើងទៅ។ ហើយជម្លោះផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជា គឺបង្កើតឡើងដោយក្រុមមួយដែលគាំទ្រដោយវៀតណាម និងឯមួយក្រុមទៀតគឺថាប្រឆាំងជាមួយនឹងវៀត-ណាម។"

ហើយខាងក្រោមនេះបន្តិចៈ "នៅពេលដែលចលនានេះចាប់ផ្ដើមឡើង គឺថាក្រុមដែលគាំទ្រដោយវៀតកុងនោះ គឺក៏បានចាប់ផ្ដើមបង្កើតកងទ័ពរបស់ខ្លួន។ វៀតកុង<>បើកផ្លូវលំហូជីមិញ ដើម្បីផ្គត់ផ្គង់សម្ភារៈ<ដល់សង្គ្រាមរបស់ពួកគេ ប្រឆាំងជាមួយអាមេរិកនៅប្រទេស>វៀតណាម។ កត្តានេះបានជំរុញឲ្យមានកិច្ចសហប្រតិបត្តិការ>ខ្លីមួយរវាង<ខ្មែរក្រហម> និងវៀតកុង។ នៅឆ្នាំ៧៣ ការវាយប្រយុទ្ធជាមួយនឹងវៀតកុងក៏ចាប់ផ្ដើមឡើង។ ការវាយប្រយុទ្ធនេះដឹកនាំដោយ តាម៉ុក ពីក្នុងចំណោមខ្មែរក្រហមទាំងអស់នោះ។ នេះគឺបង្កើតបញ្ហានៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ហើយខ្ញុំមិន<យល់អ្វីៗទាំងអស់ ដែលបាន>កើតឡើង<>នោះទេ។" បញ្ចប់ការដកស្រង់។

ឥឡូវខ្ញុំសូមសួរលោកអំពីការពើបប្រយុទ្ធគ្នារវាងបក្សកុម្មុយនីស្តកម្ពុជា និងកម្លាំងវៀតកុង លោកថាលោកអត់ដឹងរឿងនេះទេ ក៏ប៉ុន្តែ ឈូក រីន និយាយអំពីកម្លាំងភូមិភាគនិរតីនេះ គឺថាបានវាយប្រយុទ្ធគ្នាជាមួយកងទ័ពវៀតណាម ហើយលោកជាទ័ពម្នាក់ដែលមានឋានន្តរស័ក្តិនៅក្នុងភូមិភាគនិរតី តើលោកធ្លាប់មានបានប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាមនៅក្នុងទឹកដីភូមិភាគនិរតីដែរឬទេ?

[០៩:២៥:៥៤]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ដកស្រង់ពីយោបល់របស់លោក ឈូក រីន។ លោក ឈូក រីន កាលនោះគឺគាត់នៅយោធាខេត្តកំពត ឯខ្ញុំនៅខាងតាកែវ ៧៣ហ្នឹង គឺខ្ញុំនៅខាងតាកែវ។ អ៊ីចឹងការវាយប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម ហើយនិងកងទ័ពកម្ពុជាគឺមានកើតឡើងនៅខេត្តកំពត បានជាលោក ឈូក រីន គាត់ដឹង។ ឯនៅខាងតាកែវនេះ អត់មានកើតឡើងរឿងកងទ័ពវៀតណាម ហើយនិងកម្ពុជាប្រយុទ្ធគ្នាទេ។ អ៊ីចឹងបើធ្វើនៅខេត្តកំពត យើងខ្ញុំក្តាប់មិនជុំទេ គ្រាន់តែឮល្វើយៗមកអ៊ីចឹង ដំណឹងក៏មិនច្បាស់លាស់ដែរ។ អាហ្នឹងសូមជម្រាបអ៊ីចឹង។ អ៊ីចឹងបានជាលោក ឈូក រីន គាត់ដឹង ព្រោះកាលហ្នឹងគាត់នៅក្នុងខេត្តកំពត។

**ស៖** បាទ ខ្ញុំយល់ហើយ។ ឥឡូវខ្ញុំសួរតាមរបៀបផ្សេងវិញ តើលោកមានជំហរអ្វីនិយាយអំពីការវាយប្រយុទ្ធគ្នានៅមុនឆ្នាំ៧៥ រវាងកងទ័ពវៀតណាមនិងកងទ័ពកម្ពុជា? តើការប្រយុទ្ធគ្នានេះវាញឹកញាប់ប៉ុនណាដែរ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំមិនអាចនិយាយថា មានការប្រយុទ្ធគ្នារវាងកងទ័ពកម្ពុជានិងវៀតណាមញឹកញាប់យ៉ាងនោះទេ ពីព្រោះអង្គភាពយើងខ្ញុំមិនបានប្រយុទ្ធផ្ទាល់ ហើយតាមដែលខ្ញុំដឹងពីមុនមកហ្នឹងគឺថា មានការប្រយុទ្ធគ្នានៅក្នុងខេត្តកំពត១ ក្នុងស្រុកឈ្ងូក ក្នុងស្រុកឈ្ងូក។ ឯខ្ញុំនៅខាងតាកែវនេះគ្រាន់តែឮដំណឹងអ៊ីចឹង ឯការប្រយុទ្ធផ្ទាល់ មិនមានទេ។

[០៩:២៨:០១]

**ស៖** លោក ស្ទីហ្វិន ម័ររីស នេះបាន<លើកឡើងនៅ>ក្នុងសៀវភៅរបស់គាត់<អំពី>"ការវាយប្រយុទ្ធជាញឹកញាប់" ហើយមានភស្តុតាងពីខាងវៀតណាមបានបង្ហាញថា នៅមុនឆ្នាំ៧៥ គឺមានការប្រយុទ្ធគ្នារហូតដល់១៧៤ដងឯណោះ។ តើតួលេខនេះ ដែល ម័ររីស គាត់លើកឡើងថាមានការប្រយុទ្ធគ្នាមុន៧៥ រហូតដល់១៧៤ដង ត្រឹមត្រូវទេ?

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

បាទ សូមឲ្យបង្ហាញលេខឯកសារយោងផង។

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំនឹងផ្តល់ជូននាពេលបន្តិចទៀតនេះ អំពីការដែល>លោក ម័ររីស <>និយាយថាមានការប្រយុទ្ធគ្នាជាញឹកញាប់។ ចំនួនតួលេខ១៧៤ដង ដែលប្រយុទ្ធគ្នានេះ គឺមិនមាននៅក្នុងសំណុំរឿងទេ។ ប៉ុន្តែវាសៀវភៅមួយសរសេរដោយ អេងហ្គល<ប៊ើត និង> កូស្យា <ដែលអាចរកបាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម។ ខ្ញុំក៏មិនច្បាស់ដែរ។>។ តាមការពិតទៅសៀវភៅនេះខ្ញុំមិនអាចយកមកប្រើបានទេ ខ្ញុំយល់ហើយ។ <ប៉ុន្តែសូមឲ្យខ្ញុំរៀបចំសំណួរឡើងវិញ។>

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ប៉ុន្តែឥឡូវខ្ញុំនិយាយអំពីការប្រយុទ្ធគ្នាថាក្រោម២០០ដងទៅចុះ តើវាអាចដល់ចំនួននេះទេលោក?

**លោក អៀង ផាន៖**

**ឆ៖** ខ្ញុំសូមជម្រាប ហើយបញ្ជាក់ថា រឿងប្រយុទ្ធគ្នានៅក្នុងអំឡុងឆ្នាំ១៩៧៣ រវាងកងទ័ពកម្ពុជានិងវៀតណាមនេះគឺថា អង្គភាពយើងខ្ញុំអត់បានប្រយុទ្ធផ្ទាល់ទេ អ៊ីចឹងខ្ញុំមិនបានដឹងថា ចំនួនដងប៉ុន្មានពិតប្រាកដ ហើយឯកសារនេះវាចេញមកពីវៀតណាមវិញ វាមិនមែនចេញមកពីកម្ពុជាឯណា។ អ៊ីចឹងវៀតណាមសរសេរប៉ុន្មានដង រយដងក៏បានដែរ អាហ្នឹងតាមខ្ញុំយល់។ អ៊ីចឹងឲ្យខ្ញុំសន្និដ្ឋានថា ឲ្យខ្ញុំដឹង ខ្ញុំ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិនដឹងទេ ពីព្រោះខ្ញុំ អង្គភាពខ្ញុំអត់បានប្រយុទ្ធ ខ្ញុំសូមជម្រាបអ៊ីចឹង។

[០៩:២៩:៥៩]

**សះ** គឺថាខ្ញុំយល់ស្របចំពោះការបំភ្លឺចំណុចនេះ។ ឥឡូវខ្ញុំចូលទៅប្រធានបទចុងក្រោយរបស់ខ្ញុំ ហើយខ្ញុំនឹងបញ្ចប់ការតាំងសំណួរទៅកាន់រូបលោកហើយ។ ខ្ញុំសួរអំពីមេបញ្ជាការកងទ័ពទាំងអស់នៅព្រំដែនជាមួយវៀតណាមគឺឈ្មោះ រ៉ែន។ យើងបាននិយាយគ្នាខ្លះៗរួចមកហើយម្សិលមិញអំពី រ៉ែន ហើយលោកថា គាត់មិននិយាយអីច្រើនទេ គាត់នេះគឺជាកូនប្រសាររបស់ តាម៉ុក តាមដែលខ្ញុំដឹងនោះ។ មានឯកសារមួយចំនួននៅក្នុងសំណុំរឿង <ត្រូវបានចុះហត្ថលេខា ដោយបុគ្គលម្នាក់ឈ្មោះ រ៉ែន> ឬក៏ថា<ត្រូវបាន>ចម្លងទៅឱ្យ<បុគ្គលម្នាក់> ឈ្មោះ រ៉ែន<>។ អ៊ីចឹងខ្ញុំសូមសួរលោកសិន ខ្ញុំ<យល់>ថាលោកប្រហែលមិនដឹងអំពីឯកសារនេះទេ មើលទៅ។ ក៏ប៉ុន្តែសូមឱ្យលោកពិនិត្យមើលឯកសារនេះ ហើយបញ្ជាក់មើលថា តើលោកអាចបញ្ជាក់បានថា ឈ្មោះ រ៉ែន នៅលើឯកសារនេះ ជាមេបញ្ជាការរបស់លោកហ្នឹង ឬក៏មិនមែនទេ នៅពេលដែលគេបញ្ជូនលោកទៅស្វាយរៀង?

លោកប្រធាន នេះគឺព្រឹកមិញនេះ យើងខ្ញុំបានបញ្ជូនអ៊ីម៉ែលទៅឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់សាលាដំបូង ដោយមានបំណងស្នើសុំប្រើប្រាស់ឯកសារតូចបួន ពាក់ព័ន្ធ -- ឯកសារទាំងអស់នេះ គឺថាមានឈ្មោះ រ៉ែន នៅខាងលើឯកសារនេះតែម្តង។ បាទ សូមការអនុញ្ញាត។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមការបញ្ជាក់មួយលោកប្រធាន ដោយសារគាត់ថា ឯកសារទាំងអស់នេះ សាក្សីមិនស្គាល់នោះទេ។ អ៊ីចឹងតើគាត់ចង់ប្រើឯកសារហ្នឹង ក្នុងបំណងអ្វី? គាត់ចង់បង្ហាញថាតែឈ្មោះ ហើយនិងហត្ថ-លេខាដែលមាននៅលើឯកសារហ្នឹង ហើយឱ្យសាក្សីបញ្ជាក់ ឬក៏យ៉ាងម៉េច? ព្រោះខ្ញុំមិនយល់ពីគោលបំណងរបស់គាត់ទេ។ បើសិនជាសាក្សីហ្នឹង គាត់មិនស្គាល់ឯកសារទាំងបួនហ្នឹងទៅហើយ តើគោលបំណងរបស់គាត់ហ្នឹង ដាក់ឯកសារហ្នឹងបង្ហាញដើម្បីអ្វី? សូមឱ្យគាត់ជួយបញ្ជាក់បន្តិច។

[០៩:៣២:២៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ស្របជាមួយនឹងការជំទាស់ហ្នឹង។ ធម្មតាទេ តែបើកាលណាឯកសារហ្នឹង<> សាក្សីមិន<បានផ្ញើ ឬក៏មិនបាន>ទទួល គឺថាសាក្សីមិនអាចនិយាយអ្វីបានទេ ចំពោះឯកសារនេះ<>។ ក៏ប៉ុន្តែការអនុវត្តជាក់ស្តែងនៅក្នុងតុលាការយើងនេះ គឺយើងតែងតែយកឯកសារពី ស-២១ ទៅបង្ហាញសាក្សីគ្រប់

ពេលវេលា។ គឺឯកសារទាំងនោះ គឺសាក្សីមិនដឹងទេ ដូចតែគ្នានឹងឯង។ អ៊ីចឹងឯងបានជាខ្ញុំក៏ធ្វើតាមការអនុវត្តជាក់ស្តែងរបស់យើងនេះដែរ។ ខ្ញុំយល់ឃើញថា គាត់មិនបាន<ផ្ញើ ឬ>ទទួលឯកសារនេះទេ តែយ៉ាងណា គឺថាខ្ញុំស្នើសុំការអនុញ្ញាតបង្ហាញឯកសារឲ្យសាក្សីមើល។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ ពេលខ្លះគឺយើងអាចបង្ហាញឯកសារដើម្បីរំឭកការចងចាំរបស់សាក្សី។ ឥឡូវនេះលោកកំពុងតែចង់ឲ្យសាក្សីហ្នឹង គាត់ចងចាំឡើងវិញ នឹកឃើញឡើងវិញ ឬក៏យ៉ាងម៉េច? គោលបំណងរបស់លោកចង់បានអ្វី? អ៊ីចឹងបានគេចោទសំណួរទៅលោកហ្នឹង។

[០៩:៣៣:៣៩]

**លោក វ៉ិចទ័រ កូប៉េ៖**

នេះជាសំណួរមួយដ៏គួរឲ្យចាប់អារម្មណ៍លោកចៅក្រម។ គឺខ្ញុំ<ចង់សួរគាត់ អំពីឯកសារដែលនឹងបង្ហាញជូនគាត់នោះ ថាតើគាត់អាចបញ្ជាក់បានទេថា នេះគឺជា> រ៉ែន <>ដែលជាមេបញ្ជាការរបស់គាត់ ឬក៏អត់? <គាត់អាចមើលខ្លឹមសារនៃសារទូរលេខបាន ហើយមើលឈ្មោះ> រ៉ែន ហ្នឹងតើ រ៉ែន ហ្នឹងប្រកបឈ្មោះហ្នឹងយ៉ាងដូចម្តេចដែរ? ហើយ រ៉ែន នៅលើសារទូរលេខនេះ តើ រ៉ែន ហ្នឹងឬក៏អត់ ពីព្រោះវាអាចមាន រ៉ែន <ពីរបីនាក់។ ជាពិសេស គឺពាក់ព័ន្ធនឹងឯកសារចម្លងជូន ខ្ញុំគិតថា>សាក្សី គាត់ពិតជាអាចបញ្ជាក់បាន<ថាតើ រ៉ែន ពិតជាត្រូវបានគេ>ចម្លងជូនទៅគាត់ <ពាក់ព័ន្ធនឹងឯកសារយោធា> ដូចជា តាមុត <ឬក៏ សុន សេន និង> អ្នកដទៃជាដើម។ល។

សូមជម្រាបដល់ភាគី <ឯកសារទាំងអស់ដែលខ្ញុំនឹងបង្ហាញជូន> សូមការអនុញ្ញាតលោកប្រធាន គឺឯកសារ E3/1044 និង E3/1151, E3/1079, E3/992 នេះគឺជាសារទូរលេខពីក្នុងរបបនោះតែម្តង។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឯកសារទី១ សូមបង្ហាញ ERN គឺឯកសារ E3/1044 អង់គ្លេស <00875624>, ខ្មែរ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<00020881>, បារាំង <00324864> ជាឯកសារចុះថ្ងៃទី<៣០> តុលា ៧៧ ចុះហត្ថលេខាដោយឈ្មោះ រ៉ែន ដែលមានកម្មវត្ថុថា សំណើសុំដកហូតសមាសភាពមិនល្អ ដែល<>សមាសភាពមិនល្អនេះបែងចែកជាបីប្រភេទ។ លោកសាក្សី ខ្ញុំសូមចាប់ផ្ដើមជាមួយនឹងឯកសារ E3/1044។ នៅផ្នែកខាងក្រោមនៃឯកសារនេះ លោកឃើញមានឈ្មោះ រ៉ែន ហើយ។ ហើយនៅក្នុងឯកសារនេះ ឈ្មោះរបស់គាត់នេះ ក៏ខ្ញុំ *ហាយឡាយ*ឲ្យលោកមើលផងដែរ គឺឯកសារ E3/1044 ចុះថ្ងៃទី៣០ ខែតុលា ៧៧, រ៉ែន។ លោកសាក្សី តើ រ៉ែន នេះជាមេបញ្ជាការរបស់លោកហ្នឹងឬ?

[០៩:៣៧:២៩]

**ចៅក្រម ក្លូឌា ហ្វេនស័៖**

<សូមទោស។ សំណួរនេះ គឺទូទៅពេកហើយ។ ខ្ញុំអាចមើលឃើញពីរបៀបដែលសួរបញ្ជាក់ពីបុគ្គលម្នាក់ហ្នឹង ដោយប្រើប្រាស់ឯកសារនេះ ប៉ុន្តែលោកអាចសួរគាត់ថា តើនេះគឺជារបៀបដែលគាត់សរសេរ ឬយ៉ាងណា បើសិនជាខ្លឹមសារឯកសារនេះត្រូវបានបង្ហាញ។ ប៉ុន្តែ-->

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកឃើញឈ្មោះ រ៉ែន នៅខាងក្រោមនៃទំព័រនេះ។ តើឈ្មោះ រ៉ែន នេះមេបញ្ជាការរបស់លោកហ្នឹងណា ប្រកបអីចឹងដែរឬ?

**លោក អៀង ផាន៖**

**ឆ៖** ឈ្មោះ រ៉ែន នេះគឺថា អក្សរនេះគឺត្រឹមត្រូវហើយ ប៉ុន្តែខ្ញុំសូមជម្រាបថា នៅក្នុងកងទ័ពហ្នឹងមាន រ៉ែន ពីរ។ រ៉ែន មួយគឺនៅខាងអន្លង់វែង, រ៉ែន មួយទៀតនៅខាងយើងសំឡូតនេះ។ អីចឹងឈ្មោះ រ៉ែន នេះសរសេរដូចគ្នា អីចឹងខ្ញុំចង់សួរទៅវិញថា រ៉ែន ដែលៗមានឈ្មោះនេះ តើ រ៉ែន នៅអន្លង់វែង ឬក៏ រ៉ែន នៅខាងសំឡូត? ព្រោះ រ៉ែន វាមានពីរ ហើយក្នុងនេះអត់ដាក់ជីតាដូចគ្នា។ ក្នុងនេះអត់ជីតាទេ អីចឹង រ៉ែន វាមានពីរ ហើយមេដូចគ្នា។

[០៩:៣៨:៥៧]

**ប្រធានអង្គជំនុំ៖**

ប៉ុន្តែលោកសាក្សី លោកពិនិត្យមើលឯកសារមើល ចំណងជើងឯកសារនេះ គឺគេដាក់ចេញមកពីកងទ័ពបដិវត្តន៍កម្ពុជា មន្ទីរសេនាធិការ ហើយនៅក្នុងអំឡុងនោះគឺឆ្នាំមួយពាន់ -- ខែ -- ថ្ងៃទី៣០ ខែ១០ ឆ្នាំ១៩៧៧។ ហើយបើសិនជាមាន រ៉ែន ពីរមែននោះ តើ រ៉ែន នោះធ្វើការនៅមន្ទីរសេនាធិការនៃកងទ័ព

ដូចគ្នា ឬក៏យ៉ាងម៉េច បានជាអាចមានការភ័ន្តច្រឡំ? បើសិនមើល វ៉ែន តែពាក្យតែមួយអ៊ីចឹង អាចមានបញ្ហា តែបើសិនជាមើលទម្រង់នៃលិខិតជាទូទៅ ប្រហែលជាលោកអាចយល់បាន ហើយអាចឆ្លើយសំណួរហ្នឹងបាន ព្រោះលោកស្គាល់ឈ្មោះ វ៉ែន ទាំងពីរនាក់។

**លោក អៀង ផាន៖**

**ផ៖** ខ្ញុំសូមជម្រាបថា ខ្លឹមសារឯកសារនេះ ទាក់ទងនឹងកងពល១១៧។ ១១៧នេះគឺនៅផ្នែកខាងជើង ខាងអន្លង់វែងទៅវិញ។ ហើយក្នុងឯកសារនេះទៀត ដាក់កងពលមួយទៀតដាក់ កងពល១៦៤។ ១៦៤ គឺនៅខាងទិសកំពង់សោម។ ហើយក្នុងឯកសារនេះ ដាក់មួយទៀតគឺ កងពល៨០១។ ៨០១ នេះក៏នៅទិសអន្លង់វែងដែរ។ ហើយភាគច្រើនគឺឯកសារនេះ គឺបីឯកសារគឺទិសអន្លង់វែង។ ហើយមួយឯកសារគឺទិសកំពងសោម ១៦៤ កោះកុង កំពង់សោម។ អ៊ីចឹងតាមខ្ញុំមើលឯកសារនេះ គឺ វ៉ែន នេះមិនមែន វ៉ែន សំឡូតទេ ពីព្រោះ វ៉ែន នេះទាក់ទងនឹងខ្លឹមសារនេះគឺ វ៉ែន នៅ៨០១ កងពល៨០១ កងពលតូច៨០១ នៅទិសអន្លង់វែង។ នេះតាមខ្ញុំយល់ឯកសារ។

[០៩:៤១:១១]

**ប្រធានអង្គជំនុំ៖**

លោកផ្ទៀងផ្ទាត់មើលឯកសារណា លេខប៉ុន្មាននុ៎ង? 3 លេខ E3/1044 អ្ហ៎?

**លោក អៀង ផាន៖**

**ផ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាល! កុំអាលទាន់!

ឥឡូវមើលមួយម្តង។ ឥឡូវមួយមកសិនណ៎ា។ គឺមើលសួរគឺបញ្ហា E3/1044 មួយសិនណ៎ា។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សូមអរគុណលោកប្រធាន ចំពោះការអន្តរាគមន៍នេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ឯកសារទី១ ដែលខ្ញុំបង្ហាញរបស់លោកហ្នឹង គឺចុះហត្ថលេខាដោយឈ្មោះ វ៉ែន ប៉ុន្តែឯកសារបីដទៃទៀតនេះ គឺចម្លងជូនទៅ វ៉ែន វិញទេ មិនមែនជាឯកសារដែល វ៉ែន ជាអ្នកបញ្ជូនចេញទេ។ អ៊ីចឹងសុំតាមមើលមួយៗ សុំផ្តោតតែទៅលើឯកសារទី១សិនបានហើយគឺ E3/1044

01377089


ទុកឯកសារបីផ្សេងទៀតមួយអន្លើសិន។ តើ រ៉ែន ដែលនៅលើឯកសារ E3/1044 នេះ ជា រ៉ែន ដែលជាមេបញ្ជាការរបស់លោកនៅ<ពេលដែលលោកនៅស្វាយរៀង>?

[០៩:៤២:២៤]

**លោក អៀង ផាន៖**

**ឆ៖** ជា រ៉ែន ៗកូនប្រសា តាម៉ុក ជាមេបញ្ជាការកងពលធំនៅស្វាយរៀង នេះឯកសារនេះ។

**ស៖** ខ្ញុំនឹងត្រឡប់មកសួរឯកសារទី១វិញ។ ឥឡូវយើងចូលទៅសួរឯកសារបីទៀតភ្លាមៗតែម្តង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សុំបញ្ជាក់ តើលោកអាចសួរគាត់បានទេថា ម៉េចបានគាត់វាដឹងច្បាស់ថា រ៉ែន នេះជា រ៉ែន ហ្នឹងហើយ? <ដូច្នេះយើងនឹងមាននៅក្នុងកំណត់ត្រា។>

**លោក វ៉ិចទ័រ កូប៉េ៖**

<ការដែលខ្ញុំត្រឡប់មកនិយាយអំពីឯកសារទាំងនេះ គឺ>ខ្ញុំគ្រាន់តែ<យោងដោយសង្ខេបទៅលើ>ឯកសារបីផ្សេងទៀតនេះ ដែលគេចម្លងជូន<គាត់ ហើយបន្ទាប់មកខ្ញុំ ខ្ញុំនឹងត្រឡប់មកសួរអំពី>ឈ្មោះ រ៉ែន នេះវិញ <ដោយសារតែវាគឺជាឯកសារសំខាន់ដែលខ្ញុំចង់ពិភាក្សាដេញដោល។ ដូច្នេះ-->

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

យើងខ្ញុំសុំ<ឲ្យមានការ>បញ្ជាក់អំពីកាល<បរិច្ឆេទ>ឲ្យច្បាស់លាស់ផង ពីព្រោះថា គេបញ្ជូន<រ៉ែន ពីភូមិភាគនិរតី> ទៅស្វាយរៀង <ផងដែរ> ហើយអាចពេលនោះគាត់មកនៅស្វាយរៀង <ក៏គាត់អាចមិននៅស្វាយរៀងដែរ>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវខ្ញុំអ៊ីចឹង ខ្ញុំចូលទៅឯកសារបីផ្សេងទៀតសិន។ ជាមួយនឹងជំនួយការពីមេធាវីប្រឹក្សារបស់លោក សុំមើលឯកសារបីផ្សេងទៀត។ ទី១ គឺ E3/992 ដែលមានកម្មវត្ថុថាស្នើសុំរាយការណ៍ជូនសេនាធិការ ចុះថ្ងៃទី០២ មីនា ៧៨ ដែលមកពីកងពល១១៧។ ឯកសារនេះ គឺចម្លងជូនបង៨៩ (សុនសេន), បងណាត, <ផ្ញើជូនមន្ទីរឯកសារ និង>បងរ៉ែន។ អ៊ីចឹងឯកសារនេះមក ផ្ញើបញ្ជូនមកពីកងពល ១១៧ ដែលចុះហត្ថលេខាដោយ រ៉ុម ហើយចម្លងជូនទៅ បងរ៉ែន។ តើ បងរ៉ែន ដែលគេចម្លងជូននេះជាមេបញ្ជាការកងពលនោះឬ? ហើយប្រសិនបើជាយ៉ាងដូច្នេះមែន តើលោកដឹងដោយរបៀបណា?

[០៩:៤៤:៤៥]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក អៀង ផាន៖**

**ផ៖** ខ្ញុំសុំជម្រាបថា ខ្ញុំពិនិត្យតាមឯកសារនេះ ហើយតាមខ្ញុំដឹងគាត់ជាមេបញ្ជាការកងពលធំទេ ប៉ុន្តែចម្លងជូន រ៉ែន នេះ ហើយនិងឯកសារនេះ គាត់ទៅជាអគ្គសេនាធិការវិញ។ អ៊ីចឹងគាត់ឡើងឋានៈអី ខ្ញុំៗអត់បានដឹងដែរ អ៊ីចឹងខ្ញុំដឹងថាគាត់កងពល។ អ៊ីចឹងបើគាត់សេនាធិការ គ្រប់កងពលទូទាំងកម្ពុជាប្រជាធិបតេយ្យហ្នឹងគឺត្រូវរាយការណ៍ទៅសេនាធិការហើយ។ ហើយឯកសារនេះគឺរាយការណ៍ទៅ រ៉ែន ហ្នឹងមែន។ ឯកសារបីទៀតនេះរាយការណ៍ទៅ រ៉ែន ព្រោះគាត់ជាសេនាធិការ។ ប៉ុន្តែតាមខ្ញុំដឹងគាត់តែមេបញ្ជាការកងពលធំនេះ ឯការដំឡើងទៅជាសេនាធិការជាមួយលោក សុន សេន ខ្ញុំអត់បានដឹងដែរហ្នឹង។ ប៉ុន្តែឯកសារដែលរាយការណ៍នេះ ភាគច្រើនជូនទៅសេនាធិការ ហើយសេនាធិការគឺ រ៉ែន នេះឯង។ ហើយបាន រ៉ែន នេះរាយការណ៍ជូនទៅខាងលើទៀត។ សូមបញ្ជាក់ប៉ុណ្ណឹង។

**សៈ** ឥឡូវខ្ញុំសួរតាមរបៀបផ្សេង។ តើតាមធម្មតាឲ្យតែឯកសារយោធា គេតែងតែចម្លងទៅឲ្យ រ៉ែន ហ្នឹងឬ? ដូចជាគេចម្លងជូនទៅ សុន សេន ឬក៏គេចម្លងជូនទៅ ណាត ហើយនិងដូចជាចម្លងជូនទៅ បង៨១ អ៊ីចឹងដែរ។ តើលោកដឹងទេ តាមធម្មតា រាល់ឯកសារទំនាក់ទំនងផ្នែកកងទ័ពទាំងអស់ហ្នឹង តាមតួនាទីរបស់លោកហ្នឹង គេតែងតែចម្លងជូន រ៉ែន ហ្នឹងអ៊ីចឹងដែរ ឬយ៉ាងម៉េច?

[០៩:៤៦:៣៥]

**ផ៖** ខ្ញុំសូមជម្រាបថា ឯកសារវាមានចែកច្រើនផ្នែកណាស់។ ទាក់ទងនឹងឯកសារសម្ងាត់គឺថា ផ្នែកខាងខ្ញុំខាងក្រោម អត់បានទេ។ បើឯកសារណែនាំជារួម មានលក្ខណៈធំទូលាយ អាហ្នឹងខាងក្រោមទទួលបាន ប៉ុន្តែបើឯកសារដូចថា ត្រូវឃាត់ខ្លួនចាប់អ្នកនេះអ្នកនោះ គឺសម្រាប់ខាងខ្ញុំអី អត់ដឹងទេ។ ហើយសម្រាប់ថ្នាក់លើ គេចែកជូនហើយថ្នាក់លើ។ លើ តារ៉ែន ទៅគេត្រូវចែកជូនដើម្បីឲ្យដឹងទាំងអស់គ្នា ប៉ុន្តែដល់ថ្នាក់ក្រោយគេអត់ចែកទេ ពីព្រោះទាក់ទងនឹងការចាប់ខ្លួន ចាប់អីនេះ គឺដូចខ្ញុំបានជម្រាបថាកម្ពុជាប្រជាធិបតេយ្យ គឺលាក់ការណ៍ជាសំខាន់ លាក់ការណ៍ជាសំខាន់ មិនមែនចេះឲ្យដឹងទាំងអស់ទេ។ សូមជម្រាបអ៊ីចឹង។

**សៈ** ខ្ញុំសូមសួរបញ្ជាក់ឲ្យច្បាស់បន្តិចទៀត រ៉ែន នេះ ដោយសារតែតួនាទីរបស់គាត់ជាមេបញ្ជាការកងទ័ព តាមធម្មតាគេតែងតែចម្លងជូនទៅ រ៉ែន ដូចគេចម្លងជូនទៅ សុន សេន ចម្លងជូនទៅ ណាត អ៊ីចឹងដែរ។ ទោះបីជាសារទូរលេខនោះមកពីកងពលណាក៏ដោយ ដែលគេបញ្ជូនទៅសេនាធិការ តាមធម្មតាលោកឃើញថា គេចម្លងជូន រ៉ែន ហ្នឹងរាល់លើកអ៊ីចឹងឬ?

01377091



**ឆ៖** ខ្ញុំសូមជម្រាបថា ការងារដែលចម្លងជូនឯកសារទៅ រ៉ែន នេះគឺជាការងាររបស់ រ៉ែន អ៊ីចឹង ខ្ញុំមិនអាចដឹងទេ ខ្ញុំមិនអាចយល់បានទេ ខ្ញុំសូមជម្រាបអ៊ីចឹង ពីព្រោះខ្ញុំបានបញ្ជាក់ខាងដើមហើយ ថានៅកម្ពុជាប្រជាធិបតេយ្យសម័យនោះគឺថា លាក់ការណ៍ដឹកនាំជាសំខាន់ ការងារខ្ញុំៗដឹង ការងារអ្នកនោះមេគឺមេដឹងហើយ។ ដល់អ៊ីចឹងគេៗបែងចែកច្បាស់ណាស់ ការងារណាត្រូវឲ្យខាងក្រោមដឹង ការងារណាថ្នាក់លើដឹង គឺមានការបែងចែកច្បាស់លាស់ណាស់ មិនមែនចេះតែចម្លងជូនទូទៅ ខ្ញុំសូមជម្រាប។

[០៩:៤៨:៥១]

**ស៖** សូមអរគុណចំពោះការបញ្ជាក់នេះ។--

**ប្រធានអង្គជំនុំ៖**

កុំអាល! កុំអាលទាន់!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំគិតថា យើងគួរតែចូលនិយាយលម្អិតទាក់ទងនឹងឯកសារ <E3/992>។ តើសាក្សីរូបនេះគាត់ស្គាល់អ្នកចុះហត្ថលេខាលើ<សារទូលេខ>ហ្នឹងទេ ដូចជាឈ្មោះ រ៉ុម ហ្នឹង? តើ<គាត់ដឹងថា>កងពល ១១៧ហ្នឹង ឈរជើងនៅឯណា? ខ្ញុំអត់ដឹងថា លោកមេធាវីកំពុងតែចង់បានអ្វីទេ អ៊ីចឹងសួរឲ្យច្បាស់លម្អិតអំពីទំនាក់ទំនងពិសេសនេះ។>

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំរីករាយនឹងសួរអ៊ីចឹង ក៏ប៉ុន្តែខ្លឹមសារនៃសារទូរលេខនេះមិនពាក់ព័ន្ធមកដល់សាក្សីរូបនេះទេ។ ឯកសារបីផ្សេងទៀតនេះ ដែលប្រមូលនេះគ្រាន់តែយកមកចង់សួរ<ដើម្បីរកឲ្យឃើញថា តើ>គេតែងតែចម្លងជូន រ៉ែន <ឬក៏អត់ពាក់ព័ន្ធនឹងបញ្ហាហ្នឹង តែគាត់មិនបានដឹងអំពីរឿងនេះទេ។ ដូច្នេះយើងអាចចូលទៅមើលឯកសារនេះបាន ប៉ុន្តែវាគឺជា>កងពល១១៧ <ដូច្នេះ ខ្ញុំមិនគិតថា វាពាក់ព័ន្ធនោះទេ។ គាត់មិនមិនបានដឹងអំពីរឿងនេះទេ។>។ សំណួររបស់ខ្ញុំ គឺវាពាក់ព័ន្ធទៅនឹងឯកសារ E3/1044 ទៅវិញទេ ដែល រ៉ែន ជាអ្នកចុះហត្ថលេខា។

[០៩:៥០:២៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ ឯកសារ E3/992 និយាយអំពីការវាយប្រហារទៅលើមូលដ្ឋាន<ខ្មាំង>វៀត

01377092



ណាម ដែលវាមានចម្ងាយ១គីឡូម៉ែត្រពីទឹកដីប្រទេសកម្ពុជា។ អ៊ីចឹងគេនិយាយអំពីទីកន្លែងមួយឈ្មោះឡុកនិញ។ អ៊ីចឹងជាការល្អ ដើម្បីដឹងថាតើ<កន្លែងនោះគឺជាអ្វី។ ហើយខ្ញុំគិតថា> យើងកំពុងនិយាយអំពី<ជម្លោះប្រដាប់អាវុធ>រវាងវៀតណាម និងកម្ពុជាហ្នឹង<។ ប្រហែលជា លោកគិតថា វាមិនពាក់ព័ន្ធ ប៉ុន្តែវាអាចនឹងពាក់ព័ន្ធសម្រាប់អង្គជំនុំជម្រះ>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំរីករាយនឹងនិយាយអំពីការវាយប្រយុទ្ធគ្នានៅផ្លូវជាតិលេខ១៣ ឬក៏ឡុកនិញនោះ។ <ប៉ុន្តែខ្ញុំមិនច្បាស់ថា តើវាស្ថិតនៅក្នុងខេត្តស្វាយរៀង ឬក៏អត់ទេ។>

**ស៖** ជាថ្មីម្តងទៀត សំណួរខ្ញុំហ្នឹងវាពាក់ព័ន្ធចម្បងតែឯកសារ E3/1044 ទេ។ លោកសាក្សីឥឡូវនេះលោកមានឯកសារ E3/1044 ចុះថ្ងៃទី៣០ តុលា ៧៧ គឺដែលចុះហត្ថលេខាដោយ រ៉ែន នេះ លោកមាន<ឯកសារ>នេះនៅនឹងមុខលោកឬនៅ? សំណួរខ្ញុំគឺដូចតទៅនេះ តាមរយៈសក្ខីកម្មរបស់លោក ខ្ញុំដឹងហើយថា ខ្លួនលោកផ្ទាល់មិនបានចូលរួមពាក់ព័ន្ធនៅក្នុងការដកហូតសមាសភាពមិនល្អចេញពីក្នុងជួរកងកម្លាំងប្រដាប់អាវុធនោះទេ។ ក៏ប៉ុន្តែ រ៉ែន នេះ នៅក្នុងឯកសារមួយនេះ គឺបានស្នើសុំដកហូតសមាសភាពមិនល្អ ហើយគាត់បានចែកសមាសភាពមិនល្អទៅជាបីប្រភេទ។ ប្រភេទទី១ គឺមានមនុស្សបីនាក់ ដែលត្រូវបញ្ជូនទៅឲ្យ បងឌុច។ ប្រភេទទី២ ទាក់ទងទៅមនុស្សប្រាំពីរនាក់ដែលត្រូវធ្វើទៅឲ្យ បងហ៊ុយ ហើយនិងប្រភេទទី៣ គឺស្នើដកមនុស្ស២៦នាក់ ឲ្យទៅធ្វើស្រែនៅព្រៃស។ អ៊ីចឹងសំណួរខ្ញុំសួរថា តើនៅពេលនោះ លោកមានបានដឹងទេថា សមាសភាពមិនល្អ ឬក៏ថាខ្មាំងហ្នឹង គេបែងចែកជាបីប្រភេទ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ លោកដឹងទេ?

**លោក អៀង ផាន៖**

**ផ៖** ខ្ញុំសូមជម្រាបថា ផ្អែកលើឯកសារនេះ គឺថាខ្ញុំអត់បានដឹងទេ ពីព្រោះទាក់ទងនឹងការដកហូតអីនេះ គឺគេមិនឲ្យដឹងទេ គេមិនឲ្យដឹង។ ហើយក្នុងឯកសារនេះ ដកជាក់ស្តែង ឬមិនដកយ៉ាងម៉េច ខ្ញុំក៏ក្តាប់មិនបានដែរ ប៉ុន្តែឯកសារមានអ៊ីចឹង។ ហើយមើលតាមឯកសារនេះ ដកតាំងពីជំនាន់ធ្វើស្រែនៅព្រៃស ៗគឺថាចាប់តាំងពីថ្ងៃរំដោះនោះ។ នៅព្រៃសហ្នឹង គឺចាប់ពីថ្ងៃរំដោះ ៧៦នោះ ចុង៧៥ ដើម៧៦ ដែលមានកម្លាំង មានកម្លាំងដែលហៅថា សមាសភាពគេដកទៅនៅធ្វើស្រែហ្នឹង គឺតាំងពីជំនាន់ហ្នឹង។

[០៩:៥៤:១២]

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែខ្ញុំសួរលោកថា តើលោកដឹងអំពីការចាត់ចំណាត់ប្រភេទខ្មាំងនេះ ឬក៏

01377093



ថាការចាត់ចំណាត់ប្រភេទសមាសភាពមិនល្អទៅជាបីប្រភេទនេះ ដូចជាប្រភេទទី១ គឺពាក្យ សុន សេន ថាជាក្រុមគ្រោះថ្នាក់, ក្រុមទី២ ជាក្រុមសេរី<ធម្មតា> និងក្រុមទី៣ ជាក្រុមដែលត្រូវបានខ្ចាំងអូសទាញញុះញង់ គឺឯកសារ E3/13 ERN ជាអង់គ្លេស <00940355, ខ្មែរ 0005-->

**អ្នកបកប្រែ៖**

លោកប្រធាន សូមម្ដងទៀត មិនអាចតាមទាន់ទេ។

**ប្រធានអង្គជំនុំ៖**

លេខឯកសារ និងលេខ ERN សាជាថ្មី ហើយនិយាយយឺតៗ អ្នកបកប្រែបកមិនទាន់ទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គឺ សុន សេន បានបញ្ជាទៅកងទ័ពរបស់គាត់គឺ E3/13, ERN អង់គ្លេស 00940355, ខ្មែរ 00052414, បារាំង 00344983។ លោកសាក្សី តាមសម្ដីរបស់ សុន សេន គាត់ថាគេចែកខ្មាំងជាបី គឺក្រុមគ្រោះថ្នាក់ ក្រុមសេរីវើ<ធម្មតា> ដែលត្រូវអប់រំជាបន្តបន្ទាប់ ហើយនិងប្រភេទទី៣ គឺប្រភេទដែលត្រូវបានខ្មាំងញុះញង់ ខ្មាំងអូសទាញ។ តើនៅសម័យកាលនោះ នៅពេលដែលលោកធ្វើជាមេបញ្ជាការហ្នឹងណា លោកដឹងថាគេចែកសមាសភាពនេះអ៊ីចឹងទេ?

[០៩:៥៦:០២]

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ <>សួរនេះ គឺសួរអំពីសារទូរលេខជាក់លាក់<មួយ>ដែល<និយាយអំពីការបញ្ជូន>បុគ្គល<មួយចំនួនទៅ ស-២១> ហើយអ្នកខ្លះ<>បញ្ជូនទៅព្រៃស។ ឥឡូវនេះយើងហាក់បីដូចជាសួរ<អំពីបុគ្គលផ្សេងនៃ>សមាសភាពមិនល្អបីប្រភេទនេះ<>ទៅវិញ<។ រឿងមួយដែលខ្ញុំអាចមើលឃើញជារួមនោះ គឺថាពួកគេមានបីចំណុច>។ អ៊ីចឹងខ្ញុំសូមជំទាស់ទៅនឹងការសួរសំណួរនេះ មិនមានភស្តុតាងថ្មីបញ្ជាក់ថាសារទូរលេខនេះ វាអាចពាក់ព័ន្ធទៅនឹងសុន្ទរកថាណាមួយឬក៏អត់នេះទេ ប្រហែលជាសំណួរនេះត្រូវតែរៀបចំឡើងវិញ<ក្នុងការសួរឲ្យសាមញ្ញពាក់ព័ន្ធនឹងសុន្ទរកថានេះ ប៉ុន្តែគឺមិនត្រូវ>ឲ្យមានការ<ភ័ន្តច្រឡំថាជាឯកសារពីរនោះទេ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនយល់ចំពោះការជំទាស់នេះ<ទេ។ ជាច្រើនដងមកហើយ គឺ>យើងតែងតែយកឯកសារដែលជាសុន្ទរកថារបស់ សុន សេន នោះ<មកសួរដេញដោល។> ឌុច ក៏បាន ត្រូវបានយកមកសួរពាក់

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ព័ន្ធទៅនឹងឯកសារនេះដែរ <ហើយអ្នកផ្សេងទៀតជាច្រើន ក៏ត្រូវបានសួរដេញដោលអំពីបញ្ហានេះដែរ> ។ ឥឡូវនេះខ្ញុំ<អានឯកសារមួយដែល>មេបញ្ជាការ<របស់គាត់ ក៏បាននិយាយផងដែរអំពីប្រភេទទាំងបីនេះ។ ហើយសំណួររបស់ខ្ញុំ គឺសួរ>ពាក់ព័ន្ធតែទៅនឹងថាតើនៅពេលហ្នឹង គាត់ដឹងថាវាមានអត្ថិភាពគេចែកចំណាត់ប្រភេទខ្មាំងជាបីអ៊ីចឹងដែរឬទេ ដែលតាមធម្មតា រ៉ែន ហើយនិង សុន សេន <និយាយសំដៅទៅលើនោះ>។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

ខ្ញុំសូមបញ្ជាក់។ សារទូរលេខដែល រ៉ែន បានបញ្ជូនចេញទៅនេះ គឺមិនបានយោងទៅប្រភេទដែល សុន សេន បានលើកឡើងយកមកនិយាយនោះទេ។ អ៊ីចឹងឯង គឺគាត់និយាយ<ធម្មតាអំពី>ប្រភេទបី<។ គាត់>មិននិយាយអំពី<ប្រភេទទាំងនោះ ក្នុងបរិបទដូច>នៅក្នុងឯកសាររបស់ សុន សេន <នោះទេ>។

[០៩:៥៧:៤៣]

**លោក វ៉ិចទ័រ កូប៉េ៖**

តើលោកដឹងថា ប្រភេទទាំងបីនេះមិនដូចនឹងប្រភេទ សុន សេន លើកឡើងទេឬ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ខ្ញុំគិតថា បញ្ហាដែលយើងកំពុងតែមាននេះ គឺវាមិនចាំបាច់ឲ្យមានការពិភាក្សាបែបនេះទេ។ ខ្ញុំចង់និយាយថា លោកកំពុងតែទាញសេចក្តីសន្និដ្ឋានផ្សេងហើយ។> តើលោកម៉េចក៏មិនលើកសួរសំណួរទូទៅតែម្តងទៅ? ថាតើលោកដឹងគេចែក<ប្រភេទអ៊ីចឹងដែរ ឬទេ>? ហើយសឹមលោកយកឯកសារជាក់លាក់ណាមួយមកសួរមក <ដោយនិយាយថា តើនេះគឺជាប្រភេទដែលគេបែងចែកហ្នឹងមែនទេ? យើងនឹងបើកចិត្តឲ្យទូលាយ បើសិនវាជារឿងដូចគ្នានោះ>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី អ៊ីចឹងលោកដឹងទេថា គេចែកខ្មាំងជាបីប្រភេទអ៊ីចឹង? គឺថាគេតែងតែរែកមុខខ្មាំងហើយ គេចែកខ្មាំងទៅជាបីប្រភេទយ៉ាងដូច្នេះ តើលោកដឹងជារួមថាមានអ៊ីចឹងមែនទេ?

**លោក អៀង ផាន៖**

**ឆ៖** ខ្ញុំសូមជម្រាបថា ក្នុងឋានៈខ្ញុំជាមេបញ្ជាការដែរ ការបែងចែកបីប្រភេទ ដូចមាននៅក្នុងឯកសារនេះ គឺថាខ្ញុំមិនធ្លាប់ដឹងទេ ខ្ញុំមិនធ្លាប់ដឹងទេ។ ឯថ្នាក់លើយកទៅបែងចែកវិភាគគ្នាគាត់យ៉ាងណា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ខ្ញុំអត់យល់ទេ។ ប៉ុន្តែសម្រាប់ខ្ញុំធ្វើមេដឹកនាំជាបន្តបន្ទាប់មក គឺមិនដែលបែងចែកកម្លាំងដែលៗៗមិនល្អ ហើយបែងចែកជាពីរ ជាបីថ្នាក់អីចេះគឺអត់ទេ។ ហើយតាមឯកសារនេះមានតែ វ៉ែន មានតែ សុន សេន ទេ ឯថ្នាក់ក្រោមអត់បានដឹងរឿងបែងចែកអីចឹងទេ ខ្ញុំសូមជម្រាប។

[០៩:៥៩:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ត្រឹមត្រូវហើយ។ សមហេតុសមផល ខ្ញុំហៀបនឹងបញ្ចប់ទៅហើយ។ ខ្ញុំ<រីករាយនឹង>សួរឯកសារមួយទៀតគឺ E3/992 <ប៉ុន្តែ>ខ្ញុំមិនមានផែនការចង់សួរលោកទេ ក៏ប៉ុន្តែបើសិនណាជា<អង្គជំនុំជម្រះ>ត្រូវឲ្យខ្ញុំសួរ គឺមិនថ្វីទេ ខ្ញុំ<ធ្វើបាន>។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំបានប្រាប់សហភាតារបស់ខ្ញុំថា ប្រសិនជាអង្គជំនុំជម្រះមានសំណួរជាក់លាក់ទាក់<ទង>ក្នុងឯកសារហ្នឹង គឺថា<អាច>ធ្វើមុនខ្ញុំ ឬក៏ក្រោយខ្ញុំ។ ក៏ប៉ុន្តែឯកសារ 992 នេះដែលនិយាយអំពីតំបន់ក្រចេះទេ។ គឺឯកសារ E3/992នេះ ខ្ញុំមិន<ច្បាស់>ថាគាត់នឹងអាចឆ្លើយនឹងសំណួរទាក់ទងឯកសារនេះនោះទេ។ ខ្ញុំសុំស្នើថា ឥឡូវខ្ញុំអាចចាប់ផ្ដើមសួរសាក្សីរូបនេះបាន ហើយក្រោយមកបើអង្គជំនុំជម្រះមានសំណួរអ្វីសួរ ដើម្បីបញ្ជាក់បន្ថែមទៅគាត់នោះ គឺអាចសួរក្រោយខ្ញុំ។ អីចឹងឃើញថា លោកប្រធានគាត់ងក់ក្បាលអនុញ្ញាតហើយ។ ខ្ញុំអាចបន្តឥឡូវ ឬក៏យ៉ាងម៉េច?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថា ដោយសារយើងនិយាយ យើងបាននិយាយអំពីឯកសារនេះហើយ ខ្ញុំគិតថាប្រហែលជាល្អជាង ខ្ញុំសួរបន្ត ហើយលោកស្រីអាចសួរពេលក្រោយបាន។

[១០:០១:១១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សី យើងមានឯកសារទូរលេខមួយដែលគឺឯកសារ E3/992។ លោកមេធាវីអាចជួយបង្ហាញឯកសារហ្នឹងទៅគាត់បានដែរឬទេ គឺឯកសារដែលយើងបានសួរសំណួរពាក់ព័ន្ធអម្បាញ់មិញនេះ? អ្នកចុះហត្ថលេខានោះគឺឈ្មោះ រ៉ុម។ តើលោកស្គាល់ឈ្មោះ រ៉ុម នេះទេ?

**លោក អៀង ផាន៖**

**ឆ៖** ខ្ញុំសុំបញ្ជាក់ថា ឈ្មោះ រ៉ុម នេះនៅផ្នែកខាងជើង ខ្ញុំអត់បានស្គាល់ទេ កងពល១១៧ ផ្នែកខាងជើង។

**ស៖** អ៊ីចឹងកងពល១១៧ហ្នឹង ដែលលោកថាឈរជើងនៅភូមិភាគឧត្តរ។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចទេ ឲ្យច្បាស់អំពីទីតាំងឈរជើងនេះបានដែរឬទេ? លោកដឹងទេ ថាទីតាំងជាក់លាក់នៅឯណាដែរ កន្លែងឈរជើងហ្នឹង?

**ឆ៖** ខ្ញុំសុំបញ្ជាក់ថា កងពល១១៧នេះ ខ្ញុំគ្រាន់ដឹង គ្រាន់តែដឹងថា នៅទិសខាងអន្លង់វែង ឯទីតាំងជាក់លាក់នោះ ខ្ញុំមិនច្បាស់ទេ ពីព្រោះខ្ញុំនៅខាងសំឡូត ហើយដល់អន្លង់វែង វាឆ្ងាយពីគ្នាណាស់។

**ប្រធានអង្គជំនុំ៖**

ទំនងអាចៗស្តាប់គ្នាមិនបានទេដឹង ព្រោះអានេះគឹងកសារឆ្នាំ ថ្ងៃទី០២ ខែ៣ ឆ្នាំ១៩៧៨។ អ៊ីចឹងរឿងហេតុនេះគឺព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងអំឡុងឆ្នាំ៧៨ តើលោកស្គាល់ រ៉ុម ទេ? ហើយ រ៉ុម ហ្នឹងគឺអង្គភាពកងពល១១៧ហ្នឹង ឈរជើងនៅឯណា? មិនមែនជាក់ស្តែងថា បច្ចុប្បន្ន ឬក៏អីគាត់នៅទីណានោះទេ ព្រោះបើនិយាយពីសំឡូត លោកមិនអាចថា និយាយពីសំឡូតទេ ជំនាន់៧៧ និង៧៨ លោកមកនៅតាកែវ ហើយទៅភូមិភាគបូព៌ាអ៊ីចឹង អ៊ីចឹងឲ្យស្គាល់ពីព្រឹត្តិការណ៍ ដែលសួរនេះគឺគោលបំណងសួរគឺកាលពេលវេលានៃការចេញឯកសារ គឺថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៧៨។

[១០:០៣:៤៦]

**លោក អៀង ផាន៖**

**ឆ៖** ខ្ញុំសុំបញ្ជាក់ថា រ៉ុម នេះខ្ញុំស្គាល់ ប៉ុន្តែស្គាល់ម្តងម្កាលទេ។ ហើយកងពល១១៧នេះ គឺខាងកម្ពុជាប្រជាធិបតេយ្យជំនាន់ឆ្នាំ៧៨ហ្នឹង គាត់ឈរជើងនៅខាងភូមិភាគព្រៃសាន។ អាហ្នឹងក៏ទិសអន្លង់វែងទទួលដែរ ខាងព្រៃសានហ្នឹង។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** តើលោកមានឮនិយាយអំពីការវាយប្រហារនៅឡុកនិញដែរឬទេ? តើលោកដឹងថាឡុកនិញនេះមានទីតាំងភូមិសាស្ត្រនៅកន្លែងណាដែរឬទេ?

**ឆ៖** ខ្ញុំសុំជម្រាបថា ខ្ញុំមិនស្គាល់ថាឡុកនិញហ្នឹងនៅទីណាផងហ្នឹង អ៊ីចឹងការប្រយុទ្ធម៉េចបានដឹង។ សូមអរគុណ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំសូមអរគុណដែលបានឆ្លើយបញ្ជាក់នឹងសំណួររបស់ខ្ញុំ។ សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

ផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក ខៀវ សំផន។

[១០:០៥:១៥]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក អៀង ផាន។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ យើងបានជួបគ្នាមួយរយៈមកហើយនៅក្នុងសំណុំរឿង០០២/០១ ខ្ញុំសូមចោទសំណួរបន្ថែមមួយចំនួន ដើម្បីចង់បានព័ត៌មានជាក់លាក់អំពីបទពិសោធន៍របស់លោកនៅក្នុងជម្លោះប្រដាប់អាវុធ កាលណោះលោកនៅតាកែវ ហើយបន្ទាប់មកទៀតលោកទៅស្វាយរៀង។ ហើយខ្ញុំនឹងមានសំណួរបន្ថែមទៀតទៅលើអ្វីដែលលោកបានឆ្លើយទៅអង្គជំនុំជម្រះអម្បាញ់មិញ។ បើតាមចម្លើយរបស់លោក លោកបាននិយាយថា ការចាប់ផ្តើមមានទាស់គ្នា រវាងកម្ពុជាប្រជាធិបតេយ្យជាមួយនឹងវៀតណាមហ្នឹងគឺនៅឆ្នាំ៧៦ និង៧៧។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកមានចាំអំពីការវាយប្រហារលើកទី១ដែលបានកើតឡើង ហើយកាលណោះលោកនៅតាកែវ លោកចាំទេ ការប៉ះទង្គិចគ្នាលើកទី១ ហ្នឹងនៅឆ្នាំណាដែរ?

[១០:០៦:២៨]

**លោក អៀង ផាន៖**

**ឆ៖** ខ្ញុំបានបញ្ជាក់ថា នៅដើមឆ្នាំ៧៧ មានការប៉ះទង្គិចគ្នានៅតាកែវ។ ខ្ញុំមិនចាំថ្ងៃខែច្បាស់ទេ គឺថា ការប៉ះទង្គិចគ្នាដំបូងហ្នឹង គឺនៅតាមបណ្តោយព្រែកជីកវិញតេ។ បើនិយាយចំណុចងាយយល់ គឺថា នៅមុខភ្នំដិន នៅពីមុខភ្នំដិន គឺមានការប៉ះទង្គិចគ្នា។ ហើយការប៉ះទង្គិចដើមឆ្នាំ៧៧ ហ្នឹងមាន -- មិនមានសភាពអីធ្ងន់ធ្ងរទេ ណ៎ាតិចតួចៗ។ នេះៗសូមជម្រាបប៉ុណ្ណឹង។

**ស៖** កាលពីម្សិលមិញលោកបានឆ្លើយថា នៅពេលដែលលោកត្រូវបានគេចាត់តាំងឲ្យទៅខេត្តតាកែវ ដំបូងគឺលោកនៅក្នុងក្រុងតាកែវ ទីរួមខេត្តតាកែវ ហើយបន្ទាប់មកទៀត គេឲ្យលោកទៅតាម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ព្រំដែន។ អ៊ីចឹងសំណួរខ្ញុំសួរថា នៅពេលដែលលោកដឹងអំពីការប៉ះទង្គិចលើកទី១នោះ តើពេលនោះលោកនៅទីរួមខេត្តតាកែវទេ ឬក៏ពេលនោះៗលោកគេត្រូវបានគេបញ្ជូនទៅព្រំដែនបាត់ទៅហើយ?

**ធ៖** ខ្ញុំសូមបញ្ជាក់ថា ពេលប៉ះទង្គិចគ្នាជាមួយវៀតណាមនោះ គឺខ្ញុំបានទៅព្រំដែនហើយ អត់នៅតាកែវទេ។ ប៉ុន្តែការប៉ះទង្គិចនេះ មិនចំមុខអង្គភាពដែលយើងខ្ញុំទទួលខុសត្រូវទេ។ គ្រាន់តែដឹងនៅជាប់គ្នាហ្នឹងគឺដឹង ព្រោះភូមិសាស្ត្រវាតែមួយ។

[១០:០៨:៣៣]

**ស៖** ខ្ញុំចង់ចោទសំណួរនេះទៅលោកនោះគឺថា បើថា បើខ្ញុំយល់មិនច្រឡំទេកាលនោះគឺលោកនៅក្នុងកងវរសេនាធំ១១២ -- ១២ (សូមទោស)។ ហើយលោកដឹងថា មានកងវរសេនាធំផ្សេងទៀតទេនៅតាកែវហ្នឹង? ហើយទីតាំងឈរជើងរបស់ពួកក្រុមគេហ្នឹងនៅកន្លែងណាដែរ?

**ធ៖** ខ្ញុំបានជម្រាបហើយថា ក្រោយពីខ្ញុំចេញពីកងពិសេស ពី២០៣ទៅ ខ្ញុំទៅកាន់វរសេនាធំលេខ១២ ជាមេបញ្ជាការរង មិនទាន់ប្រធានទេ ជាមេបញ្ជាការរង។ ហើយទីតាំងរបស់កងពល -- វរសេនាធំលេខ១២ហ្នឹង គឺនៅចំមុខខេត្តចូវដុក – ច្រមុះជ្រូក ហ្នឹងវរសេនាធំដែលខ្ញុំកាន់កាប់ហ្នឹងគឺនៅទល់មុខខេត្តចូវដុកតែម្តង – មាត់ជ្រូកហ្នឹងតែម្តង។ ហើយវរសេនាធំផ្សេងទៀតគឺមានលេខ១៣, មានលេខ១៤ គឺបន្តមកៗទិសភ្នំដិនៗ ហើយជាប់ទៅខាងព្រំដែនកំពត។ បើនិយាយពីវរសេនាធំ១២ គឺវានៅក្នុងកងពលលេខ២ ពីមុនដែលមិនទាន់កែប្រែអង្គភាពនោះ គឺនៅក្នុងកងពលលេខ២។ ហើយដែលប៉ះប្រយុទ្ធគ្នាហ្នឹង គឺវរសេនាធំលេខ១១។ វរសេនាធំលេខ១១ ព្រោះកងពលលេខ១២ -- កងពលលេខ២ ហ្នឹងវាមាន១១, ១២, ១៣, ១៤ហ្នឹង ហើយ១១ហ្នឹង គឺនៅចំព្រែក គេហៅ "ព្រែកបាក់ដៃ" ជាប់នឹងមកពីទន្លេបាសាក់មក គឺកងពលហ្នឹងពង្រាយតាមព្រំដែនអ៊ីចឹង។ ហើយដែលប៉ះដំបូងបំផុត ដើមឆ្នាំ៧៧ ហ្នឹង គឺវរសេនាធំលេខ១១ បានន័យថា ពីខាងឆ្វេងដៃរបស់ខ្ញុំ ពីឆ្វេងអង្គភាពយើងខ្ញុំ។

[១០:១០:៥៤]

**ស៖** ដោយហេតុតែលោកនិយាយថា គឺកងវរសេនាធំ១១ ដែលចូលពាក់ព័ន្ធទៅនឹងការប៉ះទង្គិចលើកទី១ហ្នឹង តើលោកដឹងពីការប៉ះទង្គិចហ្នឹងដោយវិធីណា? តើមានកិច្ចប្រជុំ ឬក៏មានការផ្តល់ព័ត៌មានរវាងកងវរសេនាធំទាំងអស់ហ្នឹង អំពីស្ថានភាពនៅសមរភូមិ ឬក៏យ៉ាងម៉េច?

**ធ៖** ខ្ញុំសូមនិយាយហេតុផលមួយចំនួនដែលទាក់ទងនឹងការប៉ះទង្គិចគ្នា ជាមួយវៀតណាមនៅតាមព្រំដែន។ ជាដំបូងឡើយនៅក្នុងវរសេនាធំ១១ ដែលប៉ះទង្គិចគ្នានោះ មិនមានរឿងអីធំដុំទេ។ ទាក់ទង

នឹងបញ្ហាព្រំដែនៗ ធម្មតាវៀតណាមភាគច្រើន គឺគាត់ជីកបៀ។ យើងនិយាយតាមភាសាធម្មតាជីកបៀយកត្រី។ ហើយដល់ជីកបៀហ្នឹង គឺចូលក្នុងទឹកដីកម្ពុជា។ អ៊ីចឹងកម្ពុជាទៅឃាត់ឈប់ឲ្យជីក ព្រោះចូលក្នុងទឹកដីកម្ពុជា ឃាត់ម្ដងពីរដង គាត់អត់ស្ដាប់ទេ។ ដល់យើងទៅឃាត់ក្រោយហ្នឹង គាត់ដាក់គ្រាប់បែកនៅនឹងបង្គោលៗព្រំដែនដល់យើងដកបង្គោលហ្នឹង កិនឲ្យទៅដីគាត់វិញផ្ទុះគ្រាប់បែកស្លាប់។ ផ្ទុះគ្រាប់បែកស្លាប់ យើងបានទាក់ទងចរចា យ៉ាងណាក៏ដោយចំពោះមុខ ហើយរាយការណ៍មកលើទៀត ក៏ហេតុការណ៍នេះនៅដដែលនៅដដែល។ អ៊ីចឹងបង្កឲ្យមានការផ្ទុះអាវុធ ផ្ទុះអាវុធ។ ដើមឡើយគឺគាត់ដាក់អ៊ីចឹងគាត់ដាក់គ្រាប់បែកយើងមុន។ អាហ្នឹងខ្ញុំនិយាយជាក់ស្ដែងនៅលើទឹកដីកម្ពុជាតែម្ដង។ អ៊ីចឹងបង្កើតមានរឿងហៅថា អរិភាពជាមួយគ្នារហូត។ អ៊ីចឹងហើយបង្កើតមានការប្រយុទ្ធគ្នា ហើយការប្រយុទ្ធមិនមានអីធំដុំទេ បាញ់គ្នាមួយព្រូអ៊ីចឹងទៅ ស្ងាត់បាត់១អាទិត្យអ៊ីចឹង បានមួយព្រូទៀតទៅ។ អានេះសូមជម្រាបអ៊ីចឹង។ ហេតុផលដំបូង គឺអ៊ីចឹង។

[១០:១៣:១៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សី មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្ដល់វេទិកាជូនទៅមេធាវី

ការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សី មុនពេលសម្រាកនេះលោកបានពន្យល់អំពីមូលហេតុនៃការប៉ះទង្គិចគ្នាលើកទី១ ជាមួយនឹងកងវរសេនាធំ<លេខ១១>។ អ៊ីចឹងខ្ញុំសួរលោកថាតើហេតុអីបានដឹងអំពីបញ្ហាហ្នឹង ព្រោះថាលោកមិនមែននៅក្នុងកងវរសេនាធំ១១នោះទេ? តើមានការជូនដំណឹង ឬក៏មានកិច្ចប្រជុំអីដែលគេលើកឡើងអំពីការប៉ះទង្គិចគ្នាជាមួយកងវរសេនាធំលេខ១១ហ្នឹង?

**លោក អៀង ផាន៖**

**ផ៖** ខ្ញុំសូមជម្រាបថា កងពលលេខ២ហ្នឹងមានបួនវរសេនាធំ លេខ១១, ១២, ១៣, ១៤។ អ៊ីចឹងនៅក្នុងកងពលបើមានព្រឹត្តិការណ៍អីគឺកងពលកោះអញ្ជើញមកប្រជុំ ហើយប្រជុំទាក់ទងនឹងការប៉ះទង្គិចគ្នាជាមួយវៀតណាម គឺវរសេនាធំលេខ១១ហ្នឹង គាត់រាយកាណ៍ ៗជូនអង្គប្រជុំ បានយើងខ្ញុំភ្លាប់បាន។

**ស៖** សូមអរគុណ។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើកិច្ចប្រជុំបែបហ្នឹង ឬក៏ការផ្តល់ព័ត៌មានហ្នឹងញឹកញាប់ប៉ុនណាដែរ? ឬក៏ការប្រជុំហ្នឹង ឬក៏ការជួបគ្នាផ្តល់ព័ត៌មានហ្នឹងធ្វើជារៀងរាល់ថ្ងៃ ឬក៏ជួបប្រជុំផ្តល់ព័ត៌មានឲ្យគ្នាទាល់តែពេលមានបញ្ហាទេបានធ្វើ?

[១០:៣៤:៥៨]

**ផ៖** ខ្ញុំសូមជម្រាបផងដែរថា គឺថាខ្សែរយៈរបស់កងទ័ពក្នុងកងពលតែមួយ គឺថា ថ្នាក់កងពលសុទ្ធតែកំណត់ពេលវេលាប្រជុំ ៣ថ្ងៃ ឬ១អាទិត្យ ត្រូវតែជុំគ្នាម្តង អញ្ជើញវរសេនាធំទាំងអស់មកជួបជុំ។ ហើយបើមានករណីពិសេស ដូចជាមានការផ្ទុះអាវុធអីហ្នឹង គឺប្រជុំហ្នឹង គឺថាករណីពិសេសហើយ អត់បាច់ចាំដល់ពេលកំណត់ទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមចូលនិយាយពីចំណុចមួយដែលលោកនិយាយអំពីការនៅតាកែវ គឺកិច្ចប្រជុំនៅចុងឆ្នាំ១៩៧៧ ដែលមានវត្តមាន តាម៉ុក។ អ៊ីចឹងសំណួរទី១ ទាក់ទងទៅនឹង តាម៉ុកនេះ ខ្ញុំចង់ដឹងថាតើលោកជួប តាម៉ុក នេះជាលើកទី១ នៅពេលណាដែរ?

**ផ៖** ខ្ញុំសូមជម្រាបផងដែរថា ចំពោះ តាម៉ុក ហ្នឹងគឺថាសម្រាប់ខ្ញុំជួបញឹកញាប់ណាស់ ពីព្រោះគាត់ជាមេភូមិភាគ ហើយជំនាន់ហ្នឹង គឺខ្ញុំជាកងពិសេសរបស់កងពល អ៊ីចឹងការទំនាក់ទំនងរវាងកងពិសេស និងយោធភូមិភាគ ហើយនិងកងពលនេះ គឺមានការទំនាក់ទំនងគ្នាជាប់។ ហើយការប្រជុំដែលខ្ញុំជម្រាបថា ការប្រជុំនេះគឺប្រជុំលើកទី១មែន ប៉ុន្តែការជួបនិយាយគ្នាតិចតួចៗហ្នឹង គឺជួបញឹក។ ឯប្រជុំ

ជាគោលការណ៍ដែលរៀបកម្លាំងទៅស្វាយរៀងនេះ គឺនៅក្នុងចុង៧៧ហ្នឹងហើយ ចុង៧៧។ រៀបចំហើយស្រេចបាច់ បានពាក់កណ្តាល៧៨ បានខ្ញុំទៅស្វាយរៀង។

**ស៖** អ៊ីចឹងសូមអរគុណ។ លោកឆ្លើយហ្នឹង ឆ្លើយសំណួរដែលខ្ញុំរៀបនឹងសួរហើយ។ អ៊ីចឹង តាម៉ុក ហ្នឹងគាត់ចូលរួមក្នុងការរៀបចំកងកម្លាំងនៅស្វាយរៀងដែរ មិនមែនត្រឹមតែតាកែវទេ។ តើអ៊ីចឹងមែនទេ?

[១០:៣៧:២៧]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ការជ្រើសរើសកម្លាំងទ័ពពីតាកែវ អ៊ីចឹងទ័ពនៅតាកែវ គឺក្រោមការគ្រប់គ្រងរបស់ តាម៉ុក។ អ៊ីចឹង តាម៉ុក ត្រូវតែប្រជុំ ដើម្បីរៀបចំកម្លាំង រៀបចំកម្លាំងបញ្ជូនទៅស្វាយរៀង។

**ស៖** ឥឡូវខ្ញុំនឹងនិយាយអំពីស្វាយរៀងនេះ នៅពេលបន្តិចទៀតនេះ។ ឥឡូវខ្ញុំសូមនិយាយកម្រិតត្រឹមតែតាកែវសិនបានហើយ។ លោកនិយាយថា លោកបានជួប តាម៉ុក ហ្នឹងជាញឹកញាប់ ក៏ប៉ុន្តែគឺខ្ញុំសួរលោកថា លោកជួបលើកទី១ នៅឆ្នាំណា? ហើយចន្លោះឆ្នាំ៧៥ ដល់៧៩ ឬក៏លោកជួបគាត់ហ្នឹងមុនឆ្នាំ៧៥ទៀត ជាលើកទី១ហ្នឹង?

**ឆ៖** ខ្ញុំជួប តាម៉ុក តាំងពីមុនឆ្នាំ៧៥ទៀត។ ពេលដែលវាយចូលទៅក្រុងភ្នំពេញ ខ្ញុំជួបគាត់លើកទី១ហើយហ្នឹង ពីព្រោះគាត់អ្នករៀបចំផែនការជាមួយ សំ ប៊ិត រៀបចំផែនការវាយចូលទីក្រុងភ្នំពេញ។ អ៊ីចឹងខ្ញុំជួបគាត់មុន៧៥ ជាលើកទី១។

**ស៖** សូមអរគុណ។ ទាក់ទងទៅនឹងបុគ្គលិកលក្ខណៈរបស់ តាម៉ុក នេះ ខ្ញុំសង្ខេបឡើងវិញគឺថាលោកនិយាយ<កាលពីម្សិលមិញ>ថា តាម៉ុក គាត់មិនចេះនិយាយប្រឡិមប្រឡៃទេ និយាយច្បាស់ៗ។ តើបើតាមបទពិសោធន៍លោកដែលធ្លាប់បានជួបគាត់ហ្នឹង តើមនុស្សគាត់អ៊ីចឹង ឬយ៉ាងម៉េច និយាយដាច់ណាត់តែម្តង ម៉ាត់ៗ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ខ្ញុំធ្លាប់ឃើញគាត់ ហើយស្គាល់គាត់ហ្នឹង គឺថាគាត់ជាមនុស្សនិយាយដាច់ណាត់ៗៗអ៊ីចឹងហ្នឹង។ យើងនិយាយថា ភាសាធម្មតាថា និយាយៗភាសាខ្មែរ វាលះ ហើយដាច់ម៉ាត់ៗតែម្តង។ អត់ចេះ ពាក្យអប អែបអីទៀតទេ។

[១០:៤០:១២]

**ស៖** លោកបាននិយាយជាមួយលោកមេធាវី កូប៉េ អំពី ឈូក រីន ហើយ ឈូក រីន មកផ្តល់សក្ខីកម្មនៅទីនេះ ដូចដែលលោកដឹងស្រាប់ហើយ។ ហើយ ឈូក រីន និយាយដូចតទៅនេះអំពី តាម៉ុក គឺ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

សវនាការថ្ងៃទី២៣ មេសា ឆ្នាំ២០១៣ ឯកសារ E1/182.1។ ផ្នែកដែលខ្ញុំចាប់អារម្មណ៍ហ្នឹង គឺមុនម៉ោង១១:២១:១៦វិនាទីបន្តិច។ ឈូក រីន និយាយដូចតទៅនេះ៖ "លោកចង់ឲ្យខ្ញុំពិពណ៌នា តាម៉ុក ដោយសារគាត់ជាមេផ្ទាល់របស់ខ្ញុំ ៗដឹងថា គាត់ខ្លាំងកម្រិតណាហើយ។ គាត់ប្រើ<សំនួនវោហារសាស្ត្រ>ដូចតទៅនេះ គាត់និយាយថា នៅលើក្បាល ម៉ុក មានតែម្លូក។" តែប៉ុណ្ណឹងទេ សុំបញ្ចប់ការដកស្រង់។ តើលោកនៅចាំទេ តាមបទពិសោធន៍លោក លោកមានចាំពាក្យហ្នឹងទេ ថា "នៅពីលើក្បាល ម៉ុក មានតែម្លូក" ទេ ឬក៏លោកធ្លាប់ឮអ្នកណាផ្សេងទៀតនិយាយទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ពាក្យនេះគឺថា យើងនិយាយថានិយាយលេងក្រៅ មិនមែននិយាយចំពោះមុខគាត់ទេ។ ហើយគាត់ក៏មិនដែលប្រើពាក្យអ៊ីចឹងដែរ ច្រើនអ្នកក្រៅ។ គាត់និយាយស្អី មានហៅថា មានដូចជាមានអំណាចអ៊ីចឹង ដល់អ៊ីចឹងគេប្រើជាមួយគាត់ថា "នៅលើក្បាល ម៉ុក គឺមានម្លូក នៅលើម្លូក មានតែមេឃ"។ គេច្រើនតែប្រើពាក្យជាមួយគាត់អ៊ីចឹង។

**ស៖** តើលោកដឹងដែរឬទេ ថាតើសំនួនវោហារហ្នឹងមានប្រភពមកពីណា? តើគេប្រើសំនួនវោហារសាស្ត្រហ្នឹងដើម្បីពិពណ៌នាពី តាម៉ុក ហ្នឹង ដោយសារចង់និយាយអំពីអត្តចរិតរបស់គាត់ ឬក៏<អំពីការសម្រេច>របស់គាត់ ឬក៏យ៉ាងម៉េច?

[១០:៤២:៣៦]

**ឆ៖** តាមខ្ញុំយល់គឺថា គេលើកវោហារសាស្ត្រនេះ គឺគេចង់និយាយពីអំណាចរបស់គាត់ គេចង់និយាយពីអំណាចរបស់គាត់។ គាត់មានអំណាចអ៊ីចឹង ប្រៀបបានថា "លើក្បាល ម៉ុក មានម្លូក នៅលើម្លូកមានមេឃ" អ៊ីចឹងមាននរណាត្រួត ម៉ុក ទៀតទេ។ គេចង់និយាយអ៊ីចឹង។

**ស៖** ឥឡូវខ្ញុំបន្តដកស្រង់ ឈូក រីន នៅ<ក្នុងសវនាការ ថ្ងៃទី២៣ ខែមេសា> ឆ្នាំ២០១៣ គាត់និយាយបន្តទៅទៀតដូចតទៅនេះ៖ "កាលដែលខ្ញុំចេញពីនិរតី ដែល តាម៉ុក គាត់បានចេញបញ្ជាហ្នឹង <នៅពេល>ខ្ញុំបានទៅដល់<បូព៌ា> ហើយខ្ញុំសង្កេតឃើញថា តាម៉ុក បញ្ជាទៅមេបញ្ជាការទាំងអស់។ អ៊ីចឹងខ្ញុំទាញការសន្និដ្ឋានថា គាត់ហ្នឹងមានអំណាចខ្លាំង។ ហើយយើងឃើញគាត់ចេញបញ្ជាទៅទាហានគ្រប់ទិសទី។ គាត់មានឥទ្ធិពលទៅលើយោធាខ្មែរក្រហម ទាំងនៅខាងនិរតី ទាំងនៅខាង<បូព៌ា>។ កាលខ្ញុំនៅបស្ចិម ខ្ញុំឃើញគាត់ដែរ ហើយទៅបូព៌ាក៏ឃើញគាត់ដែរ។ គាត់ចេញបញ្ជាគាត់នៅទីនោះ។ អ៊ីចឹងខ្ញុំឃើញថាគាត់ហ្នឹងមានអំណាចគ្រប់កន្លែង។"

តាមរយៈចម្លើយរបស់លោកម្សិលមិញ ដែលលោកឆ្លើយទៅ កូប៉េ ហ្នឹងគឺថា <អាចថា>

លោកមិនបានទៅស្វាយរៀងហ្នឹង ក្នុងពេលជាមួយ ឈូក រីន នោះទេ។ ក៏ប៉ុន្តែខ្ញុំចង់ដឹងថា តើនៅពេលដែលលោកទៅ ស្វាយរៀងហ្នឹង លោកមានឃើញ តាម៉ុក ដែរឬទេ? ហើយមានឃើញ តាម៉ុក ហ្នឹងចេញបញ្ជាទៅមេបញ្ជាការយោធាដែរឬទេ នៅ<ក្នុងអំឡុងពេលដែលលោកនៅស្វាយរៀង>?

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលដែលខ្ញុំទៅស្វាយរៀងហ្នឹងគឺ តាម៉ុក គាត់នៅតាកែវទេ។ ហើយទៅដល់ស្វាយរៀងហ្នឹងគឺ ភារកិច្ចបញ្ជានៅស្វាយរៀងហ្នឹងគឺឈ្មោះ រ៉េន។ ហើយខ្ញុំដឹងថាលើ រ៉េន ហ្នឹងមានតែ តាសុន សេន ទេ អត់មាន តាម៉ុក គាត់ទៅខាងស្វាយរៀងទេ។ ឯទៅពេលណា ខ្ញុំភ្លាប់មិនបានទេ ប៉ុន្តែខ្សែបញ្ជាការគឺធំជាងគេគឺ សុន សេន បន្ទាប់មក រ៉េន, រ៉េន ហើយបានកងពលចំណុះ។ នៅបូព៌ាគេចាត់តាំងអ៊ីចឹង ហើយឯតាកែវនេះគឺមាន តាម៉ុក។ ឯ តាម៉ុក ទៅស្វាយរៀងដែរ ខ្ញុំភ្លាប់អត់ជុំដែរ ហ្នឹងគាត់ជាសមាជិកមជ្ឈិមដែរ ទៅយ៉ាងម៉េច ខ្ញុំមិនយល់ទេអាហ្នឹង។ ប៉ុន្តែខ្សែបញ្ជារបស់ខ្ញុំនៅស្វាយរៀងហ្នឹង ខ្ញុំដឹងថា តាសុន សេន ហើយនិង រ៉េន នេះឯង។

[១០:៤៥:៤៧]

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយពីស្វាយរៀងនេះបន្តិចទៀត។ ឥឡូវខ្ញុំបញ្ចប់ក្នុងការនិយាយពីតាកែវបន្តិចសិន។ លោកបានឆ្លើយថា លោកបានចេញទៅស្វាយរៀងហ្នឹងនៅក្នុងឆ្នាំ១៩៧៨។ អ៊ីចឹងខ្ញុំចង់សួរលោកឲ្យជួយបញ្ជាក់ចំណុចមួយចំនួនដែលយើងមាននៅក្នុងសំណុំរឿងយើងនេះ។ ហើយគឺដំបូងខ្ញុំសូមលើកយកឯកសារទី១ គឺឯកសារ E3/853, ERN ជាបារាំងគឺ 00290267, ERN ជាភាសាអង់គ្លេសគឺ 00185243, ERN ជាភាសាខ្មែរគឺ 00052825។ ដើម្បីពន្យល់បរិបទឲ្យលោកយល់គឺជាកំណត់ហេតុរបាយការណ៍ដែលផ្ញើជូនទៅអង្គការ មានសរសេរនៅលើឯកសារហ្នឹង ចេញមកពីភូមិភាគនិរតីចុះថ្ងៃទី០៣ មិថុនា ឆ្នាំ១៩៧៧។ នៅ<កថាខណ្ឌ>ទី១ នៃទំព័រដែលខ្ញុំទើបតែប្រាប់អម្បាញ់មិញនេះ និយាយ "អំពីសកម្មភាពខ្មាំងខាងក្រៅ ពីក្រៅ។ នៅតាមជួរព្រំដែន ខ្មាំងនៅតែបាញ់ផ្លោងមកលើទឹកដីយើងម្តងម្កាលដែរ។ នៅព្រំដែនខាងកំពតវិញ វាបានដកប្រជាជនវាប្រហែលជា<>បីគីឡូម៉ែត្រពីព្រំដែន ហើយនិងវាសរសេរអក្សរខ្មែរឃ្លូនថា វៀតណាម-កម្ពុជាសាមគ្គីគ្នារាប់ម៉ឺនឆ្នាំហើយ។ <តែផ្ទុយទៅវិញ> នៅវត្តកោះចន្ទុះ វាបានយកគ្រាក់ទ័រមកជីកលេណដ្ឋាន។" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងខ្ញុំចង់ដឹងថា តាមសកម្មភាពរបស់លោកនៅភូមិភាគនិរតីកាលហ្នឹងនុ៎ង លោកមានដឹងអំពីព្រឹត្តិការណ៍ខែមិថុនា ឆ្នាំ ១៩៧៧ នេះដែរឬទេ? តើនៅក្នុងខែមិថុនា ៧៧នេះ <ឬក៏មុនពេលហ្នឹង> តើលោកមានដឹងថា មានវៀតណាមបោះខិត្តប័ណ្ណអីហ្នឹងទេ? លោកដឹងទេ កាលនុ៎ងមានការបោះត្រាក់ហ្នឹង សរសេរមិត្តភាពវៀតណា

ម-កម្ពុជាអីជាដើមនេះ?

[១០:៤៨:៣៧]

**ឆ៖** ខ្ញុំសូមជម្រាបថា ត្រាក់នេះខ្ញុំអត់បានដឹងទេ អាចជាបោះនៅកំពត ឬនៅខាងណាព្រំដែនកំពត កន្លែងជីកដែលលោកស្រីមានយោបល់អម្បាញ់មិញ ឯខាងតាកែវនេះគឺអត់មានឃើញត្រាក់ទេ។

**សៈ** តើលោកស្គាល់វត្តកោះចន្លុះហ្នឹងដែរឬទេ? តើនៅតាមការប្រជុំរបស់លោកនោះ លោកមានទទួលបានព័ត៌មានស្តីអំពីការជីកលេណដ្ឋានដោយប្រើត្រាក់ទ័រនៅកន្លែងហ្នឹងដែរឬទេ? ហើយបើនិយាយជាបើកទូលាយតែម្តង ថាតើលោកមានបានទទួលព័ត៌មានពីការប្រើត្រាក់ទ័រជីកលេណដ្ឋាននេះជាទូទៅនៅកន្លែងផ្សេងទៀតអីដែរឬទេ?

**ឆ៖** ចំណុចជីកលេណដ្ឋានតាមព្រំដែនខាងតាកែវ កំពតនេះគឺថា បើនិយាយជាក់ស្តែងរវាងកម្ពុជាវៀតណាម វៀតណាមក៏មានលេណដ្ឋានហើយស្រេច កម្ពុជាក៏មានលេណដ្ឋានហើយស្រេច។ មិនមែនបានសេចក្តីថា ភាគីមួយៗ ប្រទេសមួយៗមិនមានលេណដ្ឋានទេ គឺមានលេណដ្ឋានហើយស្រេចតែម្តង។ ហើយបើវៀតណាមសុទ្ធតែបេតុង ចាក់សុទ្ធតែបេតុងតែម្តងតាមព្រំដែន មិនមែនជីកលេណ-ដ្ឋានដីដូចកម្ពុជាទេ វៀតណាមសុទ្ធបេតុង ចាក់សុទ្ធបេតុងហើយស្រេចតែម្តង។ សូមជម្រាបអ៊ីចឹង។

**សៈ** នៅពេលដែលលោកនិយាយថា លេណដ្ឋានដែលវៀតណាមធ្វើនុ៎ង ធ្វើសុទ្ធតែចាក់បេតុងនេះ ចង់និយាយថានៅខាងខ្មែរហ្នឹង គេធ្វើខុសពីខាងវៀតណាម ឬក៏យ៉ាងម៉េច? សូមលោករៀបរាប់អំពីលេណដ្ឋាននៅខាងខ្មែរបន្តិចមើល។

[១០:៥០:៥៨]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា វៀតណាមធ្វើលេណដ្ឋានបេតុង ពីព្រោះវៀតណាមមានជាងខ្មែរ ឯខ្មែរធ្វើលេណដ្ឋានដីសុទ្ធ មានតែដាក់ឈើ ហើយដាក់ដីពីលើទេ។ អ៊ីចឹងដល់ខែវស្សាមក វាបាក់វិញហើយ។ បើវៀតណាម គឺអត់បាក់ទេ បានជារៀងរហូតតែម្តង។ ឯខ្មែរមួយឆ្នាំ តែផុតពីរដូវប្រាំងហើយ ចូលដល់រដូវវស្សា លេណដ្ឋានហ្នឹងគឺត្រូវបាក់អស់ហើយ។ អ៊ីចឹងប្រាំងក្រោយ គឺធ្វើទៀតខ្មែរ។ ឯវៀតណាមអត់ទេ ធ្វើតែម្តង សុទ្ធតែបេតុងតែម្តង។ ហើយបេតុងហ្នឹងសូមជម្រាបថា កាំភ្លើងដេកា-៧៥អឺ បាញ់ទៅគ្រាន់តែឆែបបន្តិចទេ អត់បាក់ទេ។ ហើយខ្មែរលេណដ្ឋានដី ដាក់មក គឺទ្រោកទៅក្រោមហើយ។ ហ្នឹងសូមជម្រាបប៉ុណ្ណឹង។

**សៈ** លោកបាននិយាយជាច្រើនដងអំពីកងកម្លាំងដែលមិនស្មើគ្នារវាងកងទ័ពវៀតណាម និង

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

កងទ័ពកម្ពុជា ហើយម្សិលមិញលោកបានជម្រាបផងដែរថា ដោយសារហេតុហ្នឹងហើយ បានលោកទទួលបញ្ជាថា កុំឲ្យវ៉ៃគេមុន ព្រោះថាយើងមិនមានកម្លាំងគ្រប់គ្រាន់ដើម្បីវ៉ៃវៀតណាមទេ។ អ៊ីចឹងសំណួរខ្ញុំ ខ្ញុំនឹងផ្តោតទៅលើឯកសារចំនួនបី។ ខ្ញុំនិយាយជាទូទៅថា គឺជាសុទ្ធតែជាឯកសារដែលធ្វើឡើងមុនពេលដែលលោកទៅដល់ខេត្តស្វាយរៀង។ ហើយខ្ញុំចង់ដឹងថា តើនៅក្នុងពេលប្រជុំ អាចមុនពេលលោកទៅស្វាយរៀង ឬក៏ពេលដែលលោកទៅដល់ស្វាយរៀងហើយនោះ ពេលលោកបានប្រជុំនោះមានដឹងរឿងហ្នឹងដែរឬក៏អត់? អ៊ីចឹងសំណួរទី១ របស់ខ្ញុំថា តាម៉ុក ជាអ្នករើសកម្លាំង ជ្រើសរើសកម្លាំងដើម្បីបញ្ជូនទៅស្វាយរៀង។ អ៊ីចឹងខ្ញុំសួរថាតើ តាម៉ុក <ឬក៏អ្នកណាម្នាក់> គាត់មានបានពន្យល់សង្ខេបអំពីស្ថានភាពនៅស្វាយរៀង មុនពេលដែលលោកត្រូវចេញ<ពី> តាកែវ ដែរឬទេ?

[១០:៥៣:២៣]

**ឆ៖** ជាធម្មតា ខ្ញុំសូមជម្រាបថា ក្នុងនាមជាមេភូមិភាគ ឬមេកងពល គឺថាមុននឹងបញ្ជូនកម្លាំងទៅ សុទ្ធតែនិយាយពីសភាពការណ៍។ សភាពការណ៍ គាត់និយាយពេលនោះ គឺទាក់ទងនឹងវៀតណាមចូល។ ហើយចូលហ្នឹង ដូចខ្ញុំបានជម្រាបអ៊ីចឹង គឺថាក៏មិនខុសគ្នាប៉ុន្មានដែរ ចាញ់ឈ្នះគ្នាតែ២ ឬ៣គីឡូប៉ុណ្ណឹងទេ។ គាត់បានជម្រាបថា វៀតណាមចូលជិតដល់ទីរួមស្រុកប្រសូត្រហើយ អ៊ីចឹងសូមឲ្យអស់លោកទៅប្រញាប់ ហើយមានការប្រុងប្រយ័ត្ន។ អ៊ីចឹងហើយ បានខ្ញុំមានយោបល់ពីម្សិលមិញថា ខាងខ្ញុំទៅដល់ស្វាយរៀងមិនទាន់ចុះពីឡានផង វៀតណាមបាញ់ឆេះអស់ឡានបី ស្លាប់ និងរបួស ក្នុងបីឡានហ្នឹងសឹងតែទាំងអស់ទៅហើយ។ មូលហេតុអី? ពីព្រោះពេលដែលមុននឹងទៅ តាម៉ុក គាត់ឧទ្ទេសនាមសភាពការណ៍ថា វៀតណាមមិនទាន់ដល់ទីរួមស្រុកប្រសូត្រទេ។ អ៊ីចឹងមិត្តខ្ញុំ ត្រូវដឹកកម្លាំងឲ្យទៅដល់ទីរួមស្រុកប្រសូត្រ។ ការពិតវៀតណាមវាមកហួសទីរួមស្រុកប្រសូត្រហើយ បានវាបាញ់ឡានយើងបាន។ អ៊ីចឹងសភាពការណ៍ដឹងមុន ប៉ុន្តែដឹងថា នៅក្រោយស្រុក ទីរួមស្រុកប្រសូត្រ។ ប៉ុន្តែជាក់ស្តែងដែលពេលខ្ញុំទៅនេះ គឺមិនមែននៅហ្នឹងណា៎ វៀតណាមរុលមកមុខទៀតហើយ រុលមកមុខទៀតហើយ។ អ៊ីចឹងបានខូចខាតកម្លាំងអស់បីឡាន។ មិនទាន់ដឹងភូមិសាស្ត្រស្រុកស្វាយរៀង ខេត្តស្វាយរៀងយ៉ាងណាទេ កម្លាំងវាត្រូវខូចខាតបីឡានហើយស្រេច ទាំងងាប់ ទាំស្លាប់ ទាំងរបួស។

**ស៖** ពេលលោកនិយាយអំពីឡានទាំងបីហ្នឹង លោកចង់និយាយពីក្បួនឡានទ័ពដែលចេញពីតាកែវទៅស្វាយរៀង ឬក៏លោកនិយាយពីក្បួនឡានផ្សេងទៀត ឬក៏ឡានបីហ្នឹងឡានមកពីណាវិញ?

[១០:៥៥:៣០]

**ឆ៖** ក្បួនឡានហ្នឹង មិនមែនឡានបីទេទៅពីស្វាយរៀង គឺឡាន៣៥ឡាន។ ដឹកមួយជើងហ្នឹង ៣៥ឡាន ហើយទាំងអស់ដឹកទ័ពទាំងអស់ វាបួនវរសេនាធំ វាច្រើនដែរ១.៨០០។ ប៉ុន្តែទៅលើកទី១ហ្នឹង គឺ៣៥ឡាន។ ៣៥ឡាន ឡានបីហ្នឹងគឺទៅមុខគេ គឺៗដឹកទ័ពពីតាកែវទៅចុះនៅទីរួមស្រុកប្រសូត្រដើម្បី ពង្រាយកម្លាំងនៅហ្នឹង ប៉ុន្តែវៀតណាមវាមកពីមុខទីរួមស្រុកប្រសូត្រទៅហើយ អ៊ីចឹងយើងទៅហ្នឹង ធ្លាក់ក្នុងវង្វង់គ្រៀមវាបាត់ទៅហើយ ដោយសារឃាត់ឡានបីហ្នឹងលឿនជាងគេ អ្នកដែលយាមហ្នឹង អ្នកយាមផ្លូវថាកុំឱ្យទៅហ្នឹង គឺយាមឃាត់អត់ទាន់ផង ឡានបីហ្នឹងទៅផុត ៗហ្នឹងគ្រោះថ្នាក់បីឡានហ្នឹងតែម្តង។ ហ្នឹងសូមជម្រាបអ៊ីចឹង គឺឡាននេះមិនមែនទ័ពណាផ្សេងទេ គឺទ័ពដែលបញ្ជូនទៅពីតាកែវ។

**ស៖** សូមអរគុណ។ លោកបាននិយាយថា លោកបានប្រជុំជាមួយ តាម៉ុក ហ្នឹងចុងឆ្នាំ៧៧ ហើយបើខ្ញុំមិនច្រឡំទេ គឺថាលោកចេញទៅស្វាយរៀងហ្នឹង គឺខែកក្កដា ឆ្នាំ១៩៧៨។ អ៊ីចឹងខ្ញុំសួរលោកថាតើចន្លោះ<ចុងឆ្នាំ៧៧ និងខែកក្កដា ឆ្នាំ១៩៧៨ តើ>លោកមាន<ចូលរួមប្រជុំណាមួយជាមួយតាម៉ុក ឬក៏អ្នកផ្សេងទៀត ដើម្បី>ទទួលបានព័ត៌មាន<ថ្មីៗ>ដែរឬទេ? គឺ<>មានបានទទួលព័ត៌មាន<បន្ថែមថ្មីៗ លើសពីព័ត៌មានដែលទទួលបាននៅក្នុងចុងឆ្នាំ១៩៧៧ ដែរ ឬទេ>?

**ឆ៖** ខ្ញុំសូមជម្រាបថាប្រជុំចុង៧៧ ហើយបញ្ជូនកម្លាំងពាក់កណ្តាល៧៨ ខ្ញុំជឿថាលោកស្រីអាចឆ្ងល់ថា ម៉េចក៏ប្រើពេលវេលាយូរម្ល៉េះ។ ពេលវេលាប្រជុំនេះគ្រាន់តែរៀបចំកម្លាំង។ ហើយមូលហេតុអីដែលរៀបកម្លាំងយូរ ពីព្រោះស្វាយរៀងក៏ប្រឈមមុខនឹងវៀតណាមដែរ អ៊ីចឹងត្រូវដកវរសេនាធំណា ដកវរសេនាតូចណា យកកម្លាំងណាទៅប៉ះប៉ូវ ទម្រាំបានដកកម្លាំងនោះមក អ៊ីចឹងត្រូវប្រើពេលវេលា មិនមែនបានសេចក្តីថា កម្លាំងអន្តរាគមន៍ហើយ ទៅដកមកភ្លាម អត់បានទេ គឺដកកម្លាំងដែលប្រឈមមុខនឹងវៀតណាមតាមព្រំដែនតាកែវដែរ។ អ៊ីចឹងត្រូវប្រើពេលវេលាយូរ។ អ៊ីចឹងទម្រាំបានបួនវរសេនាធំ ត្រូវប្រើពេលវេលាយូរណាស់។ គិតមើលប្រជុំចុង៧៧ និយាយរួមខែ១២ ៧៧ ដល់តែខែ៥ ចុងខែ៥បាន ៗបញ្ជូនមកខែ៥ ៧៨។ អ៊ីចឹងបានខ្ញុំប្រើពាក្យថាពាក់កណ្តាល៧៨ បានដល់ស្វាយរៀង។ សូមអរគុណ។

[១០:៥៨:៤០]

**ស៖** តាមការបកប្រែនោះ ខ្ញុំឮថា បកប្រែថាលោកថាមានប្រជុំនៅខែឧសភា ឆ្នាំ១៩៧៧ តើលោកចង់មានន័យថា ខែធ្នូ ឆ្នាំ១៩៧៧? តើលោកបាននិយាយជាភាសាខ្មែរថា ខែធ្នូ ឆ្នាំ១៩៧៧ មែនទេ? ឬក៏>លោកអាចបញ្ជាក់<អំពី>ខែណា<ឱ្យបានច្បាស់ដែរ ឬទេ>?

**ឆ៖** មិនចាំខែច្បាស់ទេ ប៉ុន្តែខ្ញុំដឹងថាចុង៧៧ ប្រជុំដើម្បីរៀបចំកម្លាំង ដកកម្លាំងទៅបន្ថែមទៅ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

ស្វាយរៀង ចុង៧៧ហ្នឹង។ ហើយពីរៀងចំរហូតទៅដល់ចុងខែ៥ ៧៨ បានៗបញ្ជូនទៅ។ សូមបញ្ជាក់អ៊ីចឹង។

**សៈ** យើងមានសាក្សីឈ្មោះ ជួន ធី ដែលបានមកផ្ដល់សក្ខីកម្មមុនលោកនោះ គាត់បាននិយាយថា មុននឹងពេលដែលគេបញ្ជូនសមរភូមិនោះ គាត់នៅក្នុងអង្គភាពគាត់ ទទួលបន្ទុកខាងការងារដាំដុះ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើលោកមានដឹងដែរឬទេថា នៅក្នុងចំណោមយោធាដែលត្រូវបានបញ្ជូនទៅស្វាយរៀងនោះ តើពួកគាត់មានច្រើនដែរឬទេ <>ដែល<ត្រូវបានរំសាយទាំងស្រុង មុនពេលទៅ>ធ្វើការខាងដាំដុះបង្កបង្កើនផលហ្នឹង <និងធ្វើការសំណង់ ហើយតើប៉ុន្មានត្រូវបានចាត់តាំងឲ្យធ្វើការងារយោធា មុននឹង>ត្រូវបានបញ្ជូនទៅស្វាយរៀង<>? <តើលោកអាចផ្ដល់ជាគំនិតពីចំនួននោះបានទេ>?

[១១:០០:៣៦]

**ឆៈ** ខ្ញុំសូមជម្រាបថា ការរៀបចំបង្កើតបានជាកងពល២២១ ជាកងពលអន្តរាគមន៍ដែលខ្ញុំបានជម្រាបពីម្សិល គឺត្រូវជ្រើសរើសចេញមកពីគ្រប់កងពលដែលខ្ញុំរៀនរាប់ថា មានកងពល២១០, ២៣០, ២៥០, ២៧០។ អ៊ីចឹងមួយកងពល ជ្រើសរើសយកមកតែមួយវរសេនាធំទេ បង្កើតបានទៅជាកងពលតូចអន្តរាគមន៍២២១។ ដូច្នេះអត់មានជ្រើសរើសកម្លាំងដែលបង្កបង្កើតផលទៅទេ សម្រាប់កងពលដែលគេប្រគល់ឲ្យខ្ញុំទៅនេះ គឺអត់មានកម្លាំងដែលបង្កបង្កើតផលទេ គឺទៅកម្លាំងប្រយុទ្ធសុទ្ធសាធ កម្លាំងប្រយុទ្ធសុទ្ធសាធ។

**សៈ** អាហ្នឹងសំដៅលើកងពលតូច២២១ ក៏ប៉ុន្តែចំពោះកងពលតូចផ្សេងទៀតនោះ តើក្នុងចំណោមកងពលហ្នឹង មានអ្នកដែលទទួលបន្ទុកខាងបង្កបង្កើនផលដែរឬទេ ដែលដល់ពេលដែលមានបញ្ហានៅស្វាយរៀងហ្នឹង គេប្រមូលគាត់ ហើយបញ្ជូនគាត់ទៅស្វាយរៀងដែរ គាត់មិនបំពេញការងារជាយោធាទេ អង្កាល់នៅតាកែវហ្នឹង?

**ឆៈ** ចំណុចនេះ ខ្ញុំក្ដាប់អត់បានដែរ ពីព្រោះកម្លាំងដែលប្រគល់ឲ្យខ្ញុំ សុទ្ធតែកម្លាំងប្រយុទ្ធសុទ្ធសាធ ឯកម្លាំងបង្កបង្កើតផល អត់មកលាយឡំជាមួយអង្គភាពកងពលខ្ញុំទេ។ សូមជម្រាបអ៊ីចឹង។

[១១:០២:២០]

**សៈ** មិនបញ្ហាអ្វីទេ។ ឥឡូវខ្ញុំសូមចូលទៅនិយាយឯកសារទី១ ខ្ញុំសូមផ្ដល់ឯកសារ ប្រគល់ឯកសារនេះជូនទៅលោក។ ខ្ញុំមិនចាប់អារម្មណ៍លើខ្លឹមសារនៃឯកសារនេះទេ គឺថាមានទីតាំងមួយចំនួនដែលមានសរសេរនៅលើឯកសារហ្នឹង ដោយលោកបានរៀបរាប់ថា មានការច្បាំងគ្នា គឺថាជួនកាលរុញ

គ្នាទៅវិញទៅមក រវាងទាហានខ្មែរនិងទាហានវៀតណាមនោះ។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅពេលដែលលោកទៅដល់ស្វាយរៀងហ្នឹង តើកន្លែងដែលមានសរសេរនៅក្នុងឯកសារនេះហ្នឹង ធ្វើឱ្យលោកនឹកឃើញ ឬក៏អត់ ស្គាល់កន្លែងហ្នឹងឬក៏អត់? ឯកសារទី១ គឺឯកសារ E3/946, ERN ជាភាសាបារាំងគឺ 00332727, ERN ជាភាសាអង់គ្លេសគឺ 00185205, ERN ជាភាសាខ្មែរគឺ 00021015។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតប្រគល់ឯកសារនេះទៅលោកសាក្សី។ គឺជាទូរលេខចុះថ្ងៃទី<២៦> មេសា ឆ្នាំ<១៩៧៨> សូមទោស។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី ខ្ញុំសូមអាននៅលើទំព័រទី១ លេខ២តូច គឺជារបាយការណ៍ដែលនិយាយអំពីសភាពការណ៍នៅឆ្នាំ១៩៧៨ហ្នឹង ថ្ងៃទី២៦ ខែមេសា ដែលមានចម្លងជូន អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន។ “ស្ថានភាពខ្មាំង បន្ថែមពីលើខ្មាំងព្រះទន្លេ<យ៉ាងច្បាស់នោះ> វាបុកមួយឆាប់ឡើងត្រង់ស្ពានធ្លក តម្រង់ផ្ទះអក្សរ“ស”។ ហើយឆាបទៅ<តាមព្រៃ>ព្រំដែនតាមកក់វិញ។” សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងខ្ញុំដឹងថា កងពល<តូច>២២១របស់លោកនេះ លោកបានចុះទៅអន្តរាគមន៍ជាច្រើនកន្លែងនៅខេត្តស្វាយ-រៀង។ តើនៅខែកក្កដា ឆ្នាំ១៩៧៨ ហើយនិង២ខែបន្ទាប់មកទៀតហ្នឹង ដែលលោកនៅស្វាយរៀងដែរហ្នឹង តើនៅព្រះទន្លេ ហើយនិងស្ពានធ្លក ហើយនិងនៅកន្លែង<ព្រៃ>ព្រំដែននេះ លោកស្គាល់កន្លែងទាំងអស់ហ្នឹងទេ? សុទ្ធតែជាកន្លែងដែលលោកធ្លាប់ប្រយុទ្ធដែរ ឬក៏យ៉ាងម៉េច? ឬក៏ជាកន្លែងដែលមានការច្បាំងគ្នា ក្រោយពីខែមេសា ឆ្នាំ១៩៧៨ដែរឬក៏យ៉ាងណា?

[១១:០៥:៥៦]

**លោក អៀង ផាន៖**

**ផ៖** ខ្ញុំដូចជាមិនស្គាល់ឈ្មោះតាមឯកសារនេះ ដូចចន្លោះ។

**ស៖** <មិនមាន>បញ្ហាអ្វីទេ។ ឥឡូវខ្ញុំសូមចូលទៅនិយាយពីឯកសារមួយទៀត ដើម្បី -- គឺបើឯកសារទី២ គឺឯកសារ E3/862, ERN ជាភាសាបារាំងគឺ 00814597, ERN ជាភាសាខ្មែរគឺ <00021019>, ERN ជាភាសាអង់គ្លេស 00185207។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារនេះទៅសាក្សី គឺរបាយការណ៍ស្តីអំពីសភាពការណ៍<នៅគ្រប់>តំបន់ នៅសប្តាហ៍ទី១ <នៃខែឧសភា>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឆ្នាំ១៩៧៨។ ហើយខ្ញុំនឹងសួរគាត់ដដែលទាក់ទងនឹងទីតាំងដែលមានសរសេរនៅក្នុងឯកសារនេះ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** លោកសាក្សី អ្វីដែលខ្ញុំចាប់អារម្មណ៍នៅក្នុងឯកសារនេះគឺ ផ្នែកទី១នេះ និយាយអំពីស្ថានភាពការពារជាតិ។ ឯកសារនេះគឺចុះខែឧសភា ឆ្នាំ១៩៧៨ គឺមុនពេលដែលលោកទៅដល់បន្ទិច។ អ៊ីចឹងខ្ញុំចង់ដឹងថា មុនពេលដែលលោកទៅដល់នុ៎ង លោកធ្លាប់ទទួលបានព័ត៌មានអីពាក់ព័ន្ធទៅនឹងតំបន់២៤ និងតំបន់២៣ទេ?

[១១:០៨:០០]

**លោក អៀង ផាន៖**

**ឆ៖** ក្នុងឯកសារនេះគឺថា ខ្ញុំក្ដាប់មិនបានដែរ។ ចំណុចណាដែលខ្ញុំក្ដាប់បាន ខ្ញុំបញ្ជាក់ជូនវិញ ប៉ុន្តែឯកសារនេះ ខ្ញុំក្ដាប់មិនបាន។

**ស៖** អ៊ីចឹងខ្ញុំត្រឡប់មកសំណួរមុនវិញ។ ក្នុងពេលដែលលោកទៅដល់ពាក់កណ្ដាលឆ្នាំ១៩៧៨នោះ លោកមិនមានព័ត៌មានអ្វីពាក់ព័ន្ធនឹងទីតាំងដែលលោកត្រូវទៅហ្នឹងទេ មែនទេ? តាំងពីពេលដែលគេប្រជុំនៅ<ចុង>ឆ្នាំ៧៧ មកអត់អ្នកណាធ្លាប់ផ្ញើរបាយការណ៍ ផ្ញើទូរលេខអីឲ្យលោក មុនពេលដែលលោកទៅដល់ស្វាយរៀងដើម្បីប្រាប់អីស្ថានភាពដែលកំពុងកើតឡើងនៅស្វាយរៀងទេ មែនទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា មុននឹងខ្ញុំទៅហ្នឹងគឺថ្នាក់លើបានពន្យល់ខ្ញុំពីរឿងស្ថានភាពដែលត្រូវចាំបាច់ដែលត្រូវទៅជួយ ពាក់កណ្ដាល៧៨។ ករណីដែលចាំបាច់ត្រូវជួយហ្នឹង គឺអង្គភាពអន្តរាគមន៍របស់យើងខ្ញុំហ្នឹងត្រូវទៅទីរួម ទល់មុខទីរួមស្រុកប្រសូត្រ និងចក ភូមិចក គឺអត់ទាន់ញែកទៅណាឆ្ងាយទេ គឺយកពីរមុខព្រួញហ្នឹងសំខាន់។ ហើយជាក់ស្ដែងខ្ញុំទៅគឺពង្រាយកម្លាំង គឺតាមហ្នឹងមែន តាមហ្នឹង។

**ស៖** ពេលដែលលោកទៅដល់ស្វាយរៀង តើឈ្មោះ រ៉ែន ហ្នឹងមែនទេ ដែលមកទទួលលោក?

[១១:០៩:៤៩]

**ឆ៖** ខ្ញុំទៅដល់ស្វាយរៀងឈ្មោះ រ៉ែន នេះទទួល។ ទទួលហើយ ជួបខ្ញុំពីរនាក់ បញ្ជាក់ពីសភាពការណ៍។ អ៊ីចឹងហើយបានខ្ញុំមិនចាប់អារម្មណ៍ថា ទីរួមស្រុកប្រសូត្រមានវៀតណាមហ្នឹងណា៎ ពីព្រោះ

គាត់ក្តាប់អត់ជុំដែរ វៀតណាមមកស្ទាត់។ អ៊ីចឹងហើយបានខូចខាតបីឡានដែលខ្ញុំបញ្ជាក់ហ្នឹង ព្រោះគាត់បញ្ជាក់ខ្ញុំ ពេលដែលកម្លាំងទ័តទៅដល់ទីបញ្ជាការរបស់ រ៉ែន ហ្នឹងគឺឡានបីហ្នឹងទៅមុខហួសហើយ គាត់ទៅមុនគេនុំង ឯឡានផ្សេងទៀតគឺនៅជាមួយខ្ញុំ ជួបគាត់ ១ថា ទៅចុះនៅទីរួមស្រុកប្រសូត្រ ហើយពង្រាយកម្លាំង ហើយមួយផ្នែកទៀតពង្រាយមកភូមិចក១។ ខ្ញុំធ្វើតាមគោលការណ៍នេះ ប៉ុន្តែយើងខូចខាតបីឡានទៅហើយ។ គឺមាន ១បញ្ជាក់សភាពការណ៍ ប៉ុន្តែអ្នកនៅសមរភូមិហ្នឹងក្តាប់វៀតណាមមកអត់បានពីយប់។ ព្រោះខ្ញុំត្រូវទៅយប់ មិនមែនទៅថ្ងៃទេ ទៅពីតាកែវទៅម៉ោងប្រាំ ទៅដល់ស្វាយរៀងម៉ោងមួយ ម៉ោងបួន ឡានខ្លះម៉ោងបួន ម៉ោង ឡានដែលទៅមុនគេហ្នឹងលឿនជាងគេ។ អ៊ីចឹងដូចជាផែនការហ្នឹងដូចជា យើងថាខូចខាតដោយសារក្តាប់ស្ថានការណ៍មិនបាន ព្រោះមិនមែនទៅថ្ងៃទេ ដឹកឡានទៅនេះគឺទៅយប់ៗ បានជាគ្រោះថ្នាក់ហ្នឹង។ សូមជម្រាបអ៊ីចឹង។ អ៊ីចឹងបានន័យថា ស្ថានការណ៍ថ្នាក់លើមានពន្យល់ ហើយ រ៉ែន ហ្នឹងក៏ពន្យល់ដែរ ប៉ុន្តែគាត់អត់បានដឹងថា វៀតណាមមកយប់ហ្នឹងទេ អត់បានដឹងទេ។ សូមជម្រាបប៉ុណ្ណឹង។

**ស៖** ពេលលោកទៅដល់<ស្វាយរៀង> លោកបានបញ្ជាក់ ហើយសាក្សី ជួន ធី ក៏បាននិយាយផងដែរថា កងពល<តូច>២២១ របស់លោកហ្នឹងជាកងពលតូចចល័ត ដែលត្រូវផ្តល់ជំនួយទៅដល់កងពលតូចផ្សេងទៀតដែលត្រូវការជំនួយ។ អ៊ីចឹងពេលដែលលោកបែងចែកកម្លាំងនោះ តើលោកមានបានប្រជុំជាមួយនឹងកងពលតូចផ្សេងទៀតទេ? ហើយ រ៉ែន នេះគាត់មានចេញសេចក្តីណែនាំអ្វីជាក់លាក់ទៅកាន់លោកពាក់ព័ន្ធនឹងថា តើកងពលតូចណាដែលលោកត្រូវផ្តល់ជំនួយទៅឲ្យគេនោះ?

[១១:១២:២១]

**ឆ៖** ខ្ញុំសូមជម្រាបថា ជាធម្មតាគឺថាចូលទៅដល់សមរភូមិហើយ មេបញ្ជាការឈ្មោះ រ៉ែន ហើយមេបញ្ជាការកងពលតូចដទៃទៀត ក៏មកប្រជុំរួមជាមួយខ្ញុំផងដែរ។ ហើយប្រជុំនេះមិនមែនមានរបៀបវារៈអីធំដុំទេ ដោយសារសភាពការណ៍វាប្រញាប់ អ៊ីចឹងឈរនិយាយ។ ឈរនិយាយថា ឥឡូវនេះឥឡូវទៅនៅចំប្រសូត្រ ហើយនិងចកហ្នឹង គឺកងពល១តូច៣៤០ អ៊ីចឹងកងពលអន្តរាគមន៍របស់យើងខ្ញុំទៅជួយកងពល៣៤០ ១ដែល១មុខព្រួញគាត់ប្រសូត្រ ហើយនិងចក។ អ៊ីចឹងកងពលរបស់ខ្ញុំណោះ គឺថាមានការនិយាយគ្នាមុនហើយបានចូល មិនមែនចេះតែចូលទេ។ សូមជម្រាបអ៊ីចឹង។

**ស៖** ពេលដែល រ៉ែន គាត់ចេញសេចក្តីណែនាំទៅកាន់លោកហ្នឹង គឺគាត់ប្រាប់លោកឲ្យរុញវៀតណាម ឲ្យត្រឡប់ទៅប្រទេសវិញ ឬក៏បញ្ជាឲ្យលោកហ្នឹងថា ត្រូវវ៉ៃវៀតណាមចូលទៅដល់ក្នុងទឹក

ដីវៀតណាមតែម្ដង?

**ឆ៖** ចំណុចនេះ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបាននិយាយពីម្សិលហើយថា វៀតណាមជាប្រទេសធំ កងទ័ពច្រើន ប្រជាជនក៏ច្រើន អាវុធយុទ្ធភណ្ឌក៏ច្រើន។ ឯក្នុងឋានៈខ្ញុំមកអន្តរាគមន៍នេះ បើយើងនិយាយភាសាធម្មតាថា គ្រាន់តែទប់ៗកុំឱ្យលឿនពេកទេ បើថានិយាយឱ្យរុញវៀតណាមឱ្យធ្លាយទៅដល់ប្រទេសវៀតណាមវិញ ខ្ញុំមើលមិនមានលទ្ធភាពទេ មិនមានលទ្ធភាពទេ ខ្ញុំសូមជម្រាបអ៊ីចឹងតែម្ដង។ លទ្ធភាពគ្រាន់តែទប់ៗ ហើយទប់មិនជាប់ទៀតនោះ មិនមែនគ្រាន់ថាទប់ហើយជាប់ទេ ទប់មិនជាប់ទៀត ទប់ឆ្វេងចេញស្ដាំ ទប់ស្ដាំចេញឆ្វេង ទប់ខាងមុខចេញខាងក្រោយ ល្បិចវៀតណាមគាត់ច្រើនណាស់ ពីព្រោះគាត់មានពិសោធក្នុងសង្គ្រាមច្រើនដែរ អ៊ីចឹងការប្រយុទ្ធនេះក៏រួមផ្សំនឹងកម្លាំង រួមផ្សំនឹងអាវុធ គាត់មានប្រៀបជាងផ្នែកកម្ពុជា។ អ៊ីចឹងយើងមិនអាចទទួលការណែនាំថា ទៅរុញច្រានវៀត-ណាមឱ្យដល់ប្រទេសវៀតណាមវិញ។ សម្រាប់ខ្ញុំក៏ៗគ្មានសង្ឃឹមថារុញបានដែរ គ្រាន់តែទប់ៗបាន។ បាទ សូមអរគុណ។

[១១:១៤:៥៦]

**ស៖** អ៊ីចឹងហើយបានជានៅម្សិលមិញនោះ ពេលដែលសហព្រះរាជអាជ្ញាអានអត្ថបទមួយជូនលោកស្ដាប់ គឺជាអត្ថបទសារព័ត៌មានវៀតណាមដែលនិយាយថា កងពល<តូច>របស់លោក និងកង<តូច>ពល៣៤០ហ្នឹង បានចូលទៅដល់ទឹកដី<កម្ពុជា>*(ស៊ីក)* លោកៗពេលនុំងលោកភ្ញាក់ផ្អើលណាស់ លោកបានដូចថា វាមិនអាចអ៊ីចឹងទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងមែន ព្រោះមិនមានលទ្ធភាពអីទៅលើកទ័ពទៅៗយកទឹកដីវៀតណាមទេ។ ខ្ញុំគ្មានសង្ឃឹមអី សម័យនុំងក៏មិនមានលទ្ធភាពអីរុលទៅយកអ៊ីចឹងបានទេ។ ពីព្រោះសម្រាប់ខ្ញុំ ខ្ញុំស្គាល់ៗកងទ័ពកម្ពុជាប្រជាធិបតេយ្យហ្នឹងច្បាស់ដែរ។ គឺថាទី១ យើងទើបនឹងចេញពីសង្គ្រាម៥ឆ្នាំជាមួយ លន់នល់ទើបនឹងរើបៗឡើងវិញ រៀបចំកងកម្លាំងមិនទាន់រឹងមាំផងហ្នឹង។ អ៊ីចឹងយើងគ្មានលទ្ធភាពអីទៅឈ្លានពានវៀតណាម ទៅយកទឹកដីវៀតណាមទេ។ ខ្ញុំសូមជម្រាបលោកស្រីអ៊ីចឹង។ បាទសូមអរគុណ។

**ស៖** ខ្ញុំចង់ឱ្យលោកមានមតិយោបល់បន្តិច ទៅលើអ្វីដែលបានជជែកគ្នាកាលពីម្សិលមិញរួចមកហើយ គឺជាចម្លើយរបស់ សុខ ឈៀន ជាអតីតអនុប្រធានរបស់លោក។ គឺឯកសារ E3/428, ERN ជាភាសាបារាំង 00485477, ERN ជាភាសាអង់គ្លេស 00374950 និងជាភាសាខ្មែរ 00373485 និងបន្តទៅមុខទៀត។ កាលពីម្សិលមិញលោកបាននិយាយថា ខាងលោកហ្នឹងមិនមានបានចាប់ទាហានវៀត

ណាមបានទេ។ នេះជាចម្លើយរបស់ សុខ ឈៀន ខ្ញុំសូមដកស្រង់៖ “បើតាមខ្ញុំដឹង ទាហានខ្មែរក្រហម មិនដែលចាប់បានទាហានវៀតណាមទេ ក៏ប៉ុន្តែមានតែទាហានវៀតណាមទេ មកចាប់ទាហានខ្មែរនោះ។ ក្នុងកងរបស់ខ្ញុំ មានទាហាន២០នាក់ដែលត្រូវវៀតណាមចាប់បាន។ មូលហេតុដែលខ្មែរក្រហមមិនអាច ចាប់វៀតណាមបាន ពីព្រោះថា ពេលដែលខ្ញុំទៅដល់នោះ ទាហានវៀតណាមនុំងមានកងទ័ពរឹងមាំរួច ទៅហើយ ហើយគេដាក់មីនដាក់អីនៅតាមវាលស្រែទៀត។ អ៊ីចឹងហើយបានជាវាបង្កជាឧបសគ្គមិនឲ្យ កងទ័ពខ្មែរក្រហមនុំងរុលទៅមុខបាន។” ពាក់ព័ន្ធបញ្ហានេះ ខ្ញុំចង់សួរលោក ៗនិយាយថា លោកត្រូវបាន គេបាញ់របួសដោយរថក្រោះ ហើយនិងរបួសដោយសារមីនផងដែរ។ អ៊ីចឹងលោកអាចបញ្ជាក់បានទេ អំពីចម្លើយរបស់ សុខ ឈៀន នេះ ដែលគាត់ថា កងទ័ពវៀតណាមនុំងបានដាក់មីនជាច្រើននៅតាមវាល ស្រែ លោកមាននឹកឃើញពីចំណុចហ្នឹងទេ?

[១១:១៨:២៧]

**ឆ៖** ខ្ញុំសូមជម្រាបថា មីនពិតជាមាន ពីព្រោះយ៉ាងម៉េចបានខ្ញុំថាមាន ហើយខ្ញុំមិនដឹងថា វៀតណាមដាក់ ឬក៏កម្ពុជាយើងដាក់ទេ។ ប៉ុន្តែក្រោយដែលខ្ញុំរបួសហ្នឹង ពេលដែលខ្ញុំរបួសគឺរបួសជើង ហើយរបួសធ្ងន់។ អ៊ីចឹងគេសែងខ្ញុំមកហ្នឹង កាត់វាលស្រែ កាត់វាលស្រែហ្នឹង មកទាក់មីនមួយគ្រាប់ ទៀត ទាក់មីនដែលបង្កប់នៅក្នុងស្រែហ្នឹង ខ្ញុំត្រូវក្បាលមួយអំបែងទៀត។ ហើយអ្នកដែលសែងខ្ញុំខាង មុខគឺស្លាប់ អ្នកសែងខ្ញុំខាងក្រោយគឺបាក់ជើង ឯខ្ញុំត្រូវក្បាលមួយអំបែងទៀត។ នេះបង្ហាញថាមានគ្រាប់ មីនកប់ទៅតាមវាលស្រែមែន។ ប៉ុន្តែខ្ញុំមិនយល់ថា ខាងណាអ្នកដាក់នោះទេ ប៉ុន្តែខ្ញុំត្រូវខ្លួនឯងហើយ។ សូមជម្រាបអ៊ីចឹង។

**ស៖** អនុប្រធានរបស់លោកនុំង សុខ ឈៀន គាត់បាននិយាយថា កងទ័ពវៀតណាមដាក់បង្កប់ មីន។ អ៊ីចឹងក្រៅពីហេតុការណ៍ហ្នឹង លោកមានដឹងហេតុការណ៍ណាផ្សេង ពាក់ព័ន្ធនឹងកងពលតូចផ្សេង ស្តីអំពីការដាក់បង្កប់មីន ក្រៅពីកន្លែងដែលលោករងរបួសហ្នឹងទេ?

**ឆ៖** ខ្ញុំយល់ឃើញថា ក្នុងសង្គ្រាមមិនថា ភាគីកម្ពុជា មិនថាភាគីវៀតណាមទេ ទៅបោះទីតាំង ណា ដើម្បីការពារខ្លួនសុទ្ធសឹងតែមានគ្រាប់មីន។ យប់ឡើងគឺត្រូវតែពង្រាយគ្រាប់មីន មិនថាភាគីកម្ពុជា មិនថាភាគីវៀតណាមទេ។ កន្លែងដែលមិនស្គាល់ភូមិសាស្ត្រហ្នឹង គឺថាយប់ឡើងគឺត្រូវពង្រាយគ្រាប់មីន បីបួនគ្រាប់ ព្រឹកឡើងដោះវិញ។ នេះសូមៗជម្រាបអ៊ីចឹង។ អ៊ីចឹងបានថាសង្គ្រាមគឺអ៊ីចឹង សង្គ្រាមដើម្បី ទប់ទល់គ្នាបាន គឺថាប្រើគ្រប់ល្បិច គ្រប់វិធីទាំងអស់ គ្រាន់តែកន្លែងខ្លះគេមិននិយាយ កន្លែងខ្លះនិយាយ

ប៉ុន្តែខ្ញុំចង់បញ្ជាក់ថាសង្គ្រាមប្រើគ្រប់វិធីទាំងអស់ដើម្បីការពារអាយុជីវិតទ័ពរៀងៗខ្លួន។ សូមអរគុណ។

[១១:២០:៥៦]

**ស៖** បើនិយាយអំពីយុទ្ធសាស្ត្រទ័ពនេះ ខ្ញុំចង់ឲ្យលោកបំភ្លឺអំពីអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញ។ កាលពីម្សិលមិញ ម៉ោង១១:<៣៦>នាទី លោកបាននិយាយថាលោកបានប្រជុំជាមួយ សុន សេន នៅខាងស្វាយរៀង។ ហើយនៅរសៀលប្រហែលជាម៉ោង០១:<៤៤>នាទី លោកបាននិយាយថាលោកមិនបានជួប សុន សេន ទេ <គឺខ្ញុំស្តាប់ជាភាសាបារាំង>។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់ឲ្យបានច្បាស់ថាតើលោកមានបានប្រជុំជាមួយនឹង សុន សេន ដែរឬទេ នៅស្វាយរៀងនោះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានប្រជុំជាមួយលោក សុន សេន នៅស្វាយរៀង ណេះខ្ញុំបានបញ្ជាក់មួយកន្លែងទៀត ម្សិលមិញគឺក្រោលគោ ភូមិក្រោលគោ ហួសអ្នកលឿងបន្តិច។ ហើយទីតាំងនេះ ដែលសួរខ្ញុំជាបន្តបន្ទាប់ ក្រោលគោហ្នឹងជាទីតាំងរបស់មេបញ្ជាការ ខ្ញុំបានបញ្ជាក់ថាជាកន្លែងស្តុកភស្តុភារ ហិរញ្ញវត្ថុ គ្រាប់រំសេវ ហើយជា ក៏ជាទីតាំងចល័តរបស់ សុន សេន ពេលដែលគាត់ចល័តពីភ្នំពេញទៅគាត់ជួបថ្នាក់ដឹកនាំអី គឺនៅក្រោលគោហ្នឹងមួយភ្លែតៗទេ មិនហួសពីមួយម៉ោងទេ ហើយគាត់ចេញវិញបាត់ហើយ។ សូមជម្រាបអ៊ីចឹង។

**ស៖** លោកស្គាល់ឈ្មោះ កែ ពក ទេ?

**ឆ៖** កែ ពក ខ្ញុំឮតែឈ្មោះ ប៉ុន្តែខ្ញុំអត់ដែលបានជួប ពីព្រោះគាត់នៅខាងៗព្លៃសានៗ។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីផ្តល់ជូនទំព័រទី១នៃសាក្សី 2-TCW-942 គាត់នឹងមកផ្តល់សក្ខីកម្ម អ៊ីចឹងហើយបានជាខ្ញុំមិនអាចផ្តល់ឈ្មោះគាត់ជាសាធារណៈបាន។ អ៊ីចឹងសូមការអនុញ្ញាតពីលោកប្រធានប្រគល់ជូនទំព័រទី១នៃឯកសារនេះ ដើម្បីឲ្យគាត់មើល ថាតើគាត់ស្គាល់បុគ្គលរូបនោះ ឬក៏អត់។ ហើយខ្ញុំនឹងអានឃ្លាមួយនៃចម្លើយរបស់គាត់ ដើម្បីឲ្យសាក្សីរូបនេះផ្តល់យោបល់។ លោកប្រធាន គឺជាឯកសាររបស់សាក្សី 2-TCW-942 គឺឯកសារ E3/426, ERN ជាភាសាបារាំង 00 -- លោកប្រធាន សូមមេត្តាប្រគល់ឯកសារនេះជូនទៅលោកសាក្សី។

[១១:២៣:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** ក្នុងពេលដែលមន្ត្រីតុលាការយកឯកសារជូនលោក ខ្ញុំសូមផ្តល់ ERN ជាភាសាបារាំង គឺ 00403068, ERN ជាភាសាអង់គ្លេស 00364071, ជាភាសាខ្មែរគឺ 00357492។ លោកសាក្សី ខ្ញុំគ្រាន់តែចង់ឲ្យលោកមើលឈ្មោះដែលខ្ញុំគូសពណ៌ទឹកក្រូចហ្នឹង លោកមើលឈ្មោះគាត់ទៅ ហើយលោកស្គាល់គាត់ទេ? ហើយកុំប្រាប់ឈ្មោះគាត់ជាសាធារណៈ យើងប្រើតែរហស្សនាមគាត់ទេ។ នៅមន្ទីរភស្តុភារ ហិរញ្ញវត្ថុនៅស្វាយរៀងហ្នឹង លោកធ្លាប់ឃើញគាត់ទេ?

**លោក អៀង ផាន៖**

**ផ៖** ខ្ញុំសូមបញ្ជាក់ថាស្គាល់ ហើយក៏ធ្លាប់ឃើញ។

**ស៖** លោកឃើញគាត់ ពេលលោកនៅស្វាយរៀង នៅពាក់កណ្តាលឆ្នាំ៧៨ ហើយក្រោយមកដែលគេបញ្ជូនលោកមកភ្នំពេញហ្នឹង <ក្រោយពេលដែលលោកទទួលរងរបួសហ្នឹង>មែនទេ?

**ផ៖** ខ្ញុំស្គាល់គាត់ក្រោយ៧៨ហើយ។

[១១:២៥:២៩]

**ស៖** អ៊ីចឹងមានន័យថា លោកអត់ឃើញគាត់ទេ នៅស្វាយរៀងទេ មែនទេ?

**ផ៖** នៅស្វាយរៀង ខ្ញុំអត់ដែលជួបទេ ប៉ុន្តែក្រោយពី៧៩មក គឺខ្ញុំធ្លាប់ជួបគាត់។ ហើយរាល់ថ្ងៃហ្នឹងក៏ស្គាល់គាត់ ស្គាល់ទាំងផ្ទះ ស្គាល់ទាំងសម្លេងអីទាំងអស់។

**ស៖** ខ្ញុំសូមអានឃ្លាមួយដែលគាត់និយាយអំពី កែ ពក ប្រហែលជាពេលនុ៎ង វាខុសពីពេលដែលលោកនៅស្វាយរៀង ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំចង់ឲ្យលោកពិនិត្យមើលចំណុចនេះ។ គាត់និយាយអំពីពេលដែលគាត់នៅស្វាយរៀង៖ "បន្ទាប់មក សុន សេន បានឲ្យខ្ញុំកាន់ខាងវិទ្យុទាក់ទង និង <មន្ទីរ>ភស្តុភារ <នៅស្វាយរៀង> នៅចុងឆ្នាំ<១៩៧៧>។ នៅឆ្នាំ<១៩៧៨> សុន សេន ដកពីស្វាយរៀងទៅមន្ទីរ<សួង នៅពេលដែលមានព្រឹត្តិការណ៍បូព៌ា នៅពេលដែលវៀតណាមចូលមក> ដើម្បីរៀបចំភូមិភាគបូព៌ា <និងគ្រប់គ្រងការងារសមរភូមិបូព៌ាប៉ែកខាងជើងទៀត>។ សុន សេន គាត់មានមុខងារពីរ គឺនៅស្វាយរៀងផង នៅសួងផង។ ប្រធានខាងមេបញ្ជាការនៅខាងបូព៌ា ហើយនិង <គ្រប់គ្រងកងពលដែលប្រចាំការនៅបូព៌ា> គឺត្រូវកាន់ដោយ កែ ពក និង សុន សេន។"

ក្នុងឃ្លានេះគាត់មិនបានបញ្ជាក់ថា<ពេលណានៅ>ក្នុងឆ្នាំ៧៨ហ្នឹង<>ទេ <> ប៉ុន្តែគាត់បានបញ្ជាក់ថា សុន សេន និង កែ ពក ហ្នឹងជាមេបញ្ជាការប្រតិបត្តិការសឹកភូមិភាគបូព៌ា គឺគ្រប់គ្រងកង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពលដែលប្រចាំការនៅបូព៌ា។ អ៊ីចឹងខ្ញុំចង់ដឹងថា <នៅមុន>ពេលដែលលោក<មកដល់>ស្វាយរៀង ហ្នឹង តើលោកដឹងថា កែ ពក ហ្នឹងគាត់មានជាប់ពាក់ព័ន្ធនឹងការបញ្ជាទ័ពនៅបូព៌ាទេ?

[១១:២៧:៤០]

**ឆ៖** ខ្ញុំសូមជម្រាបថា នៅខាងបូព៌ានេះ ខ្ញុំដឹងតែលោក សុន សេន ឯលោក កែ ពក ដែលខ្ញុំដឹង តាមការប្រជុំអី គឺគាត់ទទួលខាងភូមិភាគព្រៃលិចឡើងទៅ... 

**កញ្ញា អង់តា ហ្គីសសេ៖**

ដំណើរការសវនាការ។ ហើយនៅរសៀលនេះ អង្គជំនុំជម្រះនឹងផ្ដើមធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-1065។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣០នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី 2-TCW-1065។ ហើយសាក្សីរូបនេះ គឺជានឹងផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុជម្លោះប្រដាប់អាវុធ។

មុននឹងស្ដាប់សក្ខីកម្មសាក្សី 2-TCW-1065 អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សីរូបនេះត្រូវបានស្ដាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់សាក្សីរូបនេះឋិតនៅក្នុងក្រុម "ក" នៃក្រុមទាំងបីប្រភេទនៅក្នុងអនុស្សរណៈរបស់ខ្លួន (សូមមើលឯកសារ E319/35)។ ហើយបានស្នើថា សាក្សីរូបនេះគួរប្រើរហស្សនាម ក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះយល់ឃើញថា វិធានដែលបានកម្រិតបែបនេះ គឺត្រឹមត្រូវសមស្របតាមច្បាប់នៅក្នុងករណីបែបនេះ។ ហើយការបង្គាប់នេះ គឺត្រូវធ្វើឲ្យមានតុល្យភាពគ្នារវាងតម្រូវការនៃសាធារណភាពនៃសវនាការ ជាមួយនឹងការការពារសុចរិតភាពនៃការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់ភាគីផងដែរថា សូមឲ្យគោរពឲ្យបានខ្ជាប់ខ្ជួននូវសេចក្ដីណែនាំក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញពីសំណុំរឿងផ្សេង។

ហើយមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 2-TCW-1065 រួមទាំងមេធាវីប្រឹក្សាសាក្សីគឺ

លោក ចាន់ សម្បូរ ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:៣៥:៣០]

**ប្រធានអង្គជំនុំ៖**

ស្ួស្តីលោកសាក្សី។ នៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ តាមសំណើសុំរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺយើងនឹងប្រើប្រាស់តែរហស្សនាមរបស់លោកតែប៉ុណ្ណោះ ហើយរហស្សនាមលោកគឺ 2-TCW-1065។ ភាគីនិងអង្គជំនុំជម្រះជាទូទៅ គឺតែងតែហៅលោកថាជាសាក្សីតែប៉ុណ្ណោះ។ ហើយអ៊ីចឹងសុំលោកយល់ថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធ រួមទាំងអង្គជំនុំជម្រះខ្លួនមិនប្រើនាមត្រកូល និងនាមខ្លួនលោកជាសាធារណៈនៅក្នុងដំណើរការសវនាការនេះទេ។

ហើយមន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារ E3/10667 យកទៅជូនសាក្សីពិនិត្យ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកសាក្សី តទៅនេះអង្គជំនុំជម្រះសុំឲ្យលោកបញ្ជាក់អំពីអត្តសញ្ញាណរបស់លោកដែលមាននៅក្នុងឯកសារ E3/10667 ដែលមានលេខ ERN ជាភាសាខ្មែរ00808426, ERN ជាភាសាអង់គ្លេស 00976848 និងERN ជាភាសាបារាំង 01001361។ សុំលោកសាក្សីពិនិត្យមើលកន្លែងដែលមាន *ហាយឡាយ*ពណ៌ទឹកក្រូច ថាតើឈ្មោះរបស់លោក ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត សញ្ជាតិ មុខរបរ ឈ្មោះឪពុក ឈ្មោះម្តាយ ទីលំនៅបច្ចុប្បន្ន ឈ្មោះប្រពន្ធរបស់លោក និងចំនួនកូនរបស់លោកពិតជាត្រឹមត្រូវដែរឬទេ? ហើយសុំបញ្ជាក់ថា លោកសាក្សីគ្រាន់តែឆ្លើយថា ការសរសេរនេះពិតជាត្រឹមត្រូវ ឬមិនត្រឹមត្រូវត្រង់ចំណុចណាបានហើយ។ ហើយលោកសាក្សីពិនិត្យមើលរួចហើយនូវ ថាតើលោកព័ត៌មានដែលនៅក្នុងឯកសារដែលមាន *ហាយឡាយ*ពណ៌ទឹកក្រូចដែលឲ្យលោកពិនិត្យមើល ត្រឹមត្រូវដែរឬទេ?

[១៣:៣៨:០៨]

**2-TCW-1065៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ចំពោះឯកសារដែលមានពណ៌ទឹកក្រូចនោះ គឺបានសរសេរក្នុងនេះពិតជាត្រឹមត្រូវ។

**ស៖** បាទអរគុណលោកសាក្សី។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញ ថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន និងបុគ្គលទាំងឡាយ ដែលបានទទួលយកជាភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះទេ។ តើពិតដែរទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កុំអាលទាន់! កុំអាលទាន់!

**ឆ៖** ចំពោះខ្ញុំវិញ អត់មានពាក់ព័ន្ធចំពោះអ្នកទោសណាទេ អត់មាន។

**ស៖** មិនមែនជាអ្នកទោសទេ លោកសាក្សី គឺជានេះជនជាប់ចោទណ៎ា គឺជនជាប់ចោទ នៅចោទប្រកាន់នៅឡើយទេ អ៊ីចឹងគាត់មិនទាន់មានទោសពៃរ៍អ្វីទេ គឺលោក នួន ជា និងលោក ខៀវ សំផន ណ៎ា។ ហើយតើលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយឬនៅ មុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** ចំពោះខ្ញុំ គឺបានធ្វើសម្បថចំពោះមុខអ្នកតាដំបងរួចទៅហើយ។

[១៣:៣៩:៣៦]

**ស៖** បាទ អរគុណលោកសាក្សី។ តទៅនេះយើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចរបស់លោកក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏សុំឱ្យលោកធ្វើអត្ថាធិប្បាយរៀបរាប់ដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងការឋានៈលោកជាសាក្សី ត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរដែលនាំឱ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយណាដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរបស់លោករួចហើយអម្បាញ់មិញនេះ។

ហើយក្នុងឋានៈជាសាក្សីត្រូវតែឆ្លើយឱ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោកសាក្សី តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ប្រសិនបើធ្វើ ៗប៉ុន្មានដង? ធ្វើនៅទីកន្លែងណា?

[១៣:៤០:៥៦]

**ឆ៖** ចំពោះរូបខ្ញុំបាន១ធ្វើស៊ើបអង្កេតជាមួយ បានម្ដងនៅឆ្នាំ២០១២ បានម្ដងនៅ១ភូមិជីកែ ឃុំវិហារលួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ពេលនុ៎ង។ ហ្នឹងបានតែម្ដងទេណ៎ា។

**ស៖** បាទ អរគុណ។ ហើយលោកសាក្សី តើលោកធ្លាប់បាន -- មុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យ បានអាន ឬក៏នូវកំណត់ហេតុដែលលោកបានផ្ដល់សក្ខីកម្មកាលពីពេលមុននៅនឹងភូមិ នៅលំនៅដ្ឋានរបស់លោកចំពោះអ្នកស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** ចំពោះរូបខ្ញុំគឺខ្ញុំបានអានហើយ ចំពោះកំណត់ហេតុដែលបានធ្វើ ខ្ញុំអាន បានអាន បានមើលចប់សព្វគ្រប់ហើយ។

**ស៖** បាទ អរគុណ។ តាមសមត្ថភាពដែលលោកអាចដឹងនិងចងចាំបាន តើលោកអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុដែលស្ដាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនោះ គឺវាមានខ្លឹមសារពិតជាត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នាទៅនឹងសក្ខីកម្មដែលលោកផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែរឬទេ?

**ឆ៖** ចំពោះកំណត់ហេតុដែលបានធ្វើស៊ើបអង្កេតកន្លងមក គឺពិតជាត្រឹមត្រូវហើយ ខ្ញុំអាន ព្រោះយើងបានអាន ហើយបានស្ដាប់ ឃើញថាត្រឹមត្រូវ។

[១៣:៤២:៤១]

**ស៖** បាទ អរគុណ។ ហើយលោកសាក្សី នាពេលនេះលោកបានទទួលជំនួយមេធាវីប្រឹក្សាដែលអង្គជំនុំជម្រះផ្ដល់ឲ្យតាមរយៈអង្គភាពគាំពារសាក្សី អ្នកជំនាញ តាមសំណើរបស់លោកហើយ គឺលោកមេធាវី ចាន់ សម្បូរ។ លោកអាចទុកឯកសារនុ៎ងចុះ។ ហើយតទៅនេះ យើងមានសំណួរមួយចំនួនសួរចំពោះលោក ពាក់ព័ន្ធជាមួយនឹងរឿងហេតុទាំងឡាយដែលកើតមានឡើង ដែលទំនងជាលោកអាចដឹង។ ទី១ គឺយើងសួរថា តើលោកអាចប្រាប់យើងបានដែរទេថា តើលោកចូលបដិវត្តន៍នៅថ្ងៃខែឆ្នាំណាដែរ? លោកចាំដែរទេ? ពីពេលណាមក?

**ឆ៖** ឥឡូវខ្ញុំសូមឆ្លើយ ថ្ងៃដែលចូល ខ្ញុំដែលខ្ញុំចូលបដិវត្តន៍ហ្នឹងគឺនៅឆ្នាំ១៩៧០ នៅថ្ងៃ២៩ ខែ – ២៩ ខែ៣ ៧០ នៅខេត្តស្វាយរៀង។ ពេលនុ៎ងគឺចូលដោយសារអី? គឺចូលដោយសារព្រះមហាក្សត្រខ្មែរហ្នឹង សម្ដេចតាហ្នឹង "កូនចៅអើយចូលព្រៃម៉ាគី"។ រឿងហ្នឹងហើយដែលខ្ញុំដែលចូលហ្នឹង។ ចូលព្រៃម៉ាគី អាហ្នឹងដែលចូលហ្នឹងតាំងពីថ្ងៃនុ៎ង ខែនុ៎ងមក ឆ្នាំ៧០។

**ស៖** ហើយការចូលធ្វើបដិវត្តន៍ដំបូង តើលោកធ្វើអីដែរ? គេឲ្យធ្វើអីដែរ? លោកធ្វើជាកងទ័ព ឬក៏លោកធ្វើជាខាងបុគ្គលិកស៊ីវិល។

**ឆ៖** ខ្ញុំចូលដំបូងនៅឆ្នាំ៧០ហ្នឹង ខ្ញុំធ្វើជាកងទ័ពទេចូលហ្នឹង ខ្ញុំចូលជាកងទ័ពមួយឆ្នាំ ឆ្នាំ៧០។

**ស៖** ហើយនៅអង្គភាពណាដែរ កាលលោកចូលធ្វើដំបូង?

**ឆ៖** កាលខ្ញុំចូលមុនដំបូងហ្នឹង ព្រោះនៅខេត្តស្វាយរៀងហ្នឹង គេហៅថាស្រុកសំរោង ស្រុកហ្នឹង ប៉ុន្តែឥឡូវវាអត់មានឈ្មោះស្រុកសំរោងទេ។ ស្រុកសំរោងគឺខេត្តស្វាយរៀង គឺចូលហ្នឹង។

[១៣:៤៥:១២]

**ស៖** អ៊ីចឹងបានន័យថាលោកចូលធ្វើហ្នឹង ធ្វើកងទ័ពស្រុក មែនទេ?

**ឆ៖** គឺខ្ញុំធ្វើកងទ័ពស្រុក គឺត្រឹមត្រូវ។

**ស៖** អរគុណ។ ដើម្បីពន្លឿនកិច្ចដំណើរការនេះ យើងសូមឲ្យលោករៀបរាប់អំពីសកម្មភាពការងាររបស់លោកដែលចាប់ពីលោកចូលធ្វើការទ័ពខែ៣ ឆ្នាំ១៩៧០ រហូតដល់១៧ មេសា ឆ្នាំ១៩៧៥ តើលោកបានធ្វើអ្វីខ្លះនៅក្នុងអង្គភាពណាខ្លះដែលលោកចងចាំ លោកអាចរៀបរាប់បានទេ?

**ឆ៖** ខ្ញុំសូមរៀបរាប់ជូនសាលាក្ដីខ្មែរក្រហមឲ្យបានជ្រាបថា ខ្ញុំនិយាយអំពីឆ្នាំ៧០។ ខ្ញុំធ្វើទាហានបានមួយឆ្នាំ ក្រោយមកក៏ខ្ញុំបានទៅរៀនពេទ្យ។ រៀនពេទ្យ នៅធ្វើពេទ្យហ្នឹងចាប់ពីឆ្នាំ៧១មករហូតដល់៧៦ គឺខ្ញុំធ្វើពេទ្យរហូត។ ប៉ុន្តែពេទ្យហ្នឹងគឺពេទ្យយោធាទេ គឺពេទ្យនៅសមរភូមិ មិនមែនពេទ្យនៅស្រុកទេ គឺចុះជាប់សមរភូមិនោះពេទ្យនោះ។ អាហ្នឹងបើ៧៦តែម្ដង ធ្វើពេទ្យរហូត។

**ស៖** លោកចាំដែរ លោកធ្វើពេទ្យនៅក្នុងកងទ័ពនោះ នៅក្នុងអង្គភាពណាដែរនៃកងទ័ព?

**ឆ៖** កាលខ្ញុំធ្វើពេទ្យហ្នឹងចាប់ពីឆ្នាំ៧១មករហូតដល់៧៥។ ៧៥ហ្នឹងខ្ញុំនៅពេទ្យស្រុក។ ចាប់ពីវ៉ៃបែកភ្នំពេញហើយ គឺខ្ញុំមកធ្វើពេទ្យនៅៗពេទ្យនៅភូមិភាគ ៗបូព៌ានេះ។ ធ្វើពេទ្យហ្នឹង ធ្វើប្រធានពេទ្យហ្នឹងនៅលេខ១៥៦ នៅកងពលលេខ៤ ហ្នឹងធ្វើពេទ្យ នៅឆ្នាំ៧៦ រហូតដល់៧៧ ចុង៧៧នេះ នៅភូមិភាគ។

01377121



[១៣:៤៧:៣៤]

**ស៖** បាទ អរគុណ។ ហើយបន្ថែមពីលើមុខងាររបស់លោកក្រោយ ដែលបានធ្វើពេទ្យដែលលោករៀបរាប់អំមិញនេះគឺហូរហែមក ហើយរហូតដល់ក្រោយឆ្នាំ១៩៧៥ ក្រោយថ្ងៃ១៧ មេសា ៧៥ លោកនៅបន្តធ្វើពេទ្យទៀត ប៉ុន្តែលោកធ្វើនៅពេទ្យភូមិភាគ ហើយនៅក្នុងអង្គភាព ង-១៥៦។ ហើយសំណួរសួរថាក្រៅពីពេទ្យហ្នឹង ឥឡូវលោកអាចរៀបរាប់ឱ្យអស់លម្អិតបានដែរទេអំពីមុខងារ និងតួនាទីរបស់លោកក្រោយឆ្នាំ១៩០០ -- ចាប់ពីឆ្នាំ១៩៧៦មក រហូតដល់ឆ្នាំ១៩៧៩ តើវាមានការផ្លាស់ប្ដូរប្រែប្រួលយ៉ាងណាខ្លះ អំពីការធ្វើការងាររបស់លោកនៅក្នុងសម័យបដិវត្តនៅជំនាន់នុ៎ង គឺសម័យកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ខ្ញុំសូមជម្រាបជូនបន្តទៀត។ ឥឡូវយើងខ្ញុំនិយាយអំពី៧៦ ខ្ញុំនៅជាប្រធានពេទ្យ។ ដល់ចូលមក៧៧ គឺចុង៧៧ហ្នឹង ខែ១២ហ្នឹង កម្ពុជា និងហើយវៀតណាមចាប់ផ្ដើមជាសត្រូវគ្នា ក៏ចាប់ផ្ដើមឈ្លោះគ្នាហើយ។ ហើយខ្ញុំពេទ្យ ៗគឺនៅសមរភូមិមុខផ្ទាល់ហ្នឹង នៅៗនឹងមុខគេហ្នឹង។ អ៊ីចឹងចាប់ផ្ដើមប្រទូសរ៉ាយគ្នា ឈ្លោះប្រកែកគ្នា ក៏ចាប់ផ្ដើមបើកយុទ្ធនាការប្រយុទ្ធគ្នា។ ខែ១២ ឆ្នាំ៧៧ យើងប្រយុទ្ធគ្នាហ្នឹងរហូតមកដល់ ចាប់ពីនោះមកដល់ឆ្នាំ ខ្ញុំនិយាយដោយខ្លីៗចុះ និយាយដល់២៥ ខែ៥ ៧៨ ពេលហ្នឹង ប៉ុល ពត បានធ្វើរដ្ឋប្រហារនៅកម្ពុជា ដល់ធ្វើរដ្ឋប្រហារកម្ពុជាហ្នឹង កាប់សម្លាប់កម្មាភិបាលយុទ្ធជន ប្រជាពលរដ្ឋហ្នឹង ក៏ហៅអង្គភាពខ្ញុំហ្នឹង។ និយាយរួមមួយកងពលលេខ៤ហ្នឹង ចាប់ពីប្រធានកងពលរហូតដល់ប្រធានកងវរសេនាធំ កងអនុសេនាធំ ហៅមកប្រជុំទាំងអស់ មកប្រជុំកន្លែងកងពលភូមិភាគកណ្ដាល។ ពេលដល់មកប្រជុំហ្នឹងហើយ រឿងខ្ញុំមួយដែលខ្ញុំមិនមក មូលហេតុអី ព្រោះខ្ញុំអត់មក ព្រោះខ្ញុំកាលណាមកអស់គ្នាហើយ មួយកងពលមកអស់ហើយ ខ្ញុំនៅប្រចាំសមរភូមិ សមរភូមិមុខកំពុងតែប្រយុទ្ធគ្នាជាមួយវៀតណាម ខ្ញុំមកប្រចាំហ្នឹង គឺខ្ញុំនៅប្រចាំ ក្រៅពីហ្នឹងមកទាំងអស់។

[១៣:៥០:១៤]

ដល់មកប្រជុំហ្នឹង ប្រហែលជាម៉ោងបីល្ងាច នៅកន្លែងកងពលលេខ៤នេះ ក៏វាចាប់ផ្ដើមចាប់កម្មាភិបាលទាំងអស់។ ចាប់បានអស់រលីង ចាប់យកដាក់ឡាន ចាប់យកទៅ នៅដល់ម្នាក់។ ម្នាក់ហ្នឹងវាបណ្ដើរទៅហើយ ទៅដល់អណ្ដូងមួយ វាឱ្យអង្គុយ ប៉ុន្តែវាៗបិទមុខក្រមារួចហើយ។ ដល់អង្គុយទៅយកដៃបួតក្រមា ឃើញអណ្ដូងខាងមុខ។ ដល់ឃើញអណ្ដូងអ៊ីចឹង លោតផ្លោះអណ្ដូងរួច វាបាញ់ពីក្រោយត្រូវដៃ ត្រូវរបួសដៃនេះ។ ដល់ត្រូវរបួសដៃហ្នឹង រត់ទៅដល់ខ្ញុំនៅសមរភូមិ។ គាត់ថា "បង ឥឡូវ

ហ្នឹង ពួកខាងភូមិភាគកណ្ដាលហ្នឹង ពួកកែ ពក ហ្នឹងវាសម្លាប់កម្មាភិបាលយុទ្ធជនអស់ហើយ ឥឡូវអ្នកដែលទៅហ្នឹង គឺចាប់ទាំងអស់។ អ៊ីចឹងខ្ញុំដឹងរឿងពិត ខ្ញុំដឹងរឿងពិត រឿងថា ដល់បាញ់របួសដៃអ៊ីចឹងហើយ ខ្ញុំថា អំបើអ៊ីចឹង ប៉ុល ពត ក្បត់ហើយ។ ដល់ក្បត់អ៊ីចឹងហើយ ម៉ោងប្រាំល្ងាច ខ្ញុំក៏ហៅសេនាធិការគ្រប់កងវរសេនាតូច ក្នុង ង-១៥៦ ហ្នឹង មកប្រជុំ។ ថាឥឡូវយើងមានវិធីយ៉ាងម៉េច ដោះស្រាយយ៉ាងម៉េច បើ ប៉ុល ពត សម្លាប់កម្មាភិបាល ប្រជាជន គ្រប់ក្រសួងមន្ទីរ វាសម្លាប់ហើយ។ ឥឡូវយើងគិតយ៉ាងម៉េច? ជិតយប់ហើយ។ អ៊ីចឹងមួយចំនួន គេថាឥឡូវបើយើងវាយ តើយើងទៅណា។ ខ្ញុំសម្រេចចិត្តខ្លួនឯងថា រឿងទៅណា មិនទៅណា យើងកុំអាលគិត ឥឡូវគិតវាយមកមួយរស់សិន។ អ៊ីចឹងមួយចំនួន ក៏វិលទៅផ្ទះសម្បែងវិញ។ ខ្ញុំនឹកឃើញសភាពការណ៍អ៊ីចឹង ខ្ញុំក៏ចាប់ផ្ដើមកងទ័ពនៅខ្សែត្រៀមខាងមុខ កំពុងវាយវៀតណាម ខ្ញុំដកៗមកបាន៣០០នាក់។ បាន៣០០ ឆ្លងកាត់ផ្លូវជាតិលេខ៧ហ្នឹង ឡើងមកចូលព្រៃអាងុយនេះ។ ចូលមកហ្នឹងរៀបចំទ័ព ដើម្បីបើកយុទ្ធនាការវាយ ប៉ុល ពត វិញ។ ចាប់ពីឆ្នាំ៧៨មកវិញ ខ្ញុំចាប់ផ្ដើមវាយ ប៉ុល ពត។

[១៣:៥២:១៨]

ហើយពេលនោះហ្នឹង មិនមែនវាយតែ ប៉ុល ពត ទេ ព្រោះយើងសត្រូវវៀតណាមផង ខាងក្រោយសត្រូវ ប៉ុល ពត ទៀត អ៊ីចឹងវាយទាំងពីរ។ ប៉ះវៀតណាម វាយវៀតណាម ប៉ះ ប៉ុល ពត វាយ ប៉ុល ពត ចំណោះខ្លួនខ្ញុំមួយ គឺតស៊ូ។ ហើយពេលដែលទៅនុ៎ង អត់មានស្អីទេ កងទ័ពចេញពីសមរភូមិតែអង្រឹងគ្មានទេ មានអាវុធគត់។ ស្បៀងអាហារក៏អត់ ចេញចូលព្រៃទៅតស៊ូហ្នឹង។ អំបិលក៏អត់មាន ខ្ញុំក៏យកឲ្យបងប្អូនរកបានសហករណ៍ចែកគ្នា ម្នាក់បួនដប់គ្រាប់ៗ យើងចាប់ផ្ដើមធ្វើបដិវត្តន៍តស៊ូ។ បើយើងមិនៗតស៊ូ យើងមិនរស់ គឺយើងស្លាប់។ តែបើយើងតស៊ូ យើងបានរស់ យើងបានរស់ហើយ យើងដោះប្រជាពលរដ្ឋដែលវាកាប់សម្លាប់រួចទៀត។ អ៊ីចឹងខ្ញុំចាប់ផ្ដើមបើកយុទ្ធនាការប្រយុទ្ធតែម្ដង។ មួយថ្ងៃ ខ្ញុំវាយទីតាំង ប៉ុល ពត មានពីរកន្លែងក៏មានដែរ។ ដើម្បីអី? វាយយកអង្ករ វាយយកថ្នាំពេទ្យ វាយយកគ្រាប់រំសេវ។ ហើយចំពោះទ័ព ប៉ុល ពត វាមានៗវិបត្តិពីរ ទី១ខាងមុខ នៅវៀតណាម ដែលកំពុងប្រយុទ្ធនេះ ឯនៅខាងក្រោយ គឺខ្ញុំ តស៊ូ។ ហើយខ្ញុំហ្នឹងវាយទាំងពីរ វៀតណាមក៏ខ្ញុំវាយ ប៉ុល ពត ក៏វាយ វាជាសត្រូវទាំងអស់។ យើងអត់ទាន់ដឹង អាណាមិត្ត ណាសត្រូវ។

យើងបើកយុទ្ធនាការការប្រយុទ្ធគ្នា ប្រយុទ្ធរហូត បានៗអង្រឹង បានគ្រាប់រំសេវ បានអី។ ខ្ញុំនិយាយដោយខ្លីៗ យើងបន្តពីនោះ តស៊ូវាយរហូត ចាប់ពីៗស្នួលទៅរហូតដល់មេមត់ ជាសមរភូមិរបស់

ខ្ញុំ នៅខាងជើងផ្លូវ។ គ្មាននរណាទេ មានតែខ្ញុំមួយទេដែលមានទ័ពប្រយុទ្ធជាមួយ ប៉ុល ពត។ ខ្ញុំតរហូតៗ ដល់ឆ្នាំ៧៨ ខែ១១០ ខ្ញុំនៅនឹងព្រៃហ្នឹង ខ្ញុំចល័តរហូត។ ដល់ពេលនុ៎ង បោះនៅហ្នឹង ខាងស៊ើបការណ៍ខ្ញុំ ខ្ញុំរៀបស៊ើបការណ៍៤០នាក់ ស៊ើបការណ៍ហ្នឹង។ គ្រាន់ដាក់កំប្រោងនៅនឹងព្រៃហ្នឹង ចល័ត៣ថ្ងៃ ចល័តពីកន្លែងនេះទៅកន្លែងនេះ កន្លែងនេះទៅកន្លែងនេះ ដាក់កំប្រោងហ្នឹង មានត្រឡាច មានអីនៅហ្នឹង។

[១៣:៥៤:៣៨]

ដល់នៅទៅ ស្រាប់ឃើញសំបុត្រមួយ សរសេរជាៗប៊ិកក្រហម សរសេរថា "សុំទាក់ទង សុំទាក់ទង"។ ហើយអ៊ីចឹងខ្ញុំប្រើស៊ើបការណ៍ខ្ញុំថា ចុះរឿងអី អ្នកណាដែលមកសុំទាក់ទងយើងនៅក្នុងព្រៃ។ ខ្ញុំសួរអ្នកណាដែលសួរ មកសុំទាក់ទងអ៊ីចឹង។ គេថា ថ្ងៃស្អែកនឹងសុំមកជួប។ អ៊ីចឹងខ្ញុំក៏ឲ្យស៊ើបការណ៍១០នាក់ទៅព័ទ្ធចាំកន្លែងនុ៎ង ចាំមើលមើល! អ្នកណាដែលមកសូមទាក់ទងយើងហ្នឹង។ ដល់ពេលនុ៎ងយើងនៅចាំហ្នឹង នៅពួនចាំមើល អ្នកណាដែលសុំមកជួបហ្នឹង។ ចាំមើលឃើញកងស៊ើបការណ៍វៀតណាមហ្នឹងដែលមានលាយខ្មែរ។ សូម រត់មកឱប ថាសូមទាក់ទង សូមទាក់ទង។ បានបងប្អូនស៊ើបការណ៍មករាយការណ៍ឲ្យខ្ញុំ ខ្ញុំក៏មិនទាន់ជឿដែរ ព្រោះជាសត្រូវចំពោះមុខ យើងមិនទាន់ចាត់ទុកថាអ្នកឯងត្រឹមត្រូវទេ។ អ៊ីចឹងក៏មកពិភាក្សា១២នាក់ហ្នឹង ពិភាក្សាគ្នាសាចុះសាឡើង សាចុះសាឡើងទៅបានវៀតណាមគេបញ្ជូន បញ្ជូនបក្ខជនគេនោះ មកពិភាក្សានៅភូមិ នៅភូមិកន្ទួត ភូមិកន្ទួតហ្នឹង ហ្នឹងដល់ខែ១១ហើយ។ ប្រជុំពិភាក្សាគ្នាហ្នឹងរហូតហើយ គេថាអញ្ជើញខ្ញុំហ្នឹងដើម្បីទៅវៀតណាមទៅយកគ្រាប់រំសេវ។ ឯយើងក៏ខ្សោយដែរ វាខ្សោយទៅហើយ ខ្ញុំក៏យកកងទ័ពខ្ញុំ៦០នាក់ទៅជាមួយខ្ញុំ ទៅយកសម្ភារៈដែលវៀតណាមគេឲ្យហ្នឹង។ ដល់យកបានគ្រាប់រំសេវហ្នឹងហើយ យកមកក៏ចាប់ផ្ដើមបើកយុទ្ធនាការ។

[១៣:៥៦:២៤]

យើងសហការជាមួយវៀតណាមហើយ ដើម្បីយកប្រជាពលរដ្ឋដែលរស់នៅរាប់ពាន់នាក់ក្នុងព្រៃហ្នឹង យកចេញមកៗខាងវៀតណាមហ្នឹង ខ្ញុំក៏ដាក់ខ្សែត្រៀមសងខាង ហើយឲ្យប្រជាពលរដ្ឋហ្នឹងដើរចំកណ្ដាល ដើម្បីចេញទៅរៀបចំរណសិរ្ស។ ដល់ខ្ញុំដាក់ទៅ ដាក់តាមនុ៎ង ប៉ុន្តែប្រជាជនខ្លះចេញខាងក្រៅ ខាងក្រៅដល់ឃើញពួកៗខ្មែរក្រហមវាចាប់ផ្ដើមបាញ់តែម្ដង។ ដល់បាញ់ពេលអាហ្នឹង បែកបាក់គ្នា។ ហើយខ្ញុំឆ្លងទៅដល់ខ្នងក្រពើហើយ ខ្ញុំទៅ ព្រោះខាងម្ខាងខ្សែត្រៀមវៀតណាម ម្ខាងត្រូវខ្ញុំ។ ឲ្យបងប្អូនប្រជាពលរដ្ឋហ្នឹងគឺដើរកណ្ដាល ប៉ុន្តែដល់ពេលដល់វាបែកបាក់គ្នាអ៊ីចឹង វាទៅពេញព្រៃតែម្ដង។ ទៅដល់វៀតណាម មិនទាន់ដល់វៀតណាមទេ ដល់មេមត់ ខ្នងក្រពើហ្នឹង ទៅដល់ត្រង់ហ្នឹងខ្ញុំចាប់ផ្ដើម

គ្រុន ហើយចេញពីសមរភូមិមកខ្ញុំគ្រុន។ ដល់គ្រុនអ៊ីចឹង ស្រាប់បក្ខជនវៀតណាមហ្នឹង ក្នុងភូមិភាគទី៧ ហ្នឹង គេថាសូមអញ្ជើញលោកដើម្បីទៅរៀបចំរណសិរ្ស។ ខ្ញុំថាខ្ញុំអត់ទេ ព្រោះសមរភូមិនៅគ្មាននរណាគ្រប់គ្រង។ គេថាសូមអញ្ជើញទៅ ទៅរៀបចំរណសិរ្ស ខ្ញុំថាទៅអត់កើតទេគ្រុន។ គេថាអញ្ជើញទៅ អត់អីទេ យន្តហោះគេចុះមកយក។ ម៉ោងមួយ! ម៉ោងមួយរសៀល ឧទ្ធម្ភាគចក្រមកចុះនឹងព្រៃមកដឹកខ្ញុំ។ ពេលហ្នឹងខ្ញុំដើរអត់រួចទេ គេដាក់ប្រង់កាហ្នឹង ឲ្យដេកលើប្រង់កាហ្នឹង វៀតណាមគេសែងលើ ដាក់លើឧទ្ធម្ភាគចក្រ។ សែងដល់ទីក្រុងហូជីមិញ ជិះកប៉ាល់ហោះរហូតដល់ទីក្រុងហូជីមិញ។ ទៅដល់ហ្នឹងប្រហែលជាម៉ោងប្រាំ ចុះដល់។ ខ្ញុំនៅដេកលើនុ៎ង គ្រុនផងអីផង នៅនុ៎ង។

[១៣:៥៨:១៧]

ទៅដល់នុ៎ង ក៏សម្រាកប្រហែលជាមួយអាទិត្យ នៅទីក្រុងហូជីមិញហ្នឹង។ សម្រាកពីហ្នឹងហើយ គេសម្រេចទាំងអស់ទាំងខ្មែរទាំងវៀតណាមហ្នឹង គេផ្លាស់ប្តូរការងាររបស់ខ្ញុំ ចេញពីបញ្ជាការកងទ័ពឲ្យទៅជាខាងគណៈទាក់ទងកម្ពុជា-វៀតណាម។ ខាងខ្ញុំហ្នឹងគឺខាងកម្ពុជា ខ្ញុំហ្នឹង ឯវៀតណាមហ្នឹងគេស័ក្តិ៥ ឈ្មោះ តាជុង ហ្នឹងគាត់ខាងវៀតណាម គណៈទាក់ទង។ កិច្ចការងារកម្ពុជាទាំងឡាយទាំងពួងទាល់តែមកជួបខ្ញុំ ឯការងារខាងវៀតណាមទាល់តែជួប តាជុង ចង់ប្រជុំអីក៏ដោយ ក្នុងភូមិភាគទី៧ហ្នឹង។ អ៊ីចឹងក៏រៀបចំ ដល់រៀបចំ គេបញ្ជូនខ្ញុំចេញពីហ្នឹងទៅទៀត ទៅឡុងខាញ់អ្ហ៎! កន្លែងសាលារបស់វៀតណាមខាងកើតព្រៃនគរនោះ ទៅសាលាឡុងខាញ់។

ដល់ទៅឡុងខាញ់ហ្នឹង ខ្ញុំនៅនុ៎ងប្រហែលបានមួយអាទិត្យ អត់មានបានទៅរៀនអីទេទៅនុ៎ង។ ទៅគេរៀន៣ថ្ងៃដែរ គេរៀនពីទឹកដីកម្ពុជានោះដែលមាន១ធនធានច្រើនណាស់ គេរៀនតែប៉ុណ្ណឹងទេ គេថាខ្ញុំអត់មានសាលាទេ។ ចេញពីហ្នឹងបានខ្ញុំទៅដល់១ឡុងយ៉ាវ ព្រោះឡុងយ៉ាវពីមុនខ្ញុំបញ្ជូនទ័ព៤០០នាក់ទៅរៀននុ៎ង ទៅឡុងយ៉ាវ។ ដល់ទៅឡុងយ៉ាវ ទៅដល់ឡុងយ៉ាវនុ៎ង ក៏សម្រាកជាមួយប្រធានភូមិភាគទី៧ តាបាគួង ហ្នឹង។ សម្រាកនុ៎ងបានប៉ុន្មាន ក៏ចុះមកពិភាក្សានៅភ្នំដើងម្តែងនេះទៀត។ ពិភាក្សាគ្នាថាឥឡូវយើងរកវិធីវ៉ៃយ៉ាងម៉េច បើ ប៉ុល ពត វាកំពុងតែសម្លាប់ ហើយវាកំពុងកៀរប្រជាពលរដ្ឋយកទៅលិចយើងរកវិធីណា។ ហើយយើងក៏ឯកភាពគ្នាលើផែនទី ថាបើយើងវ៉ៃរុញច្រាន ប៉ុល ពត ពីនេះទៅ ប្រជាជនយើងធ្លាក់ទឹកទន្លេហើយ ត្រូវតែស្លាប់ទាំងអស់។ អ៊ីចឹងមានវិធីវ៉ៃរបៀបកង្កែបលោតទេ វ៉ៃរបៀបកង្កែបលោត គឺវ៉ៃពេញប្រទេសតែម្តង កន្លែងណាវ៉ៃ ដើម្បីបំបែកកម្លាំងខ្មែរក្រហមហ្នឹង ធ្វើម៉េចឲ្យប្រជាពលរដ្ឋយើងបានរស់ឡើងវិញ។ ឯកភាពគ្នា គេចាប់ផ្តើមបើយុទ្ធនាការវ៉ៃ។ អាហ្នឹងរឿងប៉ុណ្ណឹង។

[១៤:០០:៣២]

រហូតមកដល់៧៩ ដល់វ៉ៃបែក៧៩នេះ ខ្ញុំគេដកពីនុ៎ងមកទៀត មកកាន់ៗភូមិភាគ២នេះ។ ខ្ញុំទទួលប្រាំខេត្ត ព្រៃវែង, ស្វាយរៀង, កំពង់ចាម, កំពង់ធំ ផ្នែកប៉ូលិសទេ មិនមែនផ្នែកទាហានទេ។ អ៊ីចឹងគេឱ្យវៀតណាម៣០ ខ្មែរ៣០ មកការពារខ្ញុំ។ ហើយយើងតំណាងឱ្យប្រទេសមែន ប៉ុន្តែយើងមិនមែនបានប្រធានទេ គ្រាន់អនុ ឯគេទេគេអ្នកប្រធាននោះ។ កិច្ចការងារទាំងឡាយទាំងពួងលើគេទេ គេអ្នកសម្រេច ប៉ុន្តែខ្ញុំ ការងារមិនស្រួល ខ្ញុំអត់ព្រមទេ ព្រោះរឿងខ្មែរ ព្រោះកាលនិយាយគ្នានៅទីក្រុងហូជីមិញ និយាយរួចហើយ តាមគោលការណ៍"៥-ខ" និងគោលការណ៍ "១១-ខ", "៨-ខ" របស់កម្ពុជា-វៀតណាមមួយ យើងនិយាយរួចហើយតើ។ អ៊ីចឹងមនុស្សខ្ញុំមនុស្សរឹង មិនងាយទន់ទេ ទោះឯណោះក៏រឹងដែរ។ ការងារណាដែលប៉ះពាល់ដល់កម្ពុជា ខ្ញុំអត់ព្រម ព្រោះខាងកម្ពុជា ៗមានប្រជាជនកម្ពុជាជាម្ចាស់ដែរ។

**ស៖** បាទ អរគុណ។ ប៉ុណ្ណឹងយើងមានសំណួរច្រើនទៀត ព្រោះសំណួរលោក សួររហូតដល់២ថ្ងៃឯណោះ អ៊ីចឹងមានសំណួរច្រើន។ ហើយប្រហែលជាភាគីគេសួរលោកច្រើន។ យើងសួរតែសំណួរមូលដ្ឋានមួយចំនួន ដើម្បីឱ្យវាមានការផ្ដើមនៃការតាំងសំណួរដេញដោលចំពោះលោក។ លោកអំមិញលោកលើក បានលើកឡើងថា នៅចាប់ពីខែ១២ៗ គឺខែធ្នូ ឆ្នាំ១៩៧៧ ក៏កើតមានជម្លោះជាមួយនឹងវៀត-ណាមនៅតំបន់ដែលលោកឈរជើង។ ហើយទី១ យើងសួរថា តើកាលពីចាប់ផ្ដើមជម្លោះហ្នឹង តើលោកធ្វើកងទ័ពនៅអង្គភាពណា? ហើយលោកមានតួនាទី មានឋានៈអ្វីដែរ?

**ឆ៖** កាលឈ្លោះគ្នាកើតឡើងគឺនៅឆ្នាំ៧៧ ខែ១២។ កាលនោះខ្ញុំឋានៈខ្ញុំ តួនាទីជាប្រធានពេទ្យ១៥៦ ប្រធានពេទ្យ១៥៦។

[១៤:០២:៥២]

**ស៖** ពេទ្យ១៥៦នេះ ចំណុះឱ្យភូមិភាគ ឬក៏ចំណុះឱ្យកងពល?

**ឆ៖** ១៥៦គឺចំណុះឱ្យកងពលលេខ៤។

**ស៖** ហើយកងពលលេខ៤ហ្នឹង លោកស្គាល់ប្រធានកងពលទេ ឬក៏និងអនុប្រធានកងពលទេ អ្នកណាខ្លះទៅ កាលពីលោកធ្វើការនៅក្នុងឆ្នាំ១៩៧៧នុ៎ង?

**ឆ៖** ដំបូងឡើយ ខ្ញុំសូមនិយាយ ប្រធានកងពលឈ្មោះ តាផន, ឯ ហេង សំរិន អ៊ីចឹងជាប្រធានយោធា ហេង សំរិន រាល់ថ្ងៃនេះ ហ្នឹងប្រធានយោធា។ ហើយអនុហ្នឹងគឺ ខ្ញុំភ្លេចត្រកូលគាត់ហើយ ឈ្មោះ តាគឹម ហើយ តាគ្រី ពីរនាក់ហ្នឹង ហ្នឹងកងពលលេខ៤។

**ស៖** ហើយកងពលលេខ៤នេះ ឈរជើងនៅកន្លែងណាដែរ? ទីបញ្ជាការៗកងពលកាលនោះ កាលជំនាន់នុ៎ង កាលមានចាប់ផ្ដើមសង្គ្រាមហ្នឹង តើទីបញ្ជាការកងពលលេខ៤ ឈរជើងនៅកន្លែងណា?

**ឆ៖** ទីបញ្ជាការកងពលលេខ៤ ឈរនៅក្រែក នៅក្រែក។

**ស៖** លោកអំមិញបាននិយាយថា មានការកិច្ចប្រជុំមួយនៅក្នុងទីបញ្ជាការកងពលលេខ៤ ដែលក្រោមការដឹកនាំកិច្ចប្រជុំហ្នឹងដោយមកពីកងកម្លាំងមកពីភូមិភាគកណ្ដាល។ ហើយក៏មានការកោះប្រជុំមានប្រធានវរៈ ឬក៏ប្រធានអនុសេនាធំដែលថ្នាក់ដឹកនាំនៅក្នុងចំណុះកងពលហ្នឹងមកប្រជុំ ហើយចាប់អស់ ចាប់សម្លាប់អស់ នៅសល់ៗតែម្នាក់ទេដែលបាញ់របួស។ សំណួរសួរថាចុះកាលណោះមេបញ្ជាការកងពល ឬក៏មេបញ្ជាការកងពលនៅឯណា បានជាលោកមិនបានរៀបរាប់ដល់មេបញ្ជាការកងពលហើយនិងមេបញ្ជារងរបស់កងពល?

[១៤:០៥:២៤]

**ឆ៖** មូលហេតុអ៊ីចេះ កន្លងមកគឺនៅសមរភូមិ ប៉ុន្តែគេហៅមកប្រជុំនៅកន្លែងកងពលក្រែកហ្នឹង ពេលហ្នឹងគេចាប់អស់ ចាប់អស។ ប៉ុន្តែលោក ហេង សំរិន ដែលគាត់រួចហ្នឹងមកពីគាត់ ពេលនោះគេដកទៅសេនាធិការព្រៃវែងបាត់ទៅហើយ នៅ តាគឹម, តាគ្រី មកគេចាប់ គេចាប់ពេលហ្នឹង ចាប់នៅក្រែកហ្នឹង ពេលប្រជុំ។

**ស៖** អរគុណ។ ចុះជាលេខាៗប្រធាន ប្រធាន ឬក៏លេខាកងពលឈ្មោះ ផន យ៉ាងម៉េចដែរជោគវាសនារបស់គាត់?

**ឆ៖** ជោគវាសនារបស់ប្រធានកងពលឈ្មោះ ផន ហ្នឹង និយាយរួមគេហៅទៅតាំងពីឆ្នាំ៧៦ម្ល៉េះបាត់តែម្ដង អត់ដឹង នៅតែ ហេង សំរិន មួយទេ។

**ស៖**អរគុណ។ ហើយលោកអំមិញក៏បានបញ្ជាក់មួយដែលជាចំណុចនៃការចាប់ផ្ដើមព្រឹត្តិការណ៍ដែលនាំឲ្យមានការចោទប្រកាន់ ក៏ដូចជាការស៊ើបសួរដេញដោលនៅពេលនេះ ក្នុងឋានៈលោកជាសាក្សីដែលបញ្ជាក់អំពីអង្គហេតុ បំភ្លឺអំពីអង្គហេតុជម្លោះប្រដាប់អាវុធ។ លោកបានលើកឡើងអំមិញកាលពីចាប់ផ្ដើមពីខែធ្នូ ឆ្នាំ១៩៧៧ ក៏កើតមានជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាម។ សំណួរសួរថា តាមបទពិសោធន៍របស់លោក ឬក៏តាមការកត់សម្គាល់របស់លោកដែលលោកបានប្រឡូកផ្ទាល់នៅក្នុងស្ថានភាពជីវភាពជាកងទ័ពតាំងពីឆ្នាំ៧០ ហើយហូរហែ ហើយលោកហាក់ដូចជានៅក្នុងជម្លោះនេះតែម្ដង។ ពិតមែនតែឋានន្តរសក្តិរបស់លោកនៅក្នុងកម្រិតមួយដែលជាមធ្យម ប៉ុន្តែទំនងជាលោកមានព័ត៌មាន

ច្រើន។ សំណួរសួរថា តើវាដើមចមពីដំបូងនោះ វាមូលហេតុអ្វីបានជាមានជម្លោះប្រដាប់អាវុធកើតឡើងរវាងកម្ពុជានិងវៀតណាមនៅតំបន់ភូមិសាស្ត្ររបស់លោកឈរជើង នៅភូមិភាគបូព៌ានោះ? លោកដឹងទេ? លោកអាចរៀបរាប់បានទេ?

[១៤:០៧:៣២]

**ឆ៖** ខ្ញុំសូមរាយការណ៍ជូន។ ការទំនាស់ហ្នឹងមានពីរ ចាប់ផ្តើមទំនាស់មុនដំបូងហ្នឹងនៅឆ្នាំ ១៩៧៣ ទំនាស់ហ្នឹងទំនាស់រឿងអី រឿងសម្ភារៈ ដែលបរទេសមហាអំណាចបញ្ជូនមកចែករំលែកមិនស្មើគ្នា ហ្នឹងទំនាស់ទី១។ ដល់ទំនាស់ទី២ វាកើតឡើងដល់ការប្រយុទ្ធគ្នាគឺទំនាស់បញ្ហាព្រំដែន ពីបញ្ហាព្រំដែនទំនាស់គ្នាហ្នឹង ព្រោះព្រំដែនមិនច្បាស់លាស់ដែលធ្វើឲ្យកើតៗទំនាស់គ្នា ប្រយុទ្ធគ្នានៅពេលហ្នឹង។

**ស៖** លោកនិយាយថា ចាប់ផ្តើមពីផលប្រយោជន៍ ទំនាស់ផលប្រយោជន៍ហ្នឹង ផលប្រយោជន៍សម្ភារៈអំមិញគឺផលប្រយោជន៍អីខ្លះទៅ? ហើយវាមានទ្រង់ទ្រាយយ៉ាងម៉េចទៅ ផលប្រយោជន៍ដែលនាំឲ្យទំនាស់រហូតដល់មានកើតជាជម្លោះគ្នា រហូតដល់មានសង្គ្រាមស៊ីសាច់ហុតឈាមគ្នារវាងកម្ពុជានិងវៀតណាម?

**ឆ៖** ទំនាស់ឆ្នាំ១៩៧៣ ទំនាស់វាអ៊ីចេះ សម្ភារៈសឹកទាំងអស់ដែលផ្តល់ឲ្យ កន្លងមកវៀតណាមហើយនិងកម្ពុជាទទួលៗឥទ្ធិពលតែមួយទេ ពីចិនទាំងអស់។ អ៊ីចឹងកាលណាផ្តល់សម្ភារៈមក តាំងពីរថយន្ត តាំងពីកាំភ្លើង គ្រាប់រំសេវ ខោអាវមក តាមរយៈវៀតណាម ហើយខ្មែរយើងមិនអាចទៅយកផ្ទាល់បានទេ តាមរយៈហ្នឹង។ ប៉ុន្តែដល់ពេលបញ្ជូនមក ចិនបញ្ជូនមកតាំងពីថ្នាំពេទ្យថ្នាំអី ដល់បញ្ជូនមកទៅ ឧទាហរណ៍ គេឲ្យមក១០០ ប៉ុន្តែយើងបានតែ៦០ វាបាត់អស់៤០។ អ៊ីចឹងការអាក់អន់ចិត្តចេះតែមានបន្តបន្ទាប់។ ហ្នឹងទំនាស់កើតឡើងពីបញ្ហាហ្នឹង ដែលទំនាស់ឡើងនុ៎ង ហ្នឹងនិយាយពីឆ្នាំ៧៣។ ដល់ពេល៧៣ហ្នឹងហើយដែលទំនាស់ហើយ ដល់វាប្រជុំសម្រេចថា ឥឡូវកងទ័ពវៀតណាមដែលនៅជាមួយ -- ខ្មែរនៅជាមួយវៀតណាមហ្នឹង គឺប្រគល់ខ្មែរឲ្យខ្មែរវិញ វៀតណាមឲ្យទៅវៀតណាមវិញ ពេលនោះចាប់ផ្តើមដកបណ្តើរៗហើយ ពី៧៣នុ៎ង។ គេចាប់ផ្តើមដកបណ្តើរៗ នៅតែៗអី? នៅតែជំនាញការមួយៗទេ នៅជាមួយខ្មែរ។ អ៊ីចឹងអាក់អន់ចិត្តតាំងពីអារឿងទ្រព្យសម្បត្តិនុ៎ង ទី១។ ដល់ចូលទី២ ពីបញ្ហាព្រំដែន។ ដល់ព្រំដែនហ្នឹងទៅ ៗពិនិត្យមើលឃើញថាវាមិនសមស្រប វាមិនត្រឹមត្រូវ ខិតចូលទៅនេះខិតចូលទៅនោះ ចាប់ផ្តើមមានគំនុំ រវាងគ្នានឹងគ្នា។ ហ្នឹងទំនាស់មានពីរហ្នឹង សូមជម្រាបជូន។

[១៤:១០:២៨]

**ស៖** បាទ អរគុណ។ ហើយដោយសារលោកជាកងទ័ពព្រំដែន ហើយបញ្ហានេះគឺដូចខ្ញុំបានជម្រាបអ៊ីចឹង គឺយើងពិភាក្សាគ្នាអំពីបញ្ហាជម្លោះប្រដាប់អាវុធរវាងកម្ពុជាវៀតណាម ដូច្នេះនៅក្នុងចំណុចមួយនៃភូមិសាស្ត្រក្នុងចំណោមភូមិសាស្ត្របណ្ដាទឹកដីដែលជាប់នឹងវៀតណាម គឺតំបន់ដែលលោកកាន់កាប់។ ហើយមូលហេតុពាក់ព័ន្ធជាមួយនឹងជម្លោះព្រំដែនអំមិញនេះ គឺវាមានកម្រិតយ៉ាងម៉េចទៅ បានជាប៉ានដល់ការជម្លោះដោយប្រដាប់អាវុធរវាងគ្នា? មានអ្នកណាជាអ្នកណាចាប់ផ្ដើមមុន? អ្នកណាជាអ្នករំលោភយកដែនដី ផែនដីមុន ឬក៏អ្នកណាជាអ្នកប្រកាន់ថា ឥរិយាបថថាទីតាំងដីរបស់ខ្លួននៅត្រឹមនេះត្រឹមនោះ? ហើយវាមានកើតឡើងទំនាស់ ឬក៏វាកើតឡើងទំនាស់ដោយភូមិសាស្ត្រផ្សេងទៀត ដូចជាទំនាស់ដីស្រែចម្ការអីជាដើម? ដើមចមមុនដំបូងបង្អស់ហ្នឹង គឺអ្វីទៅ? ហើយចំណុចណាដែលនាំឲ្យចាប់ផ្ដើមមុនគេ ផ្ទុះអាវុធមុនគេរវាងកម្ពុជា វៀតណាម? នៅដែលចំណុចដែលភូមិភាគខាងបូព៌ាទេ ដែលលោកដឹង លោកអាចដឹង លោកអាចនិយាយប្រាប់ដល់អង្គជំនុំជម្រះ អង្គសវនាការបានដឹងអំពីបញ្ហាជម្លោះនេះ។

**ធ៖** ចំពោះបញ្ហាទំនាស់ ខ្ញុំនិយាយតែនៅភូមិភាគបូព៌ាទេ។ ការទំនាស់កើតឡើងពីបញ្ហាព្រំដែនព្រោះមានភូមិមួយចំនួនជាភូមិរបស់ខ្មែរនោះ វាអត់ៗឃើញ វាទៅនៅទឹកដីគេ អាទំនាស់ហ្នឹងហើយដែលវាកើតឡើង។ វាបាត់ វាបាត់ភូមិខ្មែរ ដល់បាត់អ៊ីចឹង ក៏ទំនាស់កើតឡើង។ អ៊ីចឹងឲ្យៗខាងអ្នកសង្កេតការណ៍ អ្នកអី អ្នកស៊ើបការណ៍ស៊ើបអីចុះពិនិត្យមើល អាហ្នឹងវាយ៉ាងម៉េច ព្រំប្រទល់ហ្នឹងវាត្រឹមណា អីត្រឹមណា ហ្នឹងទំនាស់ហ្នឹង។ ដល់ទំនាស់ដោះស្រាយ ដោះអត់ចេញ។ រឿងនេះដែលដោះវាមិនចេញហ្នឹង។ ទៅប្រជុំគ្នា ក៏ដោះមិនចេញ ធ្វើម៉េចក៏ដោះមិនចេញ អ៊ីចឹងត្រូវធ្វើយ៉ាងម៉េច បើដោះមិនចេញ មានតែប្រើគ្រឿងអាវុធ។ ហើយមួយភូមិភាគបូព៌ាហ្នឹងគឺផ្ទុះដំណាលគ្នា ហ្នឹងយប់តែមួយហ្នឹងអត់មានខាងណាមុន ខាងណាក្រោយទេ។ ដោយឡែកខ្ញុំនិយាយតែខាងបូព៌ាទេ គឺផ្ទុះដំណាលគ្នាពេលយប់ហ្នឹងតែម្ដង កន្លែងណាដូចកន្លែងណា ចាប់ផ្ដើមផ្ទុះអាវុធហ្នង ពេលហ្នឹង។

[១៤:១៣:០១]

**ស៖** អរគុណ។ ហើយបន្ទាត់ព្រំដែនបូព៌ាដែលលោកមានប្រសាសន៍ ហើយលោកស្គាល់ភូមិសាស្ត្រភូមិភាគបូព៌ាច្បាស់ណាស់ ហើយលោកតាមលោកដឹង តើគេកំណត់យកពីចំណុចណានៃព្រំដែនផ្នែកចំណុចខាងជើងនៃព្រំដែន ហើយរហូតដល់ទៅចំណុចខាងត្បូងនៃព្រំដែនហ្នឹង គឺនិយាយពីរឿងភូមិសាស្ត្រវិញ ពីព្រោះនៅខាងជើងគឺជាប់នឹងភូមិភាគឦសាន ហើយនិងខាងត្បូងទៅជាប់នឹងភូមិភាគនិរតី

នេះតាមភូមិសាស្ត្រ តាមផែនទី។ ផែនទីនេះគឺយើងឃើញកំណត់ភូមិភាគបូព៌ា ដូច្នេះសំណួរសួរថាតើលោកស្គាល់ទេចំណុចចាប់ផ្ដើម -- ចំណុចពីចំណុចមួយទៅចំណុចមួយ បានន័យថា ពីចំណុចគោលពីខាងជើងបង្អស់នៃព្រំដែនរបស់បន្ទាត់ព្រំដែនដែលគ្រប់គ្រងដោយ ដែលជាប់ជាមួយនឹងភូមិភាគបូព៌ា ហើយរហូតដល់ខាងត្បូងបំផុត តើចំណុចអី? ហើយមានចម្ងាយប៉ុន្មានដែរ រយៈចម្ងាយប្រហាក់ប្រហែលប៉ុន្មានពីខាងជើងទៅខាងត្បូង?

**ឆ៖** ឥឡូវខ្ញុំសូមជម្រាបជូនអ៊ីចេះ។ បើនិយាយពីចម្ងាយចំនួនគីឡូម៉ែត្រ ខ្ញុំអត់ដឹងទេ ប៉ុន្តែខ្ញុំនិយាយតែព្រំប្រទល់ដែលជាប់នៅកំពង់ចាមដែលខ្ញុំឈរជើង។ អ៊ីចឹងមានភូមិមួយចំនួនដែលវានៅក្នុងផែនទី វាបាត់ក្នុងផែនទី វាបាត់ ដូចវត្តស្វាយ ភូមិត្នោត ភូមិក្រដាស អ៊ីចឹងនៅជិតផ្ទះប្រធានៗរដ្ឋសភាហ្នឹង ទៅមើលៗឥឡូវ។ ចង់ដឹង ខ្ញុំនាំទៅមើលឥឡូវ បាត់ៗក្នុងភូមិ -- ក្នុងផែនទីហ្នឹងតែម្ដង។ អ៊ីចឹងវាទៅណា? ភូមិហ្នឹងវាទៅណាវិញ? អារឿងហ្នឹងហើយដែលទំនាស់កើតឡើង វាអ៊ីចឹង រវាងភូមិផងរបងជាមួយហ្នឹង។ ហើយបើលោកថាទេ ខ្ញុំឆ្លើយហ្នឹងមិនជឿ ឥឡូវទៅទាំងអស់គ្នាទៅមើលជាក់ស្ដែង ឲ្យឃើញ។ ហ្នឹងសូមជម្រាបជូនប៉ុណ្ណឹង។

[១៤:១៥:០១]

**ស៖** បាទ អរគុណ។ មិនអីទេ ឆ្លើយបញ្ជាក់នេះ មូលហេតុដែលយើងសួរអំមិញ ដោយសារលោកបានបញ្ជាក់ថា ភូមិភាគ ព្រំដែននៃភូមិភាគបូព៌ាទាំងអស់ ជាមួយនឹងវៀតណាមគឺចាប់ផ្ដើមផ្ទុះអាវុធព្រមគ្នានឹងយប់តែមួយ។ ហើយអ៊ីចឹងហើយបានជាយើងសួរដល់ចំណុចថា វាប្រវែងប៉ុន្មានពីព្រោះយើងឃើញថា ការស្ដាប់សក្ខីកម្មសាក្សីមួយចំនួន គឺមានខាងចន្ទ្រា មានខាងៗចំពុះទាអីហ្នឹង គឺវាមានបញ្ហារួចហើយ ប៉ុន្តែចំណុចខ្លះ គឺមិនបានបកស្រាយអំពីបញ្ហាចំណុចហ្នឹងទេ ឧទាហរណ៍ ដូចជាជាប់នឹងមណ្ឌល ខេត្តមណ្ឌលគិរី ឬក៏ភូមិភាគឦសានហ្នឹង តំបន់មណ្ឌលគិរីហ្នឹង ក៏វាមិនមានហេតុការណ៍អីធ្ងន់ធ្ងរដែរ។ វាមានមែន ប៉ុន្តែវាមិនមានហេតុការណ៍តឹងតែងដូចអ្វីដែលលោកបានលើកឡើង។ ចំណុចមួយទៀត យើងចង់ដឹងថា នៅក្នុងភូមិភាគបូព៌ាទាំងមូលហ្នឹង មានកងកម្លាំងរបស់ភូមិភាគហ្នឹងប៉ុន្មានកងពលដែរ? ហើយកងពលអ្វីអីខ្លះទៅ? ហើយកងពលនីមួយៗ ឈរជើងនៅកន្លែងណាដែរ តាមលោកចាំ?

**ឆ៖** ខ្ញុំសូមជម្រាបជូនថា នៅក្នុងភូមិភាគបូព៌ា មានបីកងពល។ កងពលលេខ៣ កងពលលេខ៤ និងកងពលលេខ៥ មានបីកងពលហ្នឹង។ កងពលលេខ៣ ឈរនៅខេត្តស្វាយរៀង។ ហើយកងពល

លេខ៤ ឈរនៅផ្លូវជាតិលេខ៧នេះ។ កងពលលេខ៥ គឺកងពលដែលទើបនឹងកើតថ្មី ទើបកើតថ្មីទេ រួមជាមួយនឹងតំបន់ក្នុងភូមិភាគទាំងមូល តំបន់២០, ២១, ២២, ២០គត់, ២៤។ អ៊ីចឹងមានបីកងពល នៅបូព៌ាយើងហ្នឹង។

[១៤:១៧:០៣]

**ស៖** ក្នុងមួយកងពលៗហ្នឹង មានកម្លាំងកងទ័ពប្រហែលប៉ុន្មានដែរ ប្រហាក់ប្រហែលប៉ុន្មាន?

**ឆ៖** ក្នុងមួយកងពល មានជាង៧.០០០ គិតសរុបទាំងអស់។ ក្នុងមួយកងអនុសេនាតូច មាន ១២០នាក់ មួយកងអនុសេនាតូច។

**ស៖** តាមលោក ៗ--

**ឆ៖** ច្រឡំ មួយកងអនុសេនាធំមាន១២០នាក់។ មួយកងវរសេនាតូច មានមួយរយ -- អ៎!មាន ៥២០។ អ៊ីចឹងមាន៧.០០០ជាង ក្នុងមួយកងពលតូច។

**ស៖** បាទ អរគុណ។ ហើយពីរកងពលផ្សេងទៀតហ្នឹង តើលោកស្គាល់មេបញ្ជាការគេទេ មួយកងពលលេខ៣ មេបញ្ជាការ អនុបញ្ជាការ? ហើយនិងកងពលលេខ៥ មេបញ្ជាការ អនុបញ្ជាការ តើលោកស្គាល់ឈ្មោះដែរទេ?

**ឆ៖** ខ្ញុំស្គាល់តែមេៗទេ។ បើបញ្ជាការកងពលលេខ៣ហ្នឹង គឺស្គាល់តែប្រធានមួយ ពូជឿន។ ហើយចំពោះកងពលលេខ១៥ហ្នឹង គឺឈ្មោះ ឈឿន ប៉ុន្តែស្លាប់អស់ហើយ។ ហើយកងពលលេខ៤ហ្នឹង ហេង សំរិន ហ្នឹង ប្រធានរដ្ឋសភាហ្នឹង។

**ស៖** លោកថា កងពលលេខ៣ ឈរជើងនៅស្វាយរៀង ហើយនៅកន្លែងណាដែរ ទីបញ្ជាការកងពលលេខ៣?

**ឆ៖** ចំពោះខ្ញុំអត់ដឹងថានៅកន្លែងណាបញ្ជាការកងពល ប៉ុន្តែដឹងថានៅខេត្តស្វាយរៀង មិនដឹងនៅកន្លែងណាទេ។

[១៤:១៩:១៣]

**ស៖** បាទ មិនអីទេ។ ចុះកងពលលេខ៥ តើទីបញ្ជាការនៅៗកន្លែងណាដែរ? ហើយគេឈរជើងនៅតំបន់ណាដែរ កងពលលេខ៥ដែលបង្កើតថ្មី?

**ឆ៖** បញ្ជាការកងពលលេខ៥ គឺឈរនៅផ្លូវជាតិលេខ៧ ផ្លូវជាតិលេខ៧ហ្នឹងក្រោយ ក្រោយដែលវៀតណាមវាយចូលហើយ ទើបនឹងបង្កើតក្រោយទេ ឈ្មោះ ឈឿន។ កន្លងមក បងឈឿន ហ្នឹង

គាត់នៅ១៥៦ជាមួយខ្ញុំដែរ ប៉ុន្តែគេដកគាត់ហ្នឹង ទៅកាន់ប្រធានកងពលលេខ៥ គឺកងទ័ពថ្មី កងពលថ្មី កងទ័ពហ្នឹង។

**ស៖** នៅភូមិភាគបូព៌ា នៅអំឡុងពេលមុន បានន័យថាមុនមានជម្លោះជាមួយនឹងវៀតណាម ដែលចាប់ផ្តើមខែធ្នូ ឆ្នាំ១៩៧៧ តើមានកងទ័ពមជ្ឈិមឈរជើងនៅភូមិភាគបូព៌ាដែរឬទេ? ប្រសិនបើមាន តើមានប៉ុន្មានកងពលដែរ? យើងនិយាយតែក្នុងក្របខ័ណ្ឌមុនខែធ្នូ ឆ្នាំ១៩៧៧ទេ។

**ឆ៖** ខ្ញុំសូមជម្រាបជូនថា បើមុនឆ្នាំ៧៧ កងទ័ពមជ្ឈិមអត់មានទេ។ គឺបូព៌ា គឺបូព៌ាគ្រប់គ្រងដោយខ្លួនឯង។ អាហ្នឹងប៉ែកខាងហ្នឹងទេ ប៉ុន្តែខាងផ្សេងៗទៀត ខ្ញុំអត់ដឹងទេណា បើខាងហ្នឹងគឺខាងបូព៌ាគ្រប់គ្រងបូព៌ាដោយខ្លួនឯង អត់មានកងទ័ពមជ្ឈិមទេ។

[១៤:២០:៥៥]

**ស៖** បាទ អរគុណ។ ហើយសំណួរមួយទៀត យើងសួរតែសំណួរទូទៅទេ ដោយសារបញ្ហាឯកសារផង ហើយបញ្ហាលោកបានផ្តល់សក្ខីកម្មច្រើនហើយ នៅក្នុងកំណត់ដែលស្តាប់សក្ខីកម្មរបស់លោក។ លោកនិយាយកន្លងមកនេះ ហាក់ដូចជាមានការឆ្លើយបញ្ជាក់ច្រើនហើយ អំពីជម្លោះប្រដាប់អាវុធនៅក្នុងដែនដីកម្ពុជា។ សំណួរសួរថា តើមានអំឡុងពេលណាមួយនៃជម្លោះចាប់ពីខែធ្នូ ឆ្នាំ១៩៧៧មកនេះ ចាប់មានជម្លោះជាមួយគ្នាហ្នឹង តើភាគីកម្ពុជាហ្នឹងមានពេលណាមួយ ឬក៏ពេលវេលាជាក់លាក់ណាមួយដែលមានការប្រើប្រាស់កម្លាំងវាយលុកចូលទៅប្រទេសវៀតណាមដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបជូនថាអ៊ីចេះ ពេលដែលវាយចូលលុកទៅវៀតណាម យើងឃើញថាចាប់បើកយុទ្ធនាការលើកដំបូងគឺឆ្នាំ អ៊ូ! នៅខែ១២នោះ។ មានលើកទី១ មានតែមួយហ្នឹងដែលវាយលុកចូលហ្នឹងដែលខាងបូព៌ាទេ ប៉ុន្តែខាងៗភូមិភាគផ្សេងៗខ្ញុំអត់ដឹង និយាយហ្នឹង។ មានៗមួយពេលហ្នឹងគត់ដែលវាយរុញច្រានគ្នាទៅមក ទៅមកហ្នឹង ពេលហ្នឹង។ គេវាយរុញយើង យើងវាយរុញគេ អាហ្នឹងពេលហ្នឹង មានតែពេលហ្នឹងទេ។ ប៉ុន្តែក្រោយមកអត់មានទេ មានតែទប់កម្លាំង ពួកមជ្ឈិមមានតែទៅទប់វៀតណាមទេ អត់មានកម្លាំងអីរុញទៅរួចទេ នៅហ្នឹង ទប់នៅតាមព្រំដែនហ្នឹង ហើយមានតែថយចុះព្រោះវាបែកបាក់គ្នារួចទៅហើយ វាមានអីទៅវាយវៀតណាមកើតទៀត អត់មានទេ។

**ស៖** បាទអរគុណ។ ហើយចំណុចដែលលោកថា វាយរុលចូលទៅវៀតណាមអំមិញហ្នឹងគឺព្រឹត្តិការណ៍កើតឡើងនៅថ្ងៃខែឆ្នាំណាដែរ តាមលោកចាំ? ហើយអង្កាល់រុលចូលទៅទឹកដីវៀតណាមហ្នឹង ចូលដល់ចំណុចណា? ហើយចម្ងាយពីព្រំដែនប្រហែលប៉ុន្មានគីឡូដែរ?

[១៤:២៣:០៦]

**ឆ៖** ខ្ញុំសូមជម្រាបជូនអ៊ីចេះ ព្រោះការចូលហ្នឹង វាៗអង្គភាពខុសគ្នា។ ឥឡូវខ្ញុំនិយាយពី១៥៦របស់ខ្ញុំវិញ អ៊ីចឹង១៥៦ទទួលភារកិច្ច គឺវ៉ៃបន្ទាយ២៧របស់វៀតណាមតែម្ដង បន្ទាយធំហ្នឹងតែម្ដង។ ប៉ុន្តែមុខព្រួញផ្សេងៗ យើងអត់ដឹងទេ ដឹងតែ២៧ហ្នឹងគឺវាយហ្នឹងតែម្ដង។ គឺ១៥៦គឺវាយៗកម្ទេច២៧ប៉ុណ្ណឹង។ ប៉ុន្តែការវាយគ្នាឃើញថាវា បើនិយាយបែកហ្នឹង វាអស់ជាងមួយចំហៀងរួចទៅហើយ នៅសល់តិចតួចទេ។ ប៉ុន្តែដោយសារអី? ដោយសារវៀតណាមហ្នឹងមានរថក្រោះ មានអីជួយធ្វើអន្តរាគមន៍ជួយអន្តរាគមន៍ទៅ។ ដល់នៅជាប់គ្នា៣យប់៣ថ្ងៃហ្នឹង ក៏ដកទ័ពថយមកវិញ។ ដកមកក៏កិលនៅតាមព្រំដែនដែរ មិនមែនដករហូតមកក្នុងទេ។ ក៏ចាប់ផ្ដើមបើកប្រយុទ្ធគ្នាទៀត បន្តនេះទៀត។ ដល់ពេលតគ្នាតគ្នា មួយបន្ទាយ១២៧ហ្នឹង ផ្លូវមុខព្រួញហ្នឹងវាបុកអត់ដាច់ទេ បុកធ្វើម៉េចក៏មិនដាច់ដែរ។ ប៉ុន្តែវាបុកដាច់ឯណា? បុកដាច់១៥៥នោះ! ត្រង់អំពុក ភ្នំបុសតាកុក។ ដល់បុកដាច់មុខ លេងតាមផ្លូវជាតិលេខ៧មក រថក្រោះដាក់ពីនុ៎ងមក មកបាញ់ក្រោយខ្នងខ្ញុំនេះ ត្រង់ផ្លូវកែងក្រែកនេះ។ ដាក់រថក្រោះហ្នឹង លេងសុទ្ធ១២គ្រឿសមកតែម្ដង។ អ៊ីចឹងខ្ញុំឆ្ងល់ ចុះមានរថក្រោះនរណាបាញ់មកគ្នាឯងហ្នឹង។ ដល់ថាអត់ទេ បុកដាច់ផ្លូវត្រង់អំពុកហើយៗ បុសតាកុកនោះ បុក១៥៥ បុកដាច់ឯនុ៎ង វាព័ទ្ធមកក្រោយ។ បានខ្ញុំដកថយ មកទប់ខាងក្រោយវិញទៀត។ បើមុខព្រួញខ្ញុំអត់ដាច់ទេ បុកម៉េចក៏មិនដាច់ដែរ។ រវាងវៀតណាមហើយយើងហ្នឹង បើនិយាយសង្គ្រាម សង្គ្រាមហ្នឹងខ្លាំងមែនទែន ស៊ីសាច់ហុតឈាមគ្នា ព្រោះសែងរបួសសុទ្ធតែជីកក្នុងដី អត់មានសែងលើដីបានទេ។ វៀតណាមក៏អ៊ីចឹង យើងក៏អ៊ីចឹងដែរ ទល់មុខគ្នា៣០ម៉ែត្រ របួសក៏សែងក្នុងដីដែរ ក្នុងម៉ាយ្សរដី។ វៀងណាមក៏អ៊ីចឹង យើងអ៊ីចឹងដែរ។ អត់មានទៅបាញ់រាប់រយម៉ែត្រទេ ៣០ច្រើនបំផុត ត្រូវបាញ់។

[១៤:២៥:២៥]

**ស៖** បាទ អរគុណ។ ហើយពេលដែលវាយចូលទៅបន្ទាយ២៧របស់វៀតណាមហ្នឹង តើទីតាំងហ្នឹងនៅកន្លែងណា? ហើយចម្ងាយប៉ុន្មានពីព្រំដែន ពីខ្សែបន្ទាត់ព្រំដែន?

**ឆ៖** បើបន្ទាយ២៧ បើយើងនិយាយទៅវាហួសពីស្ពានដែកមួយបន្តិច ហួសមួយបន្តិចទៅដល់ហើយ មិនឆ្ងាយប៉ុន្មានទេ។ ប៉ុន្តែខ្ញុំគិតគីឡូម៉ែត្រ មិនដឹងជាប៉ុន្មាន ប៉ុន្តែមិនឆ្ងាយពីទឹកដីខ្មែរប៉ុន្មានទេ។ ពីមុនគេហៅស្ពានដែក ចេញពីស្ពានដែកទៅ ដល់បន្ទាយ២៧។ ចេញពីបន្ទាយ២៧ទៅ ដល់ផ្សារស្នាច់ហ្នឹងក្បែរជាប់គ្នា ជិតគ្នាដែរ។

**សៈ** បាទ អរគុណ។ ហើយក្នុងឱកាសនៃបញ្ហាសង្គ្រាមជម្លោះប្រដាប់អាវុធកម្ពុជា-វៀតណាម ហ្នឹង លោកអាចបង្ហាញហេតុការណ៍ណាមួយដែលវៀតណាមហ្នឹង បានវាយលុកចូលជ្រៅបំផុតមកដល់ទឹកដីកម្ពុជានៅក្នុងពេល នៅភូមិភាគបូព៌ាហ្នឹង? តើគេចូលជ្រៅហ្នឹង មកដល់ជ្រៅ ប្រហែលដល់ទីណា? ដល់ប៉ុន្មាន ចម្ងាយប៉ុន្មានចេញពី ប្រៀបទៅនឹងព្រំដែន ខ្សែបន្ទាត់ព្រំដែន? ហើយនៅក្នុងឆ្នាំណាដែរ លោកចាំទេ?

**ឆៈ** អ៊ីចេះ ខ្ញុំសូមជម្រាបជូនបញ្ហានេះ។ ក្នុងឆ្នាំ៧៧ ប៉ុន្តែថ្ងៃអត់ដឹង ភ្លេចថ្ងៃហើយ ប៉ុន្តែដឹងក្នុងឆ្នាំ៧៧ហ្នឹង ចុងឆ្នាំ៧៧ហ្នឹង។ ពេលវៀតណាមបុកមក បុកមកតាមផ្លូវជាតិលេខ៧ ប្រហែលជា២០គីឡូ បើគិតស្មាន ថាព្រំដែនមកដល់ខ្នារ មកដល់ភូមិខ្នារយើង បុកមកដល់ត្រឹមហ្នឹង ត្រឹមភូមិខ្នារហ្នឹង ឃុំស្រឡប់។ មករុលមកលិច រុលអត់រួច ព្រោះយើងបានរៀបចំកម្លាំងទប់រួចហើយ ត្រឹមភូមិខ្នារ។ បុកមកហើយ ក៏ថយទៅវិញទៅ។

[១៤:២៧:៤៧]

**សៈ** ភូមិខ្នារ ឃុំស្រឡប់ តើនៅស្រុក នៅភូមិស្រុកអី ខេត្តអី ឬក៏ពួកស្រុកអី តំបន់អីទៅ?

**ឆៈ** អានោះនៅស្រុងត្បូងឃ្មុំ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ហ្នឹងតាមផ្លូវជាតិលេខ៧។

**សៈ** វៀតណាមដែលវាយលុកចូលមកទឹកកម្ពុជាហ្នឹង តើមានប្រើកងកម្លាំងប្រភេទណាខ្លះ? កងទ័ពប្រភេទណាខ្លះ? មានរថក្រោះ ឬក៏មានកាំភ្លើងធំ ឬក៏យន្តហោះដែរឬទេ គាត់គាំទ្រដោយយន្តហោះដែរឬទេ?

**ឆៈ** ខ្ញុំសូមជម្រាបជូនអ៊ីចេះ វ៉ៃដំបូងៗឡើង ដែលខ្ញុំវ៉ៃបន្ទាយ២៧ហ្នឹង វៀតណាមគាំទ្រដោយយន្តហោះ មានយន្តហោះទៀត រថក្រោះទៀត កាំភ្លើងធុនធ្ងន់១៣០លី។ និយាយរួមអាវុធគ្រប់ប្រភេទ។ ប៉ុន្តែក្រោយមកដែលបុកមកហ្នឹង មានតែរថក្រោះ អត់មានយន្តហោះទេ មានតែរថក្រោះទេតាមផ្លូវជាតិលេខ៧ បុកចូលមក។ ប៉ុន្តែយើងក៏បាញ់ឆេះវាអស់មួយចំនួនដែរ ពេលនុ៎ង។ ហ្នឹងមកដល់ត្រឹមខ្នារទេ ដែលវៀតណាមហើយ ក៏ថយទៅវិញទៅ។

**សៈ** បាទ អរគុណ។ ហើយអំមិញលោកបានលើកឡើងថា កម្លាំងលោកតែម្តង គឺចាំមុខព្រួញលោកតែម្តង បានវ៉ៃចូលទៅបន្ទាយ២៧របស់វៀតណាម។ សំណួរសួរថា តើលោកទទួលបញ្ជាពីអ្នកណាដែរ ក្នុងការដែលទៅវាយដល់បន្ទាយ២៧របស់វៀតណាម នៅក្នុងទឹកដីវៀតណាម?

[១៤:២៩:៤៣]

**ឆ៖** ឥឡូវខ្ញុំសូមជម្រាបអ៊ីចេះ ពេលនោះខ្ញុំគ្រាន់តែជាពេទ្យនៅសមរភូមិមុខ។ ខ្ញុំមិនមែនបញ្ជាការទេ គ្រាន់ជាពេទ្យ ប៉ុន្តែនៅជួរមុខ ដឹង។ ប៉ុន្តែអានេះបើតាមដឹងហ្នឹង គឺវាជាផែនការរបស់ភូមិភាគ ព្រោះក្នុងកងពលហ្នឹងគឺអ្វីៗស្រេចលើភូមិភាគអ្នកសម្រេច។ រឿងហ្នឹងប៉ុណ្ណឹងទេ។ ភូមិភាគសម្រេចហើយ បានកងពលហ្នឹងចាប់ផ្ដើម ឲ្យគ្រប់កងវរសេនាតូចទាំងអស់ គ្រប់វរសេនាធំទាំងអស់ចាប់ផ្ដើម។ អាហ្នឹងគឺភូមិភាគហើយ គ្មាននរណាទេ។

**ស៖** នៅក្នុងអំឡុងពេលពីឆ្នាំ ខែ១២ ឆ្នាំ៧៧ រហូតដល់ចុង ដល់ឆ្នាំ៧៨ បើតាមបទពិសោធន៍របស់លោកដែលបានអនុវត្តផ្ទាល់ បានឈរផ្ទាល់នៅទីនោះ ហើយជាអ្នក បុគ្គលម្នាក់ដែលមានភាពស្និតស្នាញជាងគេនៅសមរភូមិ តើវៀតណាមហ្នឹងវាយលុកចូលមកដែនដីនៃប្រទេសកម្ពុជាហ្នឹងប៉ុន្មានលើកដែរ? ហើយផលដែលធ្វើឲ្យខូចខាតអន្តរាយហ្នឹង រវាងភាគីទាំងសងខាងហ្នឹង តាមការសង្កេតរបស់លោក ឬការតាមលោកដឹង តាមព័ត៌មានរបាយការណ៍ផ្សេងៗ តើខូចខាតយ៉ាងម៉េចដែរ?

**ឆ៖** ឥឡូវខ្ញុំសូមជម្រាបជូនអ៊ីចេះ ព្រោះការវ៉ៃហ្នឹងវាមានពីរ។ ទី១ វ៉ៃគ្រាន់តែវ៉ៃ គឺថាវ៉ៃ ប្រយុទ្ធគ្នាទៅវិញទៅមក។ ទី២ វ៉ៃរំដោះប្រទេស។ វ៉ៃវាមានពីរអ៊ីចេះ។ ប៉ុន្តែនិយាយពីឆ្នាំណា ដល់ត្រឹមឆ្នាំណា សូមលោកបញ្ជាក់បន្តិចដើម្បីឲ្យដឹង?

**ស៖** យើងនិយាយនៅក្នុងក្របខ័ណ្ឌតែឆ្នាំ ចាប់ពីដើមផ្ដើមមានជម្លោះទៅ រហូតដល់មានអន្ត-រាគមន៍របស់មជ្ឈិមទៅភូមិភាគបូព៌ា។ តើកម្រិត ឬក៏ពេលវេលានៃការប្រយុទ្ធគ្នាយ៉ាងម៉េចដែរ? ពីព្រោះពេលដែលខាងមជ្ឈិម ទ័ពមជ្ឈិមទៅ វាមានភាពច្របូកច្របល់មួយដោយចោទ ថាមានការបះបោរ មានការបង្ក្រាបអ៊ីចឹង អាហ្នឹងព្រឹត្តិការណ៍វាផ្សេង រវាងការជម្លោះហ្នឹងវាជម្លោះផ្ទៃក្នុងផង ជម្លោះខាងក្រៅអាហ្នឹងវាពិបាកស្មុគស្មាញ។ ហើយយើងសួរតែមួយកង់ដំបូងទេ គឺអំឡុងពេលពីចាប់ផ្ដើមមានជម្លោះទៅ រហូតដល់ពេលដែលខាងកងទ័ពមជ្ឈិមបញ្ជូនទៅដល់ភូមិភាគបូព៌ា។

[១៤:៣២:១៧]

**ឆ៖** ឥឡូវខ្ញុំជម្រាបជូនអ៊ីចេះ ឆ្នាំ២០៧៧ហ្នឹង គឺអត់ទាន់មានកងទ័ពមជ្ឈិមទេ គឺភូមិភាគបូព៌ាហ្នឹងអ្នកប្រយុទ្ធជាមួយវៀតណាម។ ក្រោយមកដែលវៀតណាមបុកចូលមកហើយហ្នឹង ក្នុង៧៧ដែរ ដែលវៀតណាមបុកចូលទឹកដីកម្ពុជានេះ បានកងទ័ពមជ្ឈិមហ្នឹងវាយចូលទៅ។ កងពលលេខ២របស់មជ្ឈិមហ្នឹង បានចូលទៅ។ ដល់ចូលទៅ ពេលហ្នឹងហើយដែលស្របនឹងពេលហ្នឹង វាធ្វើរដ្ឋប្រហារ ផ្ទុះនៅផ្ទៃក្នុងតែម្ដង។ ផ្ទុះនៅផ្ទៃក្នុងនៅចាប់ផ្ដើមកាប់សម្លាប់យុទ្ធជន កម្មាភិបាលមក ចាប់ពេលហ្នឹង អា

ចុង៧៧ហ្នឹង។ ចាប់តាមអង្គភាព ចាប់តាមក្រសួង មន្ទីរហ្នឹង នាំគ្នារត់ រញ៉េរញ៉ៃពេញទឹកពេញដី យកមួយរួចខ្លួន។ អាត្រង់ហ្នឹងហើយបានយើងដឹងថា ប៉ុល ពត វាសត្រូវជាមួយវៀតណាមផង ហើយវាសត្រូវជាមួយប្រជាជនកម្ពុជាផង វាសម្លាប់ហើយ។ រឿងហ្នឹងហើយដែលខ្ញុំ ដែលផ្ដាច់ខ្លួនចេញពីពេទ្យហ្នឹង ទៅកាន់ទ័ពវិញ វ៉ៃ ប៉ុល ពត វិញ ពេលហ្នឹង ក្នុង៧៨ហ្នឹង ថ្ងៃ២៥ ខែ៥ ៧៨ ខ្ញុំចាប់ផ្ដើមធ្វើទ័ពហើយ វ៉ៃៗ ប៉ុល ពត វិញហើយ។

**ស៖** បាទ អរគុណ។ ឥឡូវនេះយើងបង្វែរនូវការសួរនាំនេះ បញ្ជាជម្លោះប៉ុណ្ណេះសិន យើងនឹងសួរលម្អិតចំណុចមួយៗ ដែលជាក់លាក់ដែលមានការកត់ត្រានៅក្នុងឯកសារ។ ហើយដំបូងនេះយើងចង់សួរអំពីទំនាក់ទំនងរបស់លោក តើលោកមានស្គាល់ថ្នាក់ដឹកនាំភូមិភាគបូព៌ាដែរឬទេ? ហើយភូមិភាគបូព៌ាហ្នឹងដឹកនាំដោយលេខាភូមិភាគឈ្មោះអី? ហើយនិងអនុលេខាប៉ុន្មាននាក់ដែរ? ហើយឈ្មោះអីខ្លះ?

[១៤:៣៤:៣០]

**ឆ៖** ខ្ញុំសូមជម្រាបជូនអ៊ីចេះ ចំពោះអ្នកដឹកនាំភូមិភាគបូព៌ា ខ្ញុំស្គាល់ ៗតែម្នាក់ទេ ឈ្មោះ សោ ភឹម ហៅ យ៉ាន់។ ស្គាល់តែម្នាក់ហ្នឹង ក្នុងភូមិភាគបូព៌ាហ្នឹង។ ហើយបើនិយាយពីគាត់វិញ បើជាមួយខ្ញុំប្រហែលជាត្រូវជាជីដូនប៉ុន្មានទេ ប្រហែលជីលួតហើយយ៉ាង ព្រោះៗយាយខ្ញុំនិងម្ដាយ សោ ភឹម ហ្នឹងគាត់ជាបងប្អូនបង្កើត។ ហើយប្រហែលជា ហើយមើល៍ ម្ដាយ សោ ភឹម ហើយយាយខ្ញុំ បងប្អូនបង្កើតហើយម្ដាយខ្ញុំនឹង សោ ភឹម ត្រូវជីដូនមួយ។ ខ្ញុំហ្នឹងប្រហែលជាជីទួតយ៉ាង។ ខ្ញុំស្គាល់ដែរ ស្គាល់តែគាត់ម្នាក់ទេ ក្រៅពីហ្នឹងមិនស្គាល់ទេ។ អ៊ីចឹងបានកិច្ចការងារទាំងឡាយ ទាំងពួង ខ្ញុំក៏ឧស្សាហ៍សួរគាត់ដែរ សួរឲ្យដឹង ព្រោះកន្លងមកហ្នឹង សោ ភឹម គាត់ៗថា ប៉ុល ពត មិនមែនក្បត់។ ខ្ញុំថាក្បត់ហើយ ព្រោះសម្លាប់មនុស្ស។ ហើយគាត់ក៏បាននិយាយដែរ ដល់ខ្ញុំសួរទៅ គាត់ថា បើ ប៉ុល ពត សម្លាប់មនុស្ស បើធ្វើរដ្ឋប្រហារ ម៉េចមិនប្រាប់គាត់? ខ្ញុំថា ធម្មតាមនុស្សមិនដែលនរណាគេប្រាប់ទេ គេធ្វើរដ្ឋប្រហារហើយ ខ្ញុំនិយាយ ខ្ញុំនិយាយអ៊ីចឹង។ និយាយហ្នឹងក្នុងនាមថាវា ស្គាល់គ្នាជាឪពុកមាអីទេ បានហ៊ាននិយាយនោះ។ តែគេក្បត់យើង គេមិនដែលប្រាប់យើងទេ។ ខ្ញុំនិយាយអ៊ីចឹង។ ហើយគាត់ អារឿងហ្នឹងហើយដែលគាត់មិនច្បាស់ថា ប៉ុល ពត ហ្នឹងវាក្បត់។ ដល់មិនច្បាស់ហ្នឹងហើយ ដែលគាត់មកសួរដល់នេះ អរិយក្សត្រ មុខកំពូលនេះ មកទាំងនីរសារមកអីទៅសួរ ប៉ុល ពត ហ្នឹង។ បាទ ប៉ុណ្ណឹងទេ។

**ស៖** បាទ អរគុណ។ ហើយដើម្បីបញ្ជាក់រឿងនេះច្បាស់លាស់ តើលោកដឹងថាលោក សោ ភឹម ហ្នឹងជាមួយនឹងលោកហ្នឹង តើអ្នកណាបង អ្នកណាប្អូន? ហើយគាត់កើតនៅថ្ងៃខែឆ្នាំណា? ហើយទី១,

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ទី២ តើគាត់មានស្រុកកំណើតនៅទីកន្លែងណា? លោកចាំទេ លោកស្គាល់គាត់ច្បាស់?

[១៤:៣៦:៤៥]

**ឆ៖** អ៊ីចេះ ខ្ញុំជម្រាបជូន។ ខ្ញុំអត់ស្គាល់ទេ ថ្ងៃខែកំណើត មិនដឹងទេ អត់ដឹង។ ប៉ុន្តែដឹងភូមិ ភូមិសង្គម ឃុំគគីរសោម ស្រុកស្វាយទៀប ខេត្តស្វាយរៀង ប៉ុន្តែដល់ថ្ងៃកំណើតគាត់អត់ដឹងទេ ព្រោះយើងកើតអត់ទាន់ អត់ដឹង។

**ស៖** លោកអំមិញបាននិយាយ ហើយដូចជាមានភាពស៊ីជម្រៅណាស់ លើបញ្ហាថា និយាយបញ្ហានយោបាយ ដែលមានលក្ខណៈចរិតធ្ងន់ ថាមានលក្ខណៈធ្ងន់ ដូចជា រឿងក្បត់ រឿងរដ្ឋប្រហារអីជាដើម និយាយពិភាក្សាជាមួយ សោ ភឹម ហាក់ដូចជាវាមានកម្រិតជិតស្និទ្ធណាស់។ សំណួរសួរថាតើភាពជិតស្និទ្ធរបស់លោកបែបនេះ តើវាមានលក្ខណៈជាបុគ្គលរវាងលោក ជាមួយនឹងគាត់ ដោយសារជាសាច់ញាតិជាមួយគ្នា ឬក៏ដោយសារតួនាទីរបស់លោក ជាមួយនឹងគាត់ហ្នឹង មានទំនាក់ទំនងដោយសារតួនាទីភារកិច្ចរបស់លោក ក្នុងការបំពេញមុខងារនៅជាពេទ្យ ឬក៏ជាកងទ័ពនៅក្នុងកងពលលេខ៤?

**ឆ៖** ខ្ញុំសូមជម្រាបជូនអ៊ីចេះ។ ការទំនាក់ទំនងរវាង សោ ភឹម និងខ្ញុំ នេះវាជាសាច់ឈាមទេ មិនមែនជាការងារទេ។ ការរស់នៅជារឿងគ្រួសារធម្មតា ពីព្រោះអីគ្រួសារខ្ញុំ នៅៗក្នុងមន្ទីរទុំង ផ្នែកកសិកម្ម វាមានគ្រួសារខ្ញុំយកធ្វើគាត់មួយដែរ ប៉ុន្តែស្លាប់អស់ទៅហើយ កូនបីនាក់នៅភូមិភាគហ្នឹង ទាំងម្តាយក្មេក ទាំងអីស្លាប់ទាំងអស់។ អ៊ីចឹងហើយ បានវាមានការទំនាក់ទំនងសួរសុខទុក្ខជាមួយគាត់ ប៉ុន្តែរឿងការងារស្អីៗផ្សេង ប្រទេសអី គ្មានអីពាក់ព័ន្ធ។ បានយើងដឹងរឿងមួយចំនួនខ្លះ ហើយគាត់ប្រាប់អ៊ីចឹង។

[១៤:៣៨:៤៩]

**ស៖** អ៊ីចឹង តើក្នុងឱកាសណាដែលលោកអាចមានលទ្ធភាពនៅក្នុងការទៅជួបគាត់ ដែលមានលក្ខណៈជាឯកជន ដើម្បីអាចនិយាយ អាចពិភាក្សាជាមួយគាត់ផ្សេងៗ ដូចជាលោកបានលើកឡើងអំមិញ មានភាពស្និទ្ធស្នាលគ្នាខ្លាំង ហើយនិយាយដល់បញ្ហានយោបាយប្រទេសជាតិជ្រៅជ្រះអ៊ីចឹង តើឱកាសណាខ្លះទៅ ដែលលោកអាចធ្វើដូច្នេះបាន?

**ឆ៖** ចំពោះបញ្ហានេះ ឱកាសដែលទៅជួបគ្នា វាអត់មានកំណត់ ព្រោះខ្ញុំនៅពេទ្យរបស់កងទ័ព។ យើងអត់មានកំណត់ថា ឥឡូវពេលនេះ ថ្ងៃនេះទៅជួបគាត់ អត់ទេ។ ពេលណាយើងទំនេរទៅ ឱកាសល្អទៅ ជួបមួយភ្លែតទៅ តែប៉ុណ្ណឹងទេ។ គ្មានទៅជួបរាល់ថ្ងៃអី ទៅរាល់ខែ អត់ទេ។ អ៊ីចឹងទៅលេងគ្រួសារ

ទៅ ទៅជួបគាត់មួយភ្លែតទៅ ព្រោះគ្រួសារនៅនុ៎ង នៅខាងផលិត ខាងកសិកម្មនុ៎ង។ តែប៉ុណ្ណឹងទេ អត់មាន--

**ស៖** គ្រួសាររបស់លោកដែរធ្វើការនៅកសិកម្មភូមិភាគ ដែលនៅជិតគាត់នៅជាមួយគាត់ហ្នឹង តើពាក្យថាគ្រួសារហ្នឹង ជាប្រពន្ធរបស់លោក ឬក៏ជាឪពុករបស់លោក ឬក៏បងប្អូនរបស់លោក?

**ឆ៖** ចំពោះគ្រួសារហ្នឹងគឺខ្ញុំម្ដាយមួយ ម្ដាយបង្កើតមួយនៅជាមួយនឹង ហើយយាយក្មេកហ្នឹងមួយទៀត ហើយប្រពន្ធមួយ និងកូនបីនាក់នៅជាមួយហ្នឹង ប្រពន្ធមួយ កូនបីនាក់។

**ស៖** អ៊ីចឹងលោកដឹង ស្គាល់ទីស្នាក់ការ ឬក៏មន្ទីរៗនៃភូមិភាគបូព៌ាច្បាស់លាស់។ តើមន្ទីរភូមិភាគបូព៌ាអង្កាល់នោះ អង្កាល់ពីជំនាន់ សោ ភឹម ហ្នឹងគឺមន្ទីរភូមិភាគបូព៌ាហ្នឹងគឺ នៅទី -- បោះទីតាំងនៅកន្លែងណាដែរ?

[១៤:៤១:០៣]

**ឆ៖** ដំបូងឡើយមន្ទីរភូមិភាគហ្នឹងគឺនៅសួង នៅក្រុងសួង។ ប៉ុន្តែក្រោយមកនៅនេះ សំរោងនៅគគីរនេះ នៅខាងត្បូងដូនតី នៅហ្នឹង។ គេហៅទួលសំរោង ទួលគគីរ។ នៅហ្នឹងធ្វើផ្ទះនៅហ្នឹង មានមន្ទីរពេទ្យអីនៅហ្នឹង។

**ស៖** កាលនោះសួងឋិតនៅក្នុងតំបន់អីដែរ? តំបន់ទីប៉ុន្មាន? តំបន់ប៉ុន្មានរបស់ភូមិភាគ? ហើយសំរោង គគីរ ដូនតីហ្នឹងឋិតនៅទីតាំងតំបន់ណាដែរសម័យហ្នឹង? ហើយសម័យនេះនៅទីកន្លែងណាដែរលោកអាចបង្ហាញបានទេ?

**ឆ៖** ចំពោះទីតាំងនៅភូមិភាគ ពីមុនមកនៅសួងហ្នឹង គេហៅតំបន់២១ ចាប់ខាងជើងផ្លូវខាងជើងថ្នល់ជាតិទៅជើងគឺ២១ហើយ។ នៅសំរោង ទួលព្រាបនេះតំបន់២០ ខាងនេះគឺតំបន់២០ គឺចែកគ្នាអ៊ីចឹង។ ខាងជើងផ្លូវគឺ២១ ខាងត្បូងគឺ២០ គេចែកគ្នាដាច់អ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ដែលលោកសាក្សីបានខិតខំឆ្លើយបញ្ជាក់តបនឹងសួររបស់យើង។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់

មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ហើយសាក្សី យើងមានសំណួរទូទៅមួយចំនួនដែលមានបំណងចង់សួរ ហើយនិងមានសំណួរជាក់លាក់មួយចំនួន ចង់ឲ្យលោកបញ្ជាក់។ ហើយតទៅនេះ យើងចង់ដឹងថា ពេលវេលាដែលលោកបានត្រូវទៅជួប មានឱកាសជួប ហើយនិងពិភាក្សាក្នុងនាមលក្ខណៈគ្រួសារជាមួយនឹងលោក សោ ភឹម នៅក្នុងអំឡុងពេលលោក សោ ភឹម ធ្វើជាលេខាភូមិភាគបូព៌ា។ សួរថាតើឱកាសដែលលោកបានទៅ -- ឱកាសដែលលោកបានទៅជួបពិភាក្សាជាមួយគាត់មានលក្ខណៈគ្រួសារហ្នឹង តើមានឱកាសណាមួយ -- តើមានឱកាសណាដែលលោក --

មន្ត្រីរដ្ឋបាលតុលាការមានបញ្ហាការប្រព័ន្ធ ឧបករណ៍សំឡេង។

*(មានបញ្ហាបច្ចេកទេស)*

[១៥:០៣:៣១]

ឱកាសដែលលោកបានទៅពិភាក្សាហ្នឹងគឺថា លោកមិនថា មិនទៀងទាត់ ប៉ុន្តែយើងសួរលោកថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង ជាពិសេសអំពីឆ្នាំ៧៥ មកទល់ទៅនឹងមានព្រឹត្តិការណ៍កើតឡើងនៅភូមិភាគបូព៌ា ហើយប្រហែលជាខែ៥ ឆ្នាំ១៩៧៨ ឱកាសដែលលោកជួបពិភាក្សាជាលក្ខណៈគ្រួសារជាមួយនឹង សោ ភឹម ហ្នឹង តើសរុបហ្នឹង តើគិតលោកមើល តើលោកអាចជួប សោ ភឹម បានប៉ុន្មានដងដែរ? ហើយលើកនីមួយៗដែលលោកទៅជួបហ្នឹង បានលើកឡើង បានពិភាក្សាបញ្ហាអ្វីខ្លះ ជាមួយនឹងលោក សោ ភឹម?

2-TCW-1065៖

**ឆ៖** ខ្ញុំសូមជម្រាបជូនបន្ត។ ជាមួយពេលវេលាជួបហ្នឹង បើគិតទៅ ក្នុងមួយឆ្នាំជួបតែបីឬបួនដង តែប៉ុណ្ណឹងទេ ព្រោះខ្ញុំនៅសមរភូមិ មិនអាចមានពេលវេលាមកជួបអីគ្រប់គ្រាន់ទេ។ មកៗជួបហ្នឹង កាលណាជួបគាត់ទៅ មកលេង មកជួបសួរសុខទុក្ខគ្រួសារផង ក៏មកជួបគាត់ផង ប៉ុណ្ណឹងឯង។ វាគ្មានកិច្ចការងារអីទៅទំនាក់ទំនងអី រឿងប្រទេសជាតិ អត់មានទេ ក្នុងនាមក្នុងគ្រួសារ។ សួរសុខទុក្ខប៉ុណ្ណឹង ហើយយើងនិយាយលេងជាមួយគាត់តិចតួច គាត់ក៏មិនប្រកាន់អីដែរ។ អាហ្នឹង បើបានសួរសុខទុក្ខហ្នឹង តែប៉ុណ្ណឹងទេ។

**ស៖** បាទ អរគុណ។ តាមចម្លើយសក្ខីកម្មរបស់លោកដែលបានឆ្លើយពីមុននេះ ថាមានឱកាសមួយនោះ លោកបានពិភាក្សា និយាយជាមួយនឹងលោក សោ ភឹម បញ្ជាក់ថា មានការប្រកែកគ្នារវាងថា លោកថា ប៉ុល ពត បានធ្វើរដ្ឋប្រហារ ហើយ សោ ភឹម ហ្នឹងគាត់មិនជឿទេ។ តើព្រឹត្តិការណ៍ដែលកើតឡើង ការពិភាក្សានិយាយគ្នាចូលជ្រៅ ដល់រឿងរដ្ឋប្រហារ ដល់រឿងក្បត់អីៗហ្នឹង តើការពិភាក្សាហ្នឹង នៅកាលៈទេសៈណាមួយដែរ ពេលវេលាទីកន្លែង ដែលលោកបានពិភាក្សាពីបញ្ហានេះជាមួយនឹងលោក សោ ភឹម លោកចាំដែរទេ? ហើយលោកអាចអត្ថាធិប្បាយនូវខ្លឹមសារឲ្យបានច្បាស់លាស់ នៅក្នុងការពិភាក្សាលើបញ្ហានេះជាមួយ សោ ភឹម ដែរឬទេ?

[១៥:០៦:០៣]

**ឆ៖** ខ្ញុំសូមជម្រាបជូន នៅចុងឆ្នាំ៧៧ ពេលដែលយើងកំពុងតែធ្វើសង្គ្រាមជាមួយវៀតណាមហ្នឹង ពេលហ្នឹងខ្ញុំនៅសមរភូមិទេ។ ប៉ុន្តែដល់ល្ងាចប្រហែលជាម៉ោងប្រាំ ខ្ញុំក៏ត្រឡប់មកៗលេងផ្ទះ មកជួបគាត់នៅផ្ទះហ្នឹង។ ដល់ជួបទៅ គាត់ថា ឥឡូវសភាពការណ៍នៅសមរភូមិយ៉ាងម៉េច? គាត់ក៏សួរខ្ញុំអីចឹង។ ខ្ញុំថា សភាពការណ៍នោះ ដូចជាមិនល្អ។ មិនល្អយ៉ាងម៉េច? ខ្ញុំថា ដើមឈើ ខ្ញុំទាញឧទាហរណ៍ថាដើមឈើហ្នឹង វាអត់សូវមានខ្យល់ទេ ប៉ុន្តែវារលំតែម្តង វាដួល រំលំគ្រេងៗតែម្តង។ ដល់អីចឹងគាត់ក៏វិភាគ គាត់ថា អាហ្នឹងវាអីចឹងចេះ អាហ្នឹងព្យុះនៅចិនទេ ប៉ុន្តែឥទ្ធិពលនោះ វាដល់កម្ពុជា និយាយអីចឹងឥទ្ធិពលដល់កម្ពុជា។ ហើយខ្ញុំសួរថា ចុះធ្វើផ្ទះហ្នឹងធ្វើអី? អ៎! ធ្វើផ្ទះហ្នឹងទុកសម្រាប់ទទួលភ្ញៀវចិន។ ខែភ្លឺអង្គុយលេងពីរនាក់នៅលើគ្រែនុ៎ង ខ្ញុំក៏សួរគាត់។ ខ្ញុំថាអត់អីទេ សមរភូមិមុខ ខ្ញុំនិយាយប្រាប់គាត់អីចឹង អាហ្នឹងឆ្នាំចុង៧៧ ពេលដែលយើងប្រទង់ប្រទាញគ្នានុ៎ង។ ហ្នឹងជម្រាបជូនចៅក្រមប៉ុណ្ណឹង។

**ស៖** វាមានហេតុផលយ៉ាងម៉េចទៅបានលោកបានអះអាងជាមួយគាត់ដូច្នេះ?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

[១៥:០៧:៤០]

**ឆ៖** ចាំមើល បញ្ហាហ្នឹងវាអ៊ីចេះ។ យើងចាប់ផ្ដើមប្រយុទ្ធជាមួយវៀតណាម ប្រយុទ្ធគ្នាហ្នឹង វៀតណាមក៏អត់វៃយើង ពេលនុ៎ង។ ដល់អត់វៃអ៊ីចឹង ក៏ចាប់ផ្ដើមផ្ទុះ ខែ៥ ចាប់ផ្ដើមផ្ទុះខាងក្នុងហ្នឹងតែម្ដង។ អាវុធផ្ទុះឡើងមក ដល់ផ្ទុះឡើងខ្ញុំថា អ៊ូ! អត់ស្រួលទេរឿងនេះ ផ្ទុះផ្ទៃក្នុងហើយ។ ខ្ញុំថាអ៊ីចឹងច្បាស់ជាមានណាក្បត់ហើយ ក្បត់គ្នាហើយ។ ហើយខ្ញុំក៏និយាយលេងជាមួយគាត់ ខ្ញុំថា ប្រហែលជា ប៉ុល ពត ទេក្បត់។ គាត់ថា អ្អេ! បើ ប៉ុល ពត ក្បត់ក៏ប្រាប់គាត់ដែរ។ អាហ្នឹងនិយាយលេងជាមួយគាត់អ៊ីចឹង។ ថាបើក្បត់ ក៏ប្រាប់គាត់ដែរ។ ប៉ុន្តែក្នុង ប៉ុល ពត នុ៎ងវាមានគណៈអចិន្ត្រៃយ៍ នោះវាមានប្រាំរូបដែរ រឿងអីមិនប្រាប់គាត់។ ហើយខ្ញុំក៏និយាយលេងជាមួយគាត់បន្តទៀត។ ខ្ញុំថា ធម្មតាមនុស្សក្បត់ គេមិនដែលប្រាប់យើងទេ មិនដែលប្រាប់យើងទេ។ ហើយការវិភាគរបស់គាត់ គាត់ថាប្រហែលជា សុន សេន ទេធ្វើរដ្ឋប្រហារនោះ មិនមែនថា ប៉ុល ពត ទេ។ រឿងនេះ ជម្រាបលោកប៉ុណ្ណឹង។

[១៥:០៨:៥៥]

**ស៖** បាទ អរគុណ។ ហើយពាក់ព័ន្ធនឹងបញ្ហានេះដែរ ដោយសារលោកអំមិញ លោកពីមុននេះ លោកបានឆ្លើយលាតរហូតដល់មានបញ្ហា ប៉ុល ពត មិនជឿ មិនជឿថា ប៉ុល ពត ធ្វើរដ្ឋប្រហារទេ ហើយលោក -- គាត់ជឿថា សុន សេន ទេ។ អ៊ីចឹងហើយបានគាត់ធ្វើដំណើរសំដៅទៅភ្នំពេញ ហើយរហូតទៅដល់អរិយក្សត្រ។ យើងចង់ដឹងថា តើលោកដឹងថា ជោគវាសនារបស់ សោ ភឹម ហ្នឹងយ៉ាងម៉េចទេ កាលពីនៅក្នុងអំឡុងពេលឆ្នាំ១៩៧៧នុ៎ង? -- ៧៨ណា នៅក្នុងអំឡុង៧៨នុ៎ង តើលោកដឹងជោគវាសនារបស់គាត់យ៉ាងម៉េចទេ?

**ឆ៖** ជម្រាបជូនអ៊ីចេះ ក្នុងឆ្នាំ១៩៧៨ បើ – អានេះជាគំនិតរបស់ខ្ញុំទេ។ គាត់ដូចអស់សង្ឃឹមដែរ អស់សង្ឃឹមពេលនុ៎ង។ អារឿងមិនច្បាស់ហ្នឹងហើយ ដែលគាត់ទៅអរិយក្សត ទៅមុខកំពូលហ្នឹងឱ្យនីរសារចូលទៅសួរហ្នឹង មូលហេតុអីបាន ប៉ុល ពត បណ្ដោយឱ្យកងទ័ពភូមិភាគកណ្ដាលមកសម្លាប់ប្រជាពលរដ្ឋ សម្លាប់កម្មាភិបាលនៅបូព៌ា។ អាត្រង់ហ្នឹងហើយដែរវា គាត់អស់សង្ឃឹមអារឿងហ្នឹងដែលគាត់ឱ្យទៅសួរហ្នឹង ដើម្បីយកកិច្ចការងារឱ្យច្បាស់។ ដល់ទៅហ្នឹង វាអត់បានសម្រេចមែន អត់បានសម្រេចមែន ប៉ុល ពត គេធ្វើរដ្ឋប្រហារទៅហើយ។ ហើយយើងនៅមិនច្បាស់ វិនិច្ឆ័យវាអត់ត្រូវសភាពការណ៍ហ្នឹង។ ហើយបើគាត់ជឿខ្ញុំ គាត់ប្រាស់ចេញខាងមក ខ្វះអីកងទ័ពបូព៌ានោះ ប្រមាណបីកងពលការពារគាត់មិនបានអ្ហ? ការពារបាន។ ប៉ុន្តែគាត់មិនជឿ មិនជឿខាងក្រោមៗគេឱ្យយោបល់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អារឿងហ្នឹងដែលធ្វើឲ្យគ្រោះថ្នាក់នោះ ហ្នឹងហើយ។ អាហ្នឹងសូមជម្រាបជូនចៅក្រមប៉ុណ្ណឹង។

[១៥:១០:៥៨]

**ស៖** បាទ អរគុណ។ ហើយលោកអំមិញលើកឡើងថា គាត់ចាត់ឲ្យនីរសារទៅៗសាកសួរអំពីព័ត៌មានហ្នឹងជាមួយនឹង ប៉ុល ពត។ ហើយចុះគាត់ទៅឯណា សោ ភឹម ទៅឯណា?

**ឆ៖** ខ្ញុំសូមជូនៗបន្តទៀត អំមិញខ្ញុំនិយាយមួយគន្លាក់ ត្រឹមគាត់ វាសនារបស់គាត់។ ឥឡូវដល់ពេលដែលគាត់ចេញដំណើរទៅ។ ទៅដល់ហ្នឹងគាត់មាននីរសារទៅ ឲ្យនីរសារហ្នឹង នីរសារហ្នឹងក៏ត្រូវជាក្មួយរបស់គាត់ដែរ ឈ្មោះ ជឿក ហ្នឹង ឲ្យយកសំបុត្រទៅឲ្យគណៈមជ្ឈិមបក្សហ្នឹង។ ដល់ទៅៗគេចាប់ ជឿក ហ្នឹងបាត់ទៀត។ ចាប់បាត់ទៀត ក៏បញ្ជូនទៅមួយទៀត។ បញ្ជូនទៅមួយទៀត បញ្ជូនទៅមួយទៀត វាចាប់បាត់ទៀត។ អ៊ីចឹងគេយកទ័ព យករថក្រោះមកព័ទ្ធគាត់តែម្តង បានដឹងថាជោគវាសនាគាត់ចប់ត្រឹមណេះហើយ។ ដល់មកព័ទ្ធគាត់ហ្នឹងហើយ អាហ្នឹងគាត់សម្លាប់ខ្លួនឯងហើយ គាត់ថាអស់។ វាសនារបស់គាត់គឺចប់ត្រឹមហ្នឹងហើយ។ គាត់សម្លាប់ខ្លួនឯង បាញ់សម្លាប់ខ្លួនឯងតែម្តង។ គ្រាន់តែផ្តាំផ្ញើអ្នក -- ផ្តាំផ្ញើអ្នកក្បែរនុ៎ងថា ក្រោកឡើងតស៊ូ ព្រោះខ្ញុំឈប់ហើយ បញ្ចប់ត្រឹមហ្នឹង។ ហ្នឹងសូមជម្រាបជូនចៅក្រមប៉ុណ្ណឹង។

**ស៖** អំមិញលោកនិយាយថា មកដល់អរិយក្សត្រ បានន័យថា គាត់រួមទាំងកងការពាររបស់គាត់ ឬក៏នីរសាររបស់គាត់ហ្នឹងបានមកដល់អរិយក្សត្រ ឬក៏គាត់មកដល់ទីណា? ហើយគាត់ឲ្យប្រើប្រាស់ ប្រើនីរសារ ឬក៏កងការពាររបស់គាត់ដែលកាន់សំបុត្រចូលទៅទីក្រុងភ្នំពេញ? គាត់ឈរជើងនៅកន្លែងណា ពេលដែលហេតុការណ៍ ព្រឹត្តិការណ៍នុ៎ងដែលកើតមានឡើងនុ៎ង?

[១៥:១៣:០៣]

**ឆ៖** ចំពោះការឈរជើងហ្នឹងក៏ខ្ញុំមិនបានដឹងទេ ប៉ុន្តែនីរសារមួយដែលរត់រួចខ្លួនហ្នឹងទៅនុ៎ងគ្រាន់តែប្រាប់ ប៉ុន្តែនៅទីតាំងកន្លែងណាខ្ញុំមិនដឹង ប៉ុន្តែតែពេលហ្នឹងនៅអរិយក្សត្រហ្នឹង។ ព្រោះពេលហ្នឹងដែលគេ គាត់បាញ់សម្លាប់នីរសារហើយ គាត់សម្លាប់ខ្លួនឯងហើយ នៅនីរសារម្នាក់គត់ ដែលទៅពួនក្នុងស្រះនុ៎ង នៅក្នុងកំប្លោកហ្នឹង។ ហើយពួកនិរតីនុ៎ង វាបាញ់ក្នុងកំប្លោក ប៉ុន្តែបាញ់អត់ត្រូវ ព្រោះវាងើបនឹងច្រមុះហ្នឹង នៅនុ៎ង ហើយវានៅលបចាំមើលហ្នឹង។ ពេលដែលស្ងាត់ហើយបានវាឡើង វារត់ទៅបាត់ទៅ វារត់ទៅស្រុកវិញទៅ។ នៅតែម្នាក់គត់ ក្រៅពីហ្នឹងងាប់ទាំងអស់។ ប៉ុន្តែទីតាំងនៅកន្លែងណាកន្លែងណា ខ្ញុំមិនបានសួរទេដែរ។

**ស៖** អ៊ីចឹងព្រឹត្តិការណ៍ហ្នឹងគឺលោកឮគេថាដែរទេ បានគេ--

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** ឈ្មោះអីទៅ? ក្មួយហ្នឹងឈ្មោះអីទៅដែលអ្នកនិយាយប្រាប់លោក?

**ឆ៖** ក្មួយហ្នឹងឈ្មោះ អ៊ុង ប៉ុន្តែឥឡូវទៅថៃបាត់ហើយ ទៅចំណាកស្រុកបាត់ហើយ ទៅប៉ុន្មានឆ្នាំហើយ។

**ស៖** ក្មួយនរណាគេ? ក្មួយ សោ ភឹម ឬក៏ក្មួយរបស់ប្រពន្ធ សោ ភឹម?

**ឆ៖** ក្មួយ សោ ភឹម បាទ ត្រូវជាក្មួយ សោ ភឹម។

**ស៖** អ៊ីចឹងតាមដែលលោកឮអំមិញ គឺយើងបញ្ជាក់ឡើងវិញតាមយើងស្តាប់គឺថា ដោយសារគាត់អស់សង្ឃឹម ហើយដោយសារត្រូវបានបញ្ជូននូវនីរសារពីរនាក់ទៅ ហើយបាត់ខ្លួន។ អ៊ីចឹងគាត់អស់សង្ឃឹម ក៏គាត់សម្រេចបាញ់កងការពាររបស់គាត់មួយចំនួន ហើយរត់រួចតែមួយទេ ហើយបន្តចុងក្រោយគឺគាត់បាញ់សម្លាប់ខ្លួនគាត់។ អ៊ីចឹងមែនទេ?

[១៥:១៥:០៣]

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ចុះអ្នកបើកបររថយន្តគាត់ យ៉ាងម៉េចដែរ?

**ឆ៖** ចំពោះអ្នកបើកបរ ខ្ញុំមិនបានសួរ អត់បានសួរទេ អ្នកបើកបររថយន្ត អត់បានសួរទេ។

**ស៖** បាទ អរគុណ។ ហើយលោកចាំទេ ព្រឹត្តិការណ៍នុ៎ងកើត គេតាមគេនិយាយប្រាប់នុ៎ង ឬក៏លោកជាសាច់ញាតិហ្នឹង តើលោកដឹងព្រឹត្តិការណ៍នុ៎ង កើតឡើងនៅអំឡុងពេលវេលាណាច្បាស់លាស់ដែរទេ? ទីតាំងមិនច្បាស់ទេ ប៉ុន្តែកាលវេលាដែលកើតមានហ្នឹង លោកអាចដឹងទេថាវាមានកើតឡើងនៅពេលណា កាលៈទេសៈណាដែរ?

**ឆ៖** ខ្ញុំសូមជម្រាបជូនថា វាអត់ -- ខ្ញុំអត់ដឹងទេ ពេលវេលាណាៗ ក៏អត់ដឹងទេ ប៉ុន្តែខ្ញុំគ្រាន់តែបានសួរវា ព្រោះវាក៏ត្រូវជាក្មួយដែរ។ ដល់ខ្ញុំសួរទៅ ខ្ញុំមិនចាប់អារម្មណ៍យករឿងហ្នឹងអីមកធ្វើជាផ្លូវការអីដែរ។ គ្រាន់តែសួរឲ្យដឹងប៉ុណ្ណឹងទេ ប៉ុន្តែវាដឹងឲ្យច្បាស់លាស់យ៉ាងម៉េចៗ អត់មានច្បាស់លាស់ទេ។

**ស៖** បាទ អរគុណ។ ហើយចុះកាលពីគាត់មាន រស់រានមានជីវិតហ្នឹង តើលោក សោ ភឹម ហ្នឹងមានប្រពន្ធដែរឬទេ? ហើយប្រពន្ធគាត់ហ្នឹងឈ្មោះអី? ហើយមានកូនប៉ុន្មាននាក់ដែរលោក សោ ភឹម ដោយសារលោកជាញាតិសន្តានរបស់គាត់?

[១៥:១៦:៤៤]

**ឆ៖** ចំពោះ សោ ភឹម តែនិយាយប្រពន្ធគាត់ហ្នឹងវា ឈ្មោះដើម មិនដឹងឈ្មោះអីទេ ប៉ុន្តែគេហៅថា យាយការ៉ូ ប៉ុន្តែកូនមាន២ពីរនាក់។ កូនមួយឈ្មោះ ណាត មួយ (ប្រុស)។ ហើយស្រីមួយឈ្មោះ ក្ស៊ី។ ពីរនាក់ ប៉ុន្តែមួយទៀតកូនចិញ្ចឹមទេ បើអ្នកមិនដឹងថាកូនបង្កើត មិនមែនទេ កូនចិញ្ចឹមទេ តែកូនគាត់តែពីរនាក់ទេ។ គេហៅពេទ្យ ធ្វើប្រធានពេទ្យហ្នឹង ពេទ្យណាត ហើយឈ្មោះ ក្ស៊ី មួយ។ ហើយ ក្ស៊ី ហ្នឹង ប្ដីវាហ្នឹង ប្ដីជាកូនប្រសារ រស់ ញឹម នៅភូមិភាគពាយ័ព្យដែលមកដណ្ដឹងនោះ ប្ដីវាហ្នឹង គឺកូនគាត់ពីរនាក់ហ្នឹង។

**ស៖** ចុះកូនចិញ្ចឹមរបស់គាត់ហ្នឹង លោកស្គាល់ទេ ឈ្មោះអី? ហើយប្រុស ឬក៏ស្រី?

**ឆ៖** កូនចិញ្ចឹមរបស់គាត់ហ្នឹងគឺស្រី ឈ្មោះ តាដេវ គេហៅ តាដេវ១ ប៉ុន្តែឥឡូវមិនដឹងទៅណាអត់ដឹង បាត់។

**ស៖** ចុះឈ្មោះ ណាត ហ្នឹងប្រុស ឬក៏ស្រី?

**ឆ៖** ណាត ហ្នឹងប្រធានពេទ្យ ព-២ ស្លាប់ហើយ។ ហើយ ក្ស៊ី ហ្នឹងមិនដឹងជាស្លាប់ ដឹងជារស់ អត់ដឹងទេ ស្រី។ ណាត ប្រុស។

**ស៖** ចុះជោគវាសនារបស់ យាយការ៉ូ ប្រពន្ធរបស់គាត់ហ្នឹង យ៉ាងម៉េចដែរ?

**ឆ៖** ជោគវាសនារបស់ យាយការ៉ូ ស្លាប់បាត់ហើយ របស់គាត់ហ្នឹង គឺស្លាប់តែម្ដង។ ដឹងវាទៅយកទៅសម្លាប់កន្លែងណា យើងអត់ដឹង ព្រោះខ្ញុំនៅសមរភូមិមុខ វាអត់ដឹងទេ ព្រោះរឿងខាងក្រោយអត់សួរដឹងទេ។

**ស៖** ម៉េចក៏លោកហ៊ានអះអាងថា យាយការ៉ូ ស្លាប់ហើយ ត្រូវគេយកទៅសម្លាប់?

[១៥:១៨:៥២]

**ឆ៖** បានតែខ្ញុំហ៊ានអះអាង ដូចខ្ញុំអ៊ីចឹង គ្រួសារខ្ញុំ ទៅរកវាមិនឃើញ។ ហើយ យាយការ៉ូ បើសិនជានៅ គាត់មកបាត់ហើយ ប៉ុន្តែគាត់គេយកសម្លាប់ គ្រាន់តែឮគេថាគេសម្លាប់បាត់ទៅហើយ យាយការ៉ូ នោះ វាគ្មាននៅទេ បានខ្ញុំអះអាងថា ស្លាប់ហើយ អត់មានទៅនៅទេ។

**ស៖** បាទ អរគុណ។ ហើយអំមិញនេះ លោកបាននិយាយដល់ រស់ ញឹម ដែលត្រូវជាអ្នកដន្លងជាមួយនឹង សោ ភឹម ដោយកូនស្រីរបស់គាត់ កូន សោ ភឹម ទៅយក រៀបការជាមួយនឹងកូន រស់ ញឹម ដែល--។ លោកស្គាល់ រស់ ញឹម ដែរទេ? គាត់ធ្វើអី នៅជំនាន់១កម្ពុជាប្រជាធិបតេយ្យ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ចំពោះខ្ញុំ ខ្ញុំអត់ស្គាល់ទេ រស់ ញឹម គ្រាន់តែដឹងថា រស់ ញឹម ប្រធានភូមិភាគពាយ័ព្យ ប៉ុណ្ណឹងទេ ព្រោះកូនគាត់ប្រុស ហើយមកយកកូន សោ ភឹម នេះស្រី។ គ្រាន់តែដឹងប៉ុណ្ណឹងទេ ប៉ុន្តែគាត់ធ្វើអីៗ ខ្ញុំអត់ដឹង រស់ ញឹម។ គ្រាន់តែគេថា ប្រធានភូមិភាគពាយ័ព្យប៉ុណ្ណឹង។

**ស៖** លោកដែលដឹងថា រស់ ញឹម បានធ្វើដំណើរមកទស្សនកិច្ចនៅៗភូមិភាគបូព៌ាដែរឬទេ? មកភូមិភាគបូព៌ា កាលនោះកាន់កាប់ដោយ សោ ភឹម នោះ?

**ឆ៖** ចំពោះខ្ញុំ គាត់មកពេលណាខែណា ខ្ញុំអត់ដែលបានជួបទេ អត់បានដឹង ព្រោះយើងនៅតែផ្នែកយោធា មានទៅដឹងអីទេ រឿងខាងក្រោយ អត់ដឹង។

**ស៖** បាទ អរគុណ។ ហើយសំណួរបន្ត តើលោកស្គាល់ សួស នៅ ហៅ ឈូក ដែរឬទេ?

**ឆ៖** ចំពោះខ្ញុំអត់ស្គាល់ទេ អត់ស្គាល់ទេ។

**ស៖** បាទ មិនអីទេ។ ចុះលោកស្គាល់ ចាន់ សេងហុង ហៅ ចាន់ ដែរឬទេ?

[១៥:២១:១៣]

**ឆ៖** ចំពោះ ចាន់ សេងហុង ក៏មិនដែលឃើញដែរ គ្រាន់តែឮតែឈ្មោះគេនិយាយទេ ចាន់ សេងហុង ហ្នឹង ហើយក៏ខ្ញុំមិនដែលឃើញដែរ អត់ដែលឃើញទេ។ វាគ្មានទំនាក់ទំនងអីជាមួយគាត់នុំងផង វាគ្មាន។

**ស៖** បាទ អរគុណ។ ហើយសំណួរមួយទៀត ដែលមានការពាក់ព័ន្ធនឹងការបះបោរនេះ ដោយសារលោកបានមានលក្ខណៈពិភាក្សា ហើយមានចំណុចខ្លះគឺមានបញ្ហាប្រទេសជាតិ បញ្ហានយោបាយជ្រៅជ្រះ លោកអាចប៉ាននិយាយពិភាក្សាជាមួយនឹងលោក សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា។ សំណួរសួរថាតើលោកដែលដឹងថា សោ ភឹម ហ្នឹងធ្លាប់មានទំនាក់ទំនងជាមួយនឹងបុគ្គល ឬក៏ជាមួយនឹងខាងតំណាងរដ្ឋខាងវៀតណាមដែរឬទេ នៅក្នុងអំឡុងពេលដែលគាត់កាន់អំណាចជាលេខាភូមិភាគបូព៌ា?

**ឆ៖** ខ្ញុំសូមជម្រាបជូន ខ្ញុំអត់ដែលបានដឹងទេ រឿងការទំនាក់ទំនងជាមួយវៀតណាម ជាមួយនិយាយរួមបុគ្គលណា ខ្ញុំអត់ដែលដឹង បានដឹងសោះ អត់ដែលដឹងសោះទេ។ ហ្នឹងជម្រាបជូនប៉ុណ្ណឹង។

**ស៖** បាទអរគុណ។ ហើយជាបន្តទៅទៀតនេះ យើងមានការពាក់ព័ន្ធនឹងបញ្ហាមួយចំនួន ហើយយើងបង្ហាញ សុំបង្ហាញឯកសារមួយចំនួន ដើម្បីឱ្យលោកជួយពិនិត្យមើល ដើម្បីកំណត់អត្តសញ្ញាណបុគ្គលដែលមានការពាក់ព័ន្ធជាមួយនឹងឯកសារ។

នេះ! មន្ត្រីរដ្ឋបានតុលាការយកឯកសារនេះ យកជូនសាក្សីពិនិត្យ។ អានេះមិនបាច់ទេ។

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

[១៥:២៤:០០]

បាទ បញ្ហានេះគឺលោកធ្លាប់បានបញ្ជាក់រួចហើយ ចំពោះមុខចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿងផ្សេង។ ប៉ុន្តែគឺមិន ឯកសារនេះគឺមិនមែនជានៅក្នុងសំណុំរឿងផ្សេងទេ គឺសំណុំរឿងផ្សេងមួយទៀត គឺសារទូរលេខចុះថ្ងៃទី០៦ វិច្ឆិកា ឆ្នាំ១៩៧៧ ដែលចុះហត្ថលេខាដោយឈ្មោះ ផុន។ ហើយក្នុងអំឡុងពេលស្តាប់សក្ខីកម្មគឺឯកសារ E3/10669 "ឆ" -- អ៎! ចម្លើយទី៣ គឺត្រង់ERN ភាសាខ្មែរគឺ 008 08443, ERN ជាភាសាអង់គ្លេសគឺ 00976867, ERN ជាភាសាបារាំងគឺ 01001377។ បានបង្ហាញថា សារទូរលេខផ្សេងមួយទៀត ដែលម្នាក់នោះគឺឈ្មោះ ផុន បានចុះហត្ថលេខា។ លោកពិនិត្យមើល!

ហើយសារទូរលេខនេះ គឺចេញនៅយប់ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៧៧។ ហើយឯកសារនេះចម្លងជូនអ៊ំៗ អ៊ំនួន, បងវ៉ាន់, បងវន, បងខៀវ, មន្ទីរ, ឯកសារ។ យើងចង់ដឹងតែមួយទេ គឺថា លោកពិនិត្យមើលមើល៍ ហើយត្រង់ចំណុចឈ្មោះ ផុន។ នៅក្នុងនេះគឺឈ្មោះ ផុន ហ្នឹង លោកដែលធ្លាប់ឃើញឯកសារនេះដែរទេ?

**ឆ៖** ខ្ញុំសូមជម្រាបជូនអ៊ីចេះ ឯកសារនេះ ខ្ញុំអត់ដែលឃើញទេ។ ឈ្មោះ ផុន ហ្នឹងក៏អត់ស្គាល់ទៀត ផុន ហ្នឹង។ អត់ស្គាល់ទេ។ អត់ដែលឃើញឯកសារហ្នឹង។

[១៥:២៦:៣២]

**ស៖** ចុះហេតុការណ៍ដែលកើតមានឡើង ដូចជា បញ្ហានេះ គឺនិយាយពាក់ព័ន្ធជាមួយនឹងរឿងមានហេតុការណ៍កើតឡើង គឺនៅវេលាម៉ោងបួនរសៀលក្នុងពេលប្រជុំនោះ ខ្ញុំមានជំងឺមួយមិនដឹងហេតុផលថា ខ្យល់មែន ឬក៏មិនមែនអីទេ មិនច្បាស់ ស្រាប់តែកំពុងអង្គុយស្តាប់បងប្អូនរាយការណ៍ ធ្លាក់ពីលើកៅអីខ្ពោក អត់បម្រះ មិនដឹងខ្លួនអស់រយៈប្រហែលជា២០នាទី ទើបដឹងខ្លួន។ ល្ងាចយប់ចាប់បន្តធ្វើការឡើងវិញ បានដដែល ព្រឹកឡើងក៏នៅបន្តធ្វើការទៀត ទាល់តែចប់ដោយជោគជ័យ។ ប៉ុន្តែនៅយប់ថ្ងៃទី០៥ ព្រឹកថ្ងៃទី០៦ ខែ១១ សភាពជំងឺហាត់ហេវច្រើន កម្រិតស្ទង់ឈាមមិនទៀងទាត់ មានពេលខ្លះឡើងដល់១៤ ក្នុងរយៈពេលខ្លី ចុះមកប្រាំបួនក៏មាន។ ដូច្នេះសុខភាពមិនសូវស្រួល បានជាបាយមិនឆ្ងាញ់ ហើយមានឈឺចុកចាប់ក្នុងទ្រូង ក្រោមដោះខាងស្តាំ ឈឺរហូតដល់ចំឡកខាងក្រោម។ បច្ចុប្បន្នឈឺក្បាលធ្ងន់ ហើយនិង -- ធ្ងន់ក្បាល និងឈឺក្បាលច្រើន។

លោកចាំដែរទេ តើមានហេតុការណ៍កើតឡើងនៅក្នុងកិច្ចប្រជុំមួយដែលថ្នាក់ដឹកនាំភូមិភាគបូព៌ា

ហ្នឹង គឺថ្នាក់ដឹកនាំមានហេតុការណ៍កើតឡើងនៅក្នុងកិច្ចប្រជុំ មានព្រឹត្តិការណ៍ហ្នឹងកើតឡើងដែរទេ? មានឈឺ ហើយសន្លប់ដួលពីលើ ធ្លាក់ពីលើកៅអី ហើយសន្លប់នៅក្នុងអំឡុងពេលកិច្ចប្រជុំ តើលោកដឹងរឿងព្រឹត្តិការណ៍នេះដែរឬទេ?

[១៥:២៨:២១]

**ឆ៖** ចុះហេតុការណ៍ដែលកើតឡើងចំពោះខ្ញុំ អត់ដឹង អត់ដែលប្រជុំ ហើយក៏មិនដឹងមនុស្សហ្នឹងមានជំងឺដួលសន្លប់ ក៏អត់ដែលដឹង។ ទើបនឹងឃើញឯកសារនេះទេ។ មិនដែលឃើញផងឯកសារហ្នឹង។ មិនដឹងជាប្រជុំនៅអីណា ស្អីណាផង អត់ដឹងផង។ អត់ដែលឃើញទេ ឯកសារ។

**ស៖** លោកមាន ជាសាច់ញាតិលោហិតជាមួយនឹងលោក សោ ភឹម តើលោកអាចបញ្ជាក់បានទេ តើ សោ ភឹម ហ្នឹង តាមដែលលោកដឹងហ្នឹង តើគាត់ធ្លាប់ប្រើប្រាស់ឈ្មោះអ្វីខ្លះ នៅក្នុងអំឡុងដែលគាត់ធ្វើបំពេញការងារជាលេខាភូមិភាគបូព៌ា?

**ឆ៖** ខ្ញុំសូមជម្រាបជូនថា ពីមុនមកគេហៅថាឈ្មោះ សោ ភឹម ប៉ុន្តែក្រោយមកគេដាក់ឈ្មោះ សោ យ៉ាន់ គឺមានឈ្មោះពីរ។ សោ ភឹម ផង ហៅ សោ យ៉ាន់ ផង ទាំងពីរហ្នឹង សូមជម្រាបជូន។

**ស៖** ចុះក្នុងជួរកម្មាភិបាលជាន់ខ្ពស់ ជាជនស៊ីវិល ឬក៏ដូចជា កម្មាភិបាលជាន់ខ្ពស់នៃកងទ័ពនៅភូមិភាគបូព៌ាហ្នឹង តើមានអ្នកណាដែលប្រើឈ្មោះ ឆុន ដែរឬទេ?

**ឆ៖** ចំពោះខ្ញុំវិញ អត់ដែលឮ អត់ដែលឮឈ្មោះ ឆុន ហ្នឹង។ អត់ដែលឮ ហើយមិនដែលឃើញ ហើយក៏មិនដែលឃើញដែរ ឯកសារហ្នឹងនេះ ឈ្មោះ ឆុន អត់ដែលឮទេ។ ហ្នឹងជម្រាបជូនប៉ុណ្ណឹង។

[១៥:៣០:១៥]

**ស៖** អាហ្នឹងខ្ញុំរំឭកការចងចាំមួយ ហើយលោកនឹកឃើញ ដោយសារទូរលេខលេខ៩១ ហើយចុះថ្ងៃទី១០ ខែ១២ ខែធ្នូ ហើយឯកសារហ្នឹងគឺ E3/8370។ "គោរពជូនបង -- ជូនម – គោរពជូន ម. ៨៧០ ជាទីស្នេហា។ សភាពការណ៍នៅសមរភូមិផ្លូវលេខ២២ ក្នុងថ្ងៃទី៩ ខែ១២ និងយប់ថ្ងៃទី៩ ខែ១២ ខ្មាំងចូលច្រកត្រាចខោល។ ហើយបច្ចុប្បន្នហ្នឹងបានបោះនៅម្តុំត្រពាំងស្នាច់ ព្រៃបូតកង ហើយនិងសាពួន ខាងលិចភូមិត្រពាំងផ្លុង មួយចំនួនទៀតនៅម្តុំភូមិព្រះផ្តៅ។ យើងកំពុងស្ទាក់វ៉ៃយ៉ាងខ្លាំង ធ្វើឱ្យខ្មាំងទ្រឹង ដោយដុបៗ តាមកន្លែងដូចខាងលើ។ ហើយមុខព្រួញភូមិស្វាយ ខ្មាំងបុកខ្លាំងក្លា យើងរបើកបច្ចុប្បន្នដកមកត្រៀមការពារទប់ខ្មាំងនៅភូមិច្រករំដេង កាត់ភូមិត្រពាំងផ្តៅ ថ្នល់២២ ខាងកើត ខាងត្បូងភូមិរំសែង។ យើងបានរៀបចំកម្លាំងតូចៗវាយពីមុខយ៉ាងខ្លាំងក្លា។ លទ្ធផលថ្ងៃទី៩ ខែ១២ កម្ទេច

ខ្មាំងបាន១០៥ក្បាល របួស១៨៦ក្បាល កម្ទេចដេកា-៧៥មួយដើម កាំភ្លើងយន្តប្រាំមួយដើម បាញ់ឆេះរថក្រោះប្រាំគ្រឿង។ ឆេះដោយជាន់មីនពីរគ្រឿង នៅក្នុងរថក្រោះហ្នឹងជាន់មីន យើង ខ្មាំងជាន់មីនយើង ខ្មាំងសារភាពថា ងាប់មេបញ្ជាការកងពលវាពាក់ផ្កាយ២ មួយក្បាល។ សូមជូនពរសុខភាពល្អ មហាជ័យជម្នះ ព្រឹកថ្ងៃទី១០ ខែ១២, ផុន។"

លោកមិនចាំឈ្មោះទេ ប៉ុន្តែព្រឹត្តិការណ៍នេះ តើលោកមានបានដឹងឮដែរទេ? ព្រោះនៅក្នុងព្រឹត្តិការណ៍នៅផ្លូវលេខ២២ ហើយចំណុចអំមិញយើងបានប្រាប់ហើយ លោកប្រហែលជាស្គាល់ហើយតំបន់ភូមិសាស្ត្រហ្នឹង។ តើមានព្រឹត្តិការណ៍ហ្នឹងកើតឡើង តើលោកចង -- តើគាត់ -- លោកចាំដែរទេ តើរំឭកតាមសារទូរលេខហ្នឹង តើលោកចាំព្រឹត្តិការណ៍ហ្នឹងដែរទេ?

[១៥:៣២:៥៦]

**ឆ៖** ខ្ញុំទើបឮឯកសារហ្នឹង ប៉ុន្តែភូមិភាគបូព៌ាហ្នឹងឈ្មោះ ផុន ដូចជាគ្មាន ហើយសភាពការណ៍ដែលៗនិយាយក្នុងឯកសារនេះ ត្រាចខោលនេះវាគ្មានទ័ពណានៅ គឺទ័ពខ្ញុំហើយ។ អ៊ីចឹងបានពួកហ្នឹងគឺៗវ៉ៃពួកខ្ញុំ វ៉ៃពួកខ្ញុំត្រាចខោលហ្នឹង។ ពួកនេះប្រហែលជាពួកភូមិភាគកណ្តាល ឯកសារនេះ។ ត្រាចខោលមានវៀតណាមណានៅ អត់ទេ ពួកខ្ញុំនៅឈរជើងនុំង ពីខាងលិចត្រពាំងផ្លុងរហូត។ អាពួកហ្នឹងដែលធ្វើរដ្ឋប្រហារវ៉ៃពួកខ្ញុំ ឯកសារហ្នឹង។ ខ្ញុំមិនដែលឃើញ។ ភូមិភាគកណ្តាល និរតីអីហ្នឹង។

**ស៖** ប៉ុន្តែព្រឹត្តិការណ៍នេះ គឺខាងអ្នកចេញសារទូរលេខមិនច្បាស់ទេ ប៉ុន្តែថ្ងៃទទួល គឺថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៧ ម៉ោង១៣ និង១៥នាទី មានន័យថា ព្រឹត្តិការណ៍ហ្នឹងកើតឡើងនៅក្នុងខែធ្នូ ឆ្នាំ១៩៧៧។ យើងបានសួរបញ្ជាក់លោកហើយ អំមិញថា នៅក្នុងព្រឹត្តិការណ៍ដែលកើតមានឡើងនៅក្នុងអំឡុងពេលនោះ តើនៅក្នុងភូមិភាគបូព៌ាហ្នឹង មានកងទ័ពមកពីភូមិភាគផ្សេង ឬក៏កងទ័ពមកពីមជ្ឈិមហ្នឹងឈរជើងនៅភូមិភាគបូព៌ាដែរឬទេ? លោកបានឆ្លើយបញ្ជាក់យើងហើយថា គឺអត់មានទេ គឺមានតែកងពលទាំងឡាយដែលរៀបចំឡើយដោយនៅភូមិភាគបូព៌ា ហើយជាអ្នកម្ចាស់ការក្នុងការការពារទឹកដីនៅទីនោះ។

**ឆ៖** ឥឡូវខ្ញុំសូមជម្រាបជូនអ៊ីចេះ សភាពការណ៍កើតនៅភូមិភាគបូព៌ាវាមានពីរ។ ក្នុងឆ្នាំ៧៧ ដែលយើងវ៉ៃវៀតណាមមួយគន្លាក់ ពេលដែលវ៉ៃហើយ វៀតណាមបុកចូលមក។ ដល់បុកចូលមកដាច់កងពលហ្នឹង មានភូមិភាគកណ្តាលមួយទៀតទៅជួយ ឃើញណេះ។ ទៅជួយ ដល់ពេលទៅជួយហ្នឹងមក ភូមិភាគកណ្តាលហ្នឹងឈ្មោះ កែ ពក ហ្នឹង ដល់ទៅជួយទៅ មានវ៉ៃវៀតណាមណា វាលេងអាខ្មែរគ្នាឯងហ្នឹង។ អាហ្នឹង ចាប់ផ្តើមវាយគ្នាឯងហើយ។ ត្រង់ហ្នឹងមានពីរ ចុង អាឆ្នាំ៧៧ហ្នឹង ចុងខែ១២

ហ្នឹង វាមានពីរគន្លាក់។ ហើយនៅត្រាចខោល នៅវាលរំសែង នៅទួលសង្កែ នៅទាំងអស់ អត់មានពីណាមកនៅទេ មានតែទ័ពខ្ញុំឈរហ្នឹង។ អ៊ីចឹងមានតែពួកហ្នឹង ទៅវាយពួកខ្ញុំនេះ ភូមិភាគកណ្ដាលនេះ និរតីហ្នឹង ទៅវាយពួកខ្ញុំ ពួកហ្នឹង។ ខ្ញុំទើបនឹងឃើញទេ ឯកសារនេះ មិនដែលឃើញផង។

[១៥:៣៥:៣៧]

**ស៖** ប៉ុន្តែព្រឹត្តិការណ៍មួយដែលយើងរំឭកការចងចាំនោះ ដែលរំលេចខ្លាំងជាងគេនោះគឺ "ខ្លាំងសារភាពថាបានកម្ទេច អាមេបញ្ជាការកងពលវាពាក់ផ្កាយ២ មួយក្បាល" នេះជាចំណុចដែលប្រកាសពីការជោគជ័យរបស់កងទ័ពកម្ពុជា ចំពោះជម្លោះជាមួយនឹងវៀតណាមហ្នឹង នៅចំណុចដែលយើងបានប្រាប់អម្បាញ់មិញហ្នឹង ប៉ុន្តែវាបានកម្ទេចផ្កាយ២មួយរូប ហើយផ្កាយ២នេះ ជាមេបញ្ជាការកងពលរបស់វៀតណាម ដែលតាមព័ត៌មាន តាមសារភាពរបស់ខាងៗវៀតណាម នេះតាមៗរបាយការណ៍។ តើព្រឹត្តិការណ៍ធំធេងប៉ុណ្ណឹង តើលោកដឹង? តើលោកនៅចងចាំដែរឬទេ នូវព្រឹត្តិការណ៍ថា មានហេតុការណ៍កើតឡើងរហូតដល់សម្លាប់បាននូវមេបញ្ជាការមួយ ដែលមានឋានន្តរស័ក្តិផ្កាយ២ ដែលនៅក្នុងរថក្រោះ?

**ឆ៖** ខ្ញុំអត់ជឿ។ ប៉ុល ពត នេះវារាយការណ៍នេះ គ្រាន់តែយកថា អង្គភាពវាធ្វើបានទេ ប៉ុន្តែធាតុពិតមិនមែនសម្លាប់បានផ្កាយ២ នៅក្នុងរថក្រោះនោះ អត់ជឿ។ ពេលហ្នឹងដែលវាយគ្នាហើយ អាពួកភូមិភ្លៀន -- ភូមិភាគកណ្ដាល និងមជ្ឈិមហ្នឹង ចាប់ផ្ដើមវាយវៀតណាមផង វាយខ្ញុំផង។ ខ្ញុំអ្នកតស៊ូកងពលខ្ញុំ។ អ៊ីចឹងនៅខាង ពីចាប់ពីត្រាចខោលមក សុទ្ធតែកងទ័ពខ្ញុំហើយ នៅព្រៃរំដេង ព្រៃអីហ្នឹង គ្មានវៀតណាមនៅហ្នឹងទេ។ អ៊ីចឹងពួកហ្នឹង វាយ វាធ្វើបំបាក់បំបែក ធ្វើរដ្ឋប្រហារហ្នឹង ពួកនេះ ប៉ុន្តែខ្ញុំមិនដែលឃើញទេ ឯកសារហ្នឹង ទើបនឹងឃើញនេះ ទើបនឹងលោកបង្ហាញខ្ញុំនេះ។ ដែលវាធ្វើរដ្ឋប្រហារនេះសម្លាប់ខ្មែរនិងខ្មែរ ពួកហ្នឹង។ អ៊ីចឹងខ្ញុំអត់ដឹងទេ រឿងវាយវៀតណាមនេះ សុទ្ធរបាយការណ៍ភូតរបស់វាទេ។ រឿងម៉េចៗ អាហ្នឹងស្រេចនឹងវាហើយ យើងអត់ដឹង។

[១៥:៣៧:៤៧]

**ស៖** បាទ អរគុណ។ ហើយយើងមានឯកសារមួយចំនួនទៀត ហើយនេះ គឺសូមជូនឯកសារតែពីរទៀតទេ ដើម្បីលោកជួយពិនិត្យមើល។ ឯកសារទី១ គឺលេខ E3/988 ហើយឯកសារទី២ គឺ E3/905។ ហើយនេះ ជាប្រភេទសារទូរលេខ។ ឯកសារទី១គឺ E3/988 គឺសារទូរលេខលេខ១ សារទូរលេខ១ ទូរលេខ១៖ "គោរពជូនបងធំជាទីគោរពស្នេហា សូមជ្រាប។ ហើយ បងភឹម ជម្រាបជូនបង

អំពីសភាពការណ៍ខ្មាំងនៅព្រឹកថ្ងៃទី២២ ខែធ្នូ ឆ្នាំ -- ម៉ោងដប់ វាបុកយើងធ្លាយនៅត្រង់មុខព្រួញស្គុំ, អំពុក, ជីពាំង។ នៅថ្ងៃត្រង់ ថ្ងៃទី២២ ខែធ្នូនេះ រថក្រោះខ្មាំងមួយគ្រឿង បានចូលមកដល់ត្រង់ម៉ាស៊ីនកិនស្រូវ ផ្លូវចូលបំបែកកណ្តាលជ្រុំបន្តិច -- កណ្តោលជ្រុំបន្តិច។ ហើយមានអាមួយគ្រឿងទៀត វាបរមកពីក្រោយដែរ មកដល់ត្រង់ម្តុំភូមិបទទន្លា ខាតកើតកណ្តោលជ្រុំ។ អាទីមួយ វាបាញ់ឡានដឹកអង្ករយើងមួយគ្រឿង នៅត្រង់ម្តុំម៉ាស៊ីនកិនស្រូវ ហើយកណ្តោលជ្រុំ។ រួចហើយ វាបត់ក្បាលទៅវិញតាមផ្លូវជាតិលេខ៧ ត្រង់ទៅកើត។ ហើយវា កាលវាមក គឺតាមផ្លូវលេខ៧ដែរ ហើយនៅកុំគ្នានៅត្រង់ផ្លូវបំបែកតាហៀវ។ ហើយរយៈរសៀលថ្ងៃទី២១ ខែ១២នេះ រថក្រោះវា និងថ្មើរជើងវា ក្តាប់ចំនួនមិនបាន បានសង្គ្រប់គ្រប់ព្រៃម៉ៃសាក់ ផ្លូវបំបែកតាហៀវ នៅអន្លង់គ្រេះ។ យើងកំពុងវាយវា និងទប់វា នៅត្រង់ចំណុចនេះ។ ហើយសូមជ្រាប ដោយគោរព ភូមិភាគបូព៌ា ថ្ងៃទី២២ ខែធ្នូ សមមិត្តពាម។"

លោក មានទី១ យើងសួរថា ហេតុការណ៍ដែលកើតមានឡើងដែលយើងបានប្រាប់ហ្នឹង អំពីចំណុចពេលវេលា ហើយនិងទីកន្លែងដែលកើតមានឡើង មានហេតុការណ៍កើតឡើងអំពីការវាយលុកចូលដោយរថក្រោះរបស់វៀតណាមមកដែនដីកម្ពុជាហ្នឹង ហើយនិងតើមានព្រឹត្តិការណ៍ហ្នឹងដែរទេ លោកនៅឈរជើងនៅម្តុំហ្នឹង?

[១៥:៤០:៥៥]

**ឆ៖** អ៊ីចឹងឯកសារនេះ ដែលបង្ហាញឲ្យខ្ញុំឃើញថា ឯកសារនេះគឺត្រឹមត្រូវ។ ឯកសារឈ្មោះ ព្រាម នេះ ប៉ុន្តែខ្ញុំមិនដែលជួបផ្ទាល់ទេ ប៉ុន្តែឈ្មោះ មិត្តពាម នេះ, ពាម នេះជាសេនាធិការភូមិភាគបូព៌ា ពាម នេះ។ អ៊ីចឹងនេះជាគ្រាន់ជាឯកសារវាយការណ៍ឲ្យ សោ ភឹម ទេ ជាឯកសារសម្រាប់វាយការណ៍ទេ។ ខ្ញុំទទួលស្គាល់ឯកសារនេះ នៅខាងភូមិភាគបូព៌ា។

**សៈ** បាទ អរគុណ។ ហើយនិងឯកសារមួយទៀត គឺយើងអំមិញហើយគឺ E3/905 ទូរលេខ ០៩។ "ហើយជម្រាបមកមន្ទីរ៨៧០ជាទីគោរពស្នេហា។ អំពីសភាពការណ៍យួន ថ្ងៃទី០២ ខែធ្នូ ឆ្នាំ ១៩៧៧ វាវាយបុកចូលមកកាន់តំបន់ចម្ការកៅស៊ូក្រែកទាំងមូល តែកម្មករគ្រប់ភូមិបានដកថយ ដកផុតនៅសល់តែកងទ័ពកាំភ្លើងធំយើង ក៏ដកថយមកជើង ខាងដំបែអស់ដែរ។ តាមដំណឹងច្បាស់ថា ការទៀតព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៧ ពួកយួនវាចូលតាមផ្លូវ វាយមកចម្ការហួប រហូតចក គោកស្រុកហើយ។ រវាងពីរថ្ងៃនេះ មានការប៉ះទង្គិចនឹងកងទ័ពយើង -- មិន១ – ពីរថ្ងៃនេះ ឥតមានការប៉ះទង្គិចជាមួយកងទ័ពយើងទេ។ ចំណែកឯប្រជាជន រត់ពពាក់ពពូនជាច្រើន។ ខាងចម្ការកៅស៊ូ និងរោងចក្រ

មេមត់ឲ្យដំណឹងមិនទាន់ ដោយនីរសារមិនទាន់ត្រឡប់។ កម្លាំងយួននេះមក តាមកងទ័ពឲ្យដឹងថា ពួកវាប្រើមានច្រើន មានឡាន និងរថក្រោះ។ ហើយទ័ពយើងពពាក់ពពូនពីក្រោយ ជាមួយនឹងកាំភ្លើងធំយើងឥតដឹងថាជាពួកឯង ឬក៏ពួកគេទេ។” ហើយព្រឹត្តិការណ៍នេះ គឺអ្នករាយការណ៍នេះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៨ ភួង ឈ្មោះ ភួង។ ទី១ តើព្រឹត្តិការណ៍នេះ តើលោកដឹងដែរទេ ព្រឹត្តិការណ៍ដែលកើតមានឡើងនេះ? ហើយឈ្មោះ ភួង ហ្នឹងជាអ្នកណាគេ? តើលោកស្គាល់ដែរទេ?

**ឆ៖** អានេះ ខ្ញុំទទួលស្គាល់ថា ឯកសារនេះនៅភូមិភាគបូព៌ា។ នេះជាសេចក្ដីរាយការណ៍។ ប៉ុន្តែខ្ញុំស្គាល់វាអត់ច្បាស់ទេ ឈ្មោះ ភួង ឈ្មោះអី មិនដែលជួបគ្នាទេ អត់ដែរទេ។ ប៉ុន្តែសភាពការណ៍កើតឡើងវាអ៊ីចឹងមែន។ កាំភ្លើងត្បាល់ កាំភ្លើងអី ក៏វាអ៊ីចឹងមែនរឿងហ្នឹង។ អាហ្នឹងខ្ញុំទទួលស្គាល់ គឺទទួលស្គាល់ពីរឯកសារនេះ រាយការណ៍ពីសភាពការណ៍។ អានេះរាយការណ៍ពីឲ្យ តាភឹម។ ពីរហ្នឹងទទួលស្គាល់ថា ឯកសារហ្នឹងនៅភូមិភាគបូព៌ា ប៉ុន្តែក្រៅពីហ្នឹង អត់មានទេ។ ខ្ញុំអត់ស្គាល់ច្បាស់ទេ ភួង ហ្នឹង។

[១៥:៤៤:៣៥]

**ស៖** បាទ ឥឡូវនេះដោយសារលោកបានដឹងឯកសារនេះ យើងក៏ចង់បង្ហាញលោកពីរបីឯកសារទៀតដែរ ពាក់ព័ន្ធនឹងបញ្ហានេះ។ ប៉ុន្តែលោក អំមិញលោកបញ្ជាក់ថាតើឈ្មោះ ភួង ហ្នឹងមានតួនាទីអ្វីដែរ? ឬក៏លោកមិនស្គាល់តួនាទីរបស់គាត់ទេ? ហើយគាត់ធ្វើអី?

**ឆ៖** ខ្ញុំសូមជម្រាបជូនអ៊ីចេះ ឈ្មោះ ភួង ហ្នឹងខ្ញុំអត់ស្គាល់ទេ តួនាទីរបស់គាត់។ គ្រាន់តែគេនិយាយ ប៉ុន្តែមិនដឹងតួនាទីធ្វើស្អីៗយើងអត់ដឹង ព្រោះខាងរដ្ឋអំណាច ហើយខាងទាហានវាខុសគ្នា អ៊ីចឹងវាផ្ដាច់គ្នាទាំងអស់ ខ្ញុំអត់ដឹង។ អានេះខាងការងាររដ្ឋអំណាច យើងការងារទាហាន។ អ៊ីចឹងវាអត់ដឹងទេ។ ជំនាន់នុ៎ង គឺផ្ដាច់គ្នាទាំងអស់ អត់ដឹងទេ វាផ្ដាច់ជាកង់ៗតែម្ដង។

**ស៖** យើងមានសារទូរលេខមួយចំនួនទៀត ហើយឥឡូវនេះយើងសង្ខេប យើងយកតែបីទៀតទេ ដើម្បីសួរបញ្ជាក់លោក។

ក្រឡាបញ្ជីយកឯកសារនេះជូនសាក្សី! -- អ៎! មន្ត្រីរដ្ឋបាលតុលាការ!

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

[១៥:៤៦:៤៣]

បាទ ហើយសូមមើលឯកសារទី១ គឺសារទូរលេខលេខ៧ ឯកសារហ្នឹង E3/906។ ហើយ “ជម្រាបមក៨៧០ជាទីគោរពស្នេហា។ សភាពការណ៍យួនឈ្លានពានថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៧ វេលា

ម៉ោងដប់ពីរ ពួកវាពង្រីកមុខព្រួញពីតាហៀវ រហូតដល់បទទន្លា បណ្ដោយផ្លូវជាតិលេខ៧។ ឯមុខព្រួញខាងជើង វាពង្រីកដល់ស្រម៉, ទឹកជ្រៅ, នាងទើន, ខ្នុរ មានបររថក្រោះជាន់ប្រជាជន យុទ្ធជនពិការដែលរត់ខ្ចាត់ខ្ចាយជាច្រើន។ ម្យ៉ាងទៀតថ្ងៃម្សិល ២២ ពួកវាបានចាប់កងចល័តកំពុងច្រូតស្រូវ បានរត់ប្រហែលជា១០០នាក់។ ហើយដំណើរកងទ័ពវានេះ គឺស្ងាត់ណាស់ ឥតមានបាញ់ក្នុងក្លាំងទេ ចូលដល់ វាដុតកម្ទេចតែម្ដង ភូមិដាជាដើម ដុតអស់ហើយ។ ហើយពេលកន្លងមកនេះ ខ្ញុំបានដាក់ការទាក់ទងផ្ទាល់ទៅសមរភូមិផង ទៅ បងភឹម ផងដើម្បីយល់អំពីសភាពការណ៍ តែឥឡូវនេះដាច់ គ្រាន់តែបានដឹងតាមរយៈនីរសារចុះឡើង ស៊ើបការណ៍ និងដឹងតាមរយៈប្រជាជនដែលរត់លូនតែប៉ុណ្ណោះ។ ហើយនៅខាងចម្ការកៅស៊ូក្រែក មានមកដល់ឆ្លូងខ្លះ ខាងមេមត់ មិនទាន់បានដឹង។ ចំណែកឯខ្ញុំដកមកឆ្លូងទុកតែយុទ្ធជន៣០នាក់នៅការពារ។ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៧, ភួង។"

ហើយលោកមិនស្គាល់ឈ្មោះ ភួង ទេ ប៉ុន្តែលោកទទួលស្គាល់ថា របាយការណ៍ និងព្រឹត្តិការណ៍នោះ គឺកើតឡើងនៅភូមិភាគបូព៌ា ចំពោះឯកសារមុន។ ហើយឥឡូវឯកសារនេះ នៅសារទូរលេខនេះ តើលោកស្ដាប់ហើយអំពីព្រឹត្តិការណ៍ដែលកើតមានឡើងនេះ តើលោកអាចបញ្ជាក់បានទេតើព្រឹត្តិការណ៍នេះ មានកើតមានឡើងនៅតំបន់ដែលលោក -- លោកដឹងទេថា មានព្រឹត្តិការណ៍នេះកើតឡើងដែរឬទេ?

**ឆះ** ខ្ញុំសូមៗជម្រាបជូននៅឯកសារនេះ ព្រឹត្តិការណ៍ហ្នឹងគឺកើតឡើងអ៊ីចឹងមែន ខ្ញុំទទួលស្គាល់បីឯកសារហើយ។ ហ្នឹងកើតឡើងអ៊ីចឹងពិតប្រាកដមែន អ៊ីចឹងមែន។

[១៥:៤៩:២០]

**សះ** បាទ ហើយឯកសារមួយទៀត គឺឯកសារ E3/108 ទូរលេខ០៩។ "ជម្រាបមកមន្ទីរ៨៧០ ជាទីគោរពស្នេហា ពួកយួនវាក្ដាប់ផ្លូវលេខ៧ តាំងពីភូមិស្ទឹង ទៅដល់ផ្សារមេមត់ ខាងជើងផ្លូវជាតិវាចូលដល់នាងទើន, ខ្នុរ, ជាច។ ចម្ការកៅស៊ូវាចូលទាំងស្រុង ដុតជ័រ និងយកបានអង្ករ អំបិលជាច្រើន។ កៅស៊ូមេមត់ ខាងលិចចូលដល់ភូមិស្ពាន រោងកម្មករ ដកថយអស់។ រោងចក្រមេមត់ក៏ដកថយដែរ។ ព្រឹកមិញថ្ងៃទី២៤ នេះវាចូលមុខព្រួញមកពីខាងកើតរោងចក្រ។ ខ្មាំងរឹបអូសយកអីវ៉ាន់ប្រជាជនជាច្រើន ចាប់ប្រជាជន និងកងចល័តច្រូតស្រូវខាងណោះជាង២០០នាក់ វាធ្វើបាបយ៉ាងខ្លោចផ្សាណាស់ វាសម្រាតនៅខ្លួនទទេ ទាំងប្រុសទាំងស្រី ហើយនៅមុខវាកុំឲ្យបាញ់។ ខាងយើងមកដល់ថ្ងៃទី១៤ ខែធ្នូនេះ គឺស្ថិតនៅក្នុងសភាពបាត់ម្ចាស់ការដដែល កងទ័ពខ្ចាត់ខ្ចាយ ទាក់ទងគ្នាមិនបាន ក្ដាប់មេបញ្ជាការមិនបាន ក្ដាប់ខ្មាំងមិនបាន គ្រាប់រំសេវដែលយកទៅត្រៀមប្រយុទ្ធតាមព្រំដែនកន្លងមក ត្រូវខ្មាំងរឹបអូសជាច្រើន

ហើយព័ត៌មានយើងក្ដាប់ផ្ទាល់ពីសមរភូមិតាមរយៈទាក់ទងខាងចម្ការកៅស៊ូ និងកងទ័ពយើង។ ខ្ញុំប្រើតែអ្នកភ្ជាប់ជាមួយសមរភូមិដែរ។ ម៉្យាងទៀត កងឈ្លបចម្ការកៅស៊ូក៏តាមដានខ្លាំងជាប់។ ចំពោះសភាពការណ៍នេះផ្ទាល់ -- ខ្លួនខ្ញុំផ្ទាល់ យើងខ្ញុំសូមឲ្យអង្គការជួយធ្វើអន្តរាគមន៍ឲ្យបានឆាប់។ ហើយខាង បងភឹម បានផ្ញើសំបុត្រឲ្យមកខ្ញុំ ខាងចម្ការកៅស៊ូចាត់កម្លាំងប្រយុទ្ធប្រញាប់ ហើយឯកភាពដោយចាត់តាំងអង្គភាព “គ” រួចហើយ ៗលទ្ធភាពពង្រឹងក៏បានច្រើន។ ដូច្នេះយើងខ្ញុំស្នើអង្គការអនុញ្ញាតឲ្យខាងកៅស៊ូចាត់តាំងកម្លាំងចំនួនប្រាំបី “ឃ” ហើយសូមអង្គការជួយផ្ដល់អាវុធសម្រាប់ប្អូន “ឃ” ដោយមានអាវុធបាញ់រថក្រោះផង ផ្ដល់ឲ្យឆាប់នៅមន្ទីរកៅស៊ូនៅជុប។ ហើយថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១០៧៧, ភួង។” លោកដឹងទេព្រឹត្តិការណ៍ដែលយើងបានបង្ហាញលោកដែលនូវខ្លឹមសារនៃៗសារទូរលេខនេះ តើវាមានព្រឹត្តិការណ៍នេះកើតឡើងមែនដែរឬទេ? ហើយលោកដឹងព្រឹត្តិការណ៍នេះដែរឬទេ?

[១៥:៥២:២៩]

**ឆ៖** ឯកសារនេះតាមលោកបង្ហាញខ្ញុំ ៗមើលឃើញថា ឯកសារនេះខាងចម្ការកៅស៊ូ ភួង ហ្នឹង ភួង ហ្នឹងខាងទទួលខាងផ្នែកចម្ការកៅស៊ូ។ នៅផ្នែកខាងកៅស៊ូទេ ខាងកៅស៊ូប៊ូព៉ាហ្នឹង ឈ្មោះ ភួង ហ្នឹង មិនមែនផ្នែកខាងទាហាន ផ្នែកអីទេ កាន់ខាងកៅស៊ូនេះ ឈ្មោះ ភួង ហ្នឹង។ ខាងចម្ការកៅស៊ូនេះរាយការណ៍ឲ្យភូមិភាគនេះ។

**ស៖** បាទ រាយការណ៍ឲ្យមន្ទីរ៨៧០ទេ ហើយឯកសារអំមិញនេះ គឺឯកសារ E3/908 សូមបញ្ជាក់ ហើយមានការបកប្រែ ហើយមានបកប្រែមិនត្រូវគឺទៅជា108 តាមពិត908។ ហើយសូមបញ្ជាក់ដែរជាដើម្បីជាប្រតិចារឹកថា សារទូរលេខដែលយើងបានបង្ហាញឲ្យសាក្សីពិនិត្យ ហើយនិងពិភាក្សានេះ គឺសុទ្ធតែជាសារទូរលេខដែលមានតែមួយទំព័រទេ។

ហើយចុងក្រោយ គឺយើងមើលឯកសារចុងក្រោយនេះគឺសារទូរលេខលេខ០៨ ឯកសារ E3/909។ “ហើយជម្រាបមកមន្ទីរ៨៧០ ជាទីគោរពស្នេហា។ ទើបទទួលដំណឹងបានអំពីចម្ការកៅស៊ូមេមត់ថា នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៧ ពួកយួនចូលតាមដង រហូតដល់ការដ្ឋានចម្ការកៅស៊ូមេមត់ខាងលិច បានចាប់ឡានដឹកអង្ករពេញមួយគ្រឿង ហើយមុខព្រួញវាមួយទៀតនៅតាមផ្លូវជិត តម្រង់ទៅផ្សារមេមត់ និងខ្ទង់ក្រពើ ប៉ុន្តែក្ដាប់មិនបាន តើខាងនោះយ៉ាងម៉េចនៅឡើយ។ តាមវិភាគពួកវាមានទិសវាយលុកយកតំបន់២១ ចាប់ពីផ្លូវប្រធាតុ ឆ្លងទៅកើត លទ្ធភាពវាមាន ព្រោះយើងប្រហោងក្នុងគ្មានទ័ពធំមានតែឈ្លបកៅស៊ូប្រយុទ្ធមិនបាន ឯទ័ពធំ ទៅទប់ខាងព្រំដែនអស់តាំងពីយូរមកហើយ។ ឥឡូវនេះ

កំពុងបាត់ម្ចាស់ការ។ តាមដឹងបងប្អូនទ័ពធំ ខ្ចាត់ខ្ចាយទាក់គ្នាមិនបានទេ។ ហើយសភាពការណ៍នេះ បញ្ជាក់ខាងលើនេះ ព្រោះខ្ញុំឃើញសភាពការណ៍នេះផ្ទាល់ ព្រោះថា ជាប់នឹងបញ្ជាការកងពល និងចុះឡើងជាប់នឹងអង្គការ។ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១០៧៧, ភួង។"

[១៥:៥៥:៣៧]

លោកៗស្តាប់បានហើយនូវរបាយការណ៍នៅក្នុងសារទូរលេខនេះ។ តើព្រឹត្តិហេតុ ព្រឹត្តិការណ៍នេះ តើលោកដឹងដែរឬទេ? តើលោកចាំដែរទេ តើមានហេតុការណ៍ហ្នឹងកើតឡើងនៅតំបន់ និងពេលវេលាដូចយើងបានអាននៅក្នុងសារទូរលេខនេះដែរឬទេ?

**ឆ៖** អ៊ីចឹងខ្ញុំសូមជម្រាបលោកចៅក្រម ព្រោះអ៊ីចេះ តាមមុខព្រួញទីមួយៗទទួលខុសគ្នា ប៉ុន្តែវាជាផ្លូវការ យើងបើមើលរបាយការណ៍វាយឲ្យភូមិភាគហ្នឹង ឈ្មោះ ភួង ហ្នឹង ភួង ហ្នឹង គឺគ្រប់គ្រងខាងចម្ការកៅស៊ូ ឈ្មោះ ភួង ហ្នឹង ខាងការងារស៊ីវិល មិនមែនការងារទាហានទេ។ អ៊ីចឹងវាយការណ៍ឲ្យភូមិភាគ។ ហើយដល់មុខព្រួញដែលចូលមកហ្នឹង ខាងមេមត់ហ្នឹង វានៅ ង-១៥៤។ អ៊ីចឹងខ្ញុំគ្រាន់តែដឹងគ្រាន់តែដឹងថាវាចូល ៗមែន ប៉ុន្តែឲ្យឃើញជាក់ស្តែងនឹងភ្នែក យើងអត់ឃើញទេ ព្រោះយើងនៅ១៥៦ វាខុសគ្នាប៉ុណ្ណឹង។ ប៉ុន្តែរឿងហ្នឹង វាទៅអ៊ីចឹងមែន។ ឯកសារប្អូននេះ គឺឯកសារនៅចម្ការកៅស៊ូដែលវាយការណ៍ឲ្យៗភូមិភាគនេះ ឲ្យដឹងនេះ ឈ្មោះ ភួង នេះ។ ភួង ហ្នឹងគ្រប់គ្រងខាងផ្នែកចម្ការកៅស៊ូ យើងគ្រាន់តែដឹងប៉ុណ្ណឹងទេ។ ប៉ុន្តែរឿងហ្នឹងវាអ៊ីចឹង។ ទទួលស្គាល់ឯកសារប្អូននេះ ខ្ញុំទទួលស្គាល់ថា ឯកសាររបស់ភូមិភាគនេះ វាយការណ៍ជូនភូមិភាគ។ មានតែប៉ុណ្ណឹងទេ។ ប៉ុន្តែឲ្យខ្ញុំដឹង ឃើញផ្ទាល់ភ្នែកអត់ឃើញទេ ព្រោះមុខព្រួញខុសគ្នា។ នៅមេមត់ ហើយនៅក្រែក វាៗឆ្ងាយណាស់ ៣០គីឡូនោះ មិនមែនជិតទេ។ អ៊ីចឹងវាអត់អាចដឹង ប៉ុន្តែរឿងហេតុ -- រឿងរ៉ាវដែលកើតឡើង វាទៅអ៊ីចឹង រឿងហ្នឹង។ យើងដឹងទៅអ៊ីចឹង រឿងហ្នឹង។ ហ្នឹងសូមជម្រាបជូនចៅក្រមតែប៉ុណ្ណឹង។

[១៥:៥៧:៣៩]

**ស៖** អរគុណ។ ហើយសំណួរចុងក្រោយរបស់យើង គឺសូមលោកបញ្ជាក់ យើងបានសួររួចហើយ ប៉ុន្តែតាមយើងនៅចងចាំ គឺថាលោកមិនទាន់ឆ្លើយតបនឹងសំណួររបស់យើងទេ។ នៅគ្រប់សមរភូមិដែលមានជម្លោះវាយលុក វាយគ្នាជាមួយនឹងវៀតណាមហ្នឹង យើងចង់និយាយពីបញ្ហាការខូចខាតវិញ បើធៀប ប្រៀបធៀបទៅ រវាងភាគីទាំងពីរ បាន័យថា ភាគីកម្ពុជា និងភាគីវៀតណាម ដែលនៅសមរភូមិជម្លោះហ្នឹង អាស្រ័យលោកអាចមានតាមបទពិសោធន៍របស់លោក និងការសង្កេតរបស់លោក

ថាតើមានខាងភាគីណាខូចខាតច្រើនជាង ទាំងអាយុជីវិត ទាំងទ្រព្យសម្បត្តិ?

**ឆ៖** ឥឡូវខ្ញុំសូមៗជម្រាបជូន លោកចៅក្រម តាមបទពិសោធន៍។ អាហ្នឹងខ្ញុំនិយាយនៅមុខព្រួញខ្ញុំទេ មុខព្រួញគេ ខ្ញុំអត់និយាយទេ ព្រោះយើងអត់ដឹង យើងនិយាយស្មានអត់កើត។ រឿងពិតដែលយើងឃើញប៉ុនណា យើងធ្វើប៉ុណ្ណឹង។ អ៊ីចឹងមុខព្រួញខ្ញុំវិញ ១៥៦ហ្នឹង បើតាមការពិសោធន៍ ហើយយើងប្រយុទ្ធជាក់ស្ដែងនៅសមរភូមិ យើងគ្រាន់តែបាត់បង់អាយុជីវិតច្រើន។ ប៉ុន្ដែទ្រព្យសម្បត្តិបាត់តិចទេ ឯវៀតណាម គឺបាត់បង់ទ្រពសម្បត្តិច្រើន ព្រោះចាប់ផ្ដើមប្រយុទ្ធមុនដំបូង យើងរឹបអូសយកបានទ្រព្យ បានអាវុធធុនធ្ងន់មកលើយើងហើយ ទាំងអស់។ ក្រោយមកបុកជាប់ដៃគ្នា ប្រទង់ប្រទាញគ្នា យើងបេះ យើងៗបាញ់រនេះរថក្រោះប៉ុន្មានគ្រឿងទៀត។ ឃើញដែរ? អ៊ីចឹងពេលដែលជាប់ដៃគ្នាហ្នឹង ខ្សែទូរស័ព្ទហ្នឹង វៀតណាមដែលវាយមក យើងចូលទៅ ទាញគ្នាម្ខាងម្នាក់ វាដណ្ដើមខ្សែទូរស័ព្ទហ្នឹង ទាញគ្នាទៅវិញទៅមក។ ពេលហ្នឹងប្រយុទ្ធមិនមែនដូចឥឡូវទេ ប្រយុទ្ធស៊ីសាច់ហុតឈាមគ្នា។ ច្រើនណាស់២០ម៉ែត្រ ៣០ម៉ែត្រច្រើនបំផុត ឆ្ងាយ។

[១៥:៥៩:៤៩]

អ៊ីចឹងការគ្រោះថ្នាក់ច្រើនណាស់ ទាំងខ្មែរ ទាំងវៀតណាមអ៊ីចឹង ដូចខ្ញុំជម្រាបជូនអ៊ីចឹង។ គ្រាន់តែសែងរបួស ក៏សែងក្នុងដីដែរ អត់មានសែងខាងលើបានទេ។ គ្រាន់តែភូមិពោងមួយ ខាងជើងត្រពាំងផ្គុង ប្រយុទ្ធគ្នា៣ថ្ងៃ។ ៣ថ្ងៃនុ៎ង អត់លែងឃ្លានបាយហើយ ធុំតែរំសេវទេ។ អាវុធយុទ្ធភណ្ឌធុនតូចលែងឮហើយ ឮចាប់ពីបេទៅ ១០៥, ១៣០។ ដល់បែកអាភូមិពោង ឃើញប៉ុន្មាន? វៀតណាមគ្រាន់តែនៅក្នុងលេណដ្ឋាន៥០នាក់ ទម្រាំនឹងវ៉ៃបែក ។ ប៉ុន្ដែឯៗយើងក៏អស់ច្រើនដែរ មិនមែនតិច។ អ៊ីចឹងថាពេលនុ៎ងយើងប្រយុទ្ធខ្លាំងមែនទែន ស៊ីសាច់ហុតឈាមគ្នា។ សង្គ្រាមនៅកម្ពុជា ខ្ញុំជម្រាបជូនចៅក្រមចុះសង្គ្រាមវ៉ៃអាមេរិក សង្គ្រាមវ៉ៃ លន់ នល់ សង្គ្រាមវ៉ៃខ្មែរក្រហម ចាញ់សង្គ្រាមវ៉ៃវៀតណាមទេ វ៉ៃស៊ីសាច់ហុតឈាមគ្នា ទាញគ្នាយកតែម្ដង។ អ្នកណា--

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ សុំអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមគូសបញ្ជាក់ថា មានទូរលេខផ្សេងទៀតដែរ ដែលយើងនឹងបង្ហាញទៅសាក្សីរូបនេះ គឺឯកសារ E3/891, E3/983, E3/922, E3/251, E3/901,

E3/10669.1 ឯកសារ E3/1067។ ហើយទូរលេខទាំងអស់នេះ ត្រូវបានព្រីនហើយអស់ហើយៗ មានជាភាសាខ្មែរដែរ។ អ៊ីចឹងខ្ញុំសុំឲ្យផ្តល់ទូរលេខទាំងអស់នេះទៅសាក្សីរូបនេះ ដើម្បីឲ្យគាត់អាចអាននៅពេលយប់នេះ ហើយព្រឹកស្អែកនេះ យើងអាចសួរគាត់ទាក់ទងទៅនឹងបញ្ហានេះ។ សុំយោបល់ពីគាត់។

[១៦:០២:២៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០២ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1065 ហើយសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកសាក្សី។ ហើយសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។ ហើយអង្គជំនុំជម្រះក៏សូមអរគុណដែរ លោកមេធាវីប្រឹក្សាសាក្សី លោក ចាន់ សម្បូរ។ ហើយសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះ នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

ហើយបង្គាប់ឲ្យអនុរក្ស -- ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោកសាក្សីហ្នឹង វិលត្រឡប់ទៅកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់មកកាន់ មកផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត នៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោកជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*